# មជ្ឈមណ្ឌលឯកសារកម្ពុជា

*ករណី ឡេង គីម I03939*

*សម្ភាសន៍ជាមួយ ឡេង គីម ហៅ គង់ គីម អាយុ៨៦ឆ្នាំ ជាម្ចាស់ប្រវត្តិរូប*

*មុខងារសម័យខ្មែរក្រហមៈ អ្នកយាមគុក*

*ជាប្រធានប៉ុស្តិ៍រដ្ឋបាលឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

*សព្វថ្ងៃនៅភូមិតាំងក្នុង ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

*ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០២*

*សម្ភាសន៍ដោយៈ អ៊ីសា ឧស្មាន, វ៉ាន់ថាន់ ពៅដារ៉ា និង ដាន់ សុដា*

*សរុបៈ ៦៣ទំព័រ*

ឧស្មានៈ សុំស្គាល់ឈ្មោះ?

គង់ គីមៈ ឈ្មោះបច្ចុប្បន្នណឹង?

ឧស្មានៈ បាទៗ

គង់ គីមៈ គង់ គីម ។

ឧស្មានៈ ចុះពីជំនាន់?

គង់ គីមៈ ពីជំនាន់ដែលនៅផ្ទះ ឡេង គី ឈ្មោះដើម ។

ឧស្មានៈ ឡេង គី ឈ្មោះដើម?

គង់ គីមៈ ណឹងហើយ នេះដែលគេបញ្ចេញខ្ញុំមកធ្វើទ័ព កាលឆ្នាំ៧៣ណឹងខ្ញុំដាក់កែនបណ្ដោយ ។

ឧស្មានៈ ជំនាន់ ប៉ុល ពតនេះ?

គង់ គីមៈ បាទ ចេញនៅ៧៣ណឹង ខ្ញុំកែដាក់ឈ្មោះ គង់ គីម រហូតដល់បច្ចុប្បន្ននេះ ។

ឧស្មានៈ ពូសព្វថ្ងៃពីអាយុប៉ុន្មាន?

គង់ គីមៈ ៨៦ ។

ឧស្មានៈ លោកពូសព្វថ្ងៃជាស្អីដែរលោកពូ មានតួនាទី?

គង់ គីមៈ មេប៉ុស្តិ៍ ប្រធានប៉ុស្តិ៍រដ្ឋបាល ។

ខស្នានៈ ប្រធានប៉ុស្តិ៍រដ្ឋបាលសង្កាត់?

គង់ គីមៈ បាទ សង្កាត់ នឹងឃុំដូចគ្នា ។

ខស្នានៈ ឃុំអី?

គង់ គីមៈ ឃុំជៀប ។

ខស្នានៈ ស្រុកទឹកផុស?

គង់ គីមៈ បាទ!

ខស្នានៈ លោកតា ប្រពន្ធលោកតាឈ្មោះអី?

គង់ គីមៈ តេង ម៉ុត ។

ខស្នានៈ គាត់អាយុប៉ុន្មានហើយ?

គង់ គីមៈ អាយុ៤៤ ។

ខស្នានៈ ហើ លោកតាបានរៀបការជាមួយគ្នានៅឆ្នាំណា?

គង់ គីមៈ នៅឆ្នាំ១៩៨០ ។

ខស្នានៈ ស្រុកកំណើតលោកតានៅណា?

គង់ គីមៈ នៅស្ទោង-កំពង់ធំ ។

ខស្នានៈ ហើ ឪពុកម្តាយលោកតាឈ្មោះអីដែរ?

គង់ គីមៈ ម្តាយឈ្មោះ ឡេង គា ។ ឪពុកឈ្មោះ ដូ ឡុង ។ ម្តាយខ្ញុំស្លាប់ ប៉ុនឪពុកនៅនេះ ។

ខស្នានៈ រស់នៅណា?

គង់ គីមៈ រស់នៅស្រុកស្ទោងណឹង ។

ដារ៉ាៈ នៅកំពង់ធំនោះវិញ អត់អញ្ជើញគាត់មកនៅជាមួយ?

គង់ គីមៈ ស្រុកកំណើតកើតណោះ ខ្ញុំរសាត់តាមធ្វើទាហាន បានធ្លាក់មកនៅណេះ ។

ខស្នានៈ ចុះលោកតា បានមកនៅភូមិនេះនៅឆ្នាំណា?

គង់ គីមៈ នៅឆ្នាំ១៩៧៩ ។

ខស្នានៈ នៅណើងជាស្រុកកំណើតប្រពន្ធរបស់លោកតា?

គង់ គីមៈ បាទ ស្រុកកំណើតប្រពន្ធ ។

ខស្មានៈ អូ! ចឹងលោកពូមកនៅស្រុកខាងប្រពន្ធ?

គង់ គីមៈ បាទ!

ខស្មានៈ សព្វថ្ងៃលោកពូមានកូនប៉ុន្មាននាក់?

គង់ គីមៈ កូន ៤មានគ្រួសារ២ នៅ២ ។ ៤នោះ ស្រី៣ប្រុស១ ។

ខស្មានៈ លោកពូខ្ញុំសុំលោកពូជួយនិយាយប្រាប់ពីដំបូងបង្អស់ ពេលដែលលោកពូនៅតូចៗណឹង លោកពូបានរៀននៅកន្លែងណា ហើយបន្ទាប់ជាបន្តបន្ទាប់មក ។ កាលលោកពូនៅជាមួយឪពុក ម្តាយណឹង?

គង់ គីមៈ កាលនៅឪពុកម្តាយខ្ញុំ កើតនៅឆ្នាំ១៩៥៦ដល់នៅជាមួយឪពុកម្តាយណឹងមិនទាន់បាន រៀនសូត្រទេ ព្រោះកាលណោះនៅវ័យក្មេង ។ កាលនៅឆ្នាំ១៩៧៣គឺគេបានយកទៅធ្វើជានិរសាស្រុក ប៉ុល ពត ។

ខស្មានៈ ស្រុក?

គង់ គីមៈ បាទ! និរសាស្រុកស្មោង ។ ធ្វើនិរសាបាន១ឆ្នាំ បានគេបញ្ជូនមកខេត្តកំពង់ធំណឹង គឺគេបញ្ជូនមកវ៉ៃនៅ ទាហានខេត្តកំពង់ធំ ។ ដល់៧៤គេបញ្ជូនមកព្រែកក្តាមណឹង គឺព្រែកក្តាមយើងខាងជើងភ្នំពេញណឹង គឺវ៉ៃភ្នំពេញណឹង ។ វ៉ៃណឹងបានមួយឆ្នាំ រហូតដល់ឆ្នាំ៧៥ កងពលខ្ញុំខាងភូមិភាគខត្តរ ។

ខស្មានៈ បាទ កងពលអីណឹង?

គង់ គីមៈ កងពល ខ្ញុំមិនចាំរឿងកងពលនៅក្នុងភូមិភាគខត្តរណឹង ។ ដល់៧៥វ៉ៃបែកមុខព្រួញខ្ញុំចូលពីទិសខាងជើងទៅតាមផ្លូវជាតិលេខ៥ណឹង គឺ ដល់បែកភ្នំពេញ គឺមានកងពល ៣១០ ដឹកនាំដោយ អឿន ។

ខស្មានៈ បែកភ្នំពេញ?

គង់ គីមៈ បាទ ហើយវរសេនាធំរបស់ សុង វាត្រូវជាតា ខ្ញុំអត់ចាំដែរ ។

ខស្មានៈ វរសោនធំឈ្មោះ សុង?

គង់ គីមៈ បាទៗ!

ខស្មានៈ វរសេនាធំលេខប៉ុន្មាន?

កង់ គីមៈ វរសេនាធំលេខ៣៧ មិនទេ ហើយវរសេនាតូចខ្ញុំអត់ចាំដែរ ប៉ុន្តែស្គាល់តែប្រធានកង វរសេនតូចឈ្មោះ យឹម ។

ខស្មានៈ ចាំលេខទេពូ?

កង់ គីមៈ អត់ លេខអត់ចាំ ។ ចាំតែលេខកងពល៣១០ ។

ខស្មានៈ ចុះជាបន្តមកទៀតលោកពូរៀបរាប់ត្រួសសិន?

កង់ គីមៈ បន្តមកទៀតគេឲ្យឈរជើងប្រកាន់នៅក្នុងដីឡូតាមកងពល កងពល៣១០គឺចាប់ពីវត្តភ្នំ កន្លែងឃោសនាការមកជើងមកទល់នឹងព្រែកក្តាមណឹង កងពល៣១០ភូមិភាគឧត្តរ ។ ទុយលគោកមួយ, អន្លង់ក្ងាន, ទួលសង្កែទៅលើកងពលខ្ញុំណឹងនៅណឹង ។

ខស្មានៈ នៅក្នុង អឿន ដដែល?

កង់ គីមៈ បាទ អឿន ដដែល ហើយខ្ញុំណឹងជាកងពិសេសឲ្យវរសេនាធំរបស់ សុង ណឹង ។

ខស្មានៈ ប្រធានកងពិសេសឈ្មោះអី?

កង់ គីមៈ ខ្ញុំមិនអាចចាំបានទេ ។

ខស្មានៈ ចុះបន្ទាប់មកទៀតទៀតពូ?

កង់ គីមៈ ស្គាល់មួយឈ្មោះ ប៉ុន មួយ ។

ខស្មានៈ បន្ទាប់មកទៀតពូមានបានធ្វើអីទៀតទេ?

កង់ គីមៈ បន្ទាប់មកទៀតគេឲ្យនៅការពារនៅតាមតូបៗ តាមប៉ុស្តិ៍ៗ ការពារតាមថ្នល់ជុំវិញវត្តភ្នំម៉ាដួរជ្រោយចង្វារណឹងមួយប៉ុស្តិ៍ ។

ខស្មានៈ នៅឆ្នាំណា?

កង់ គីមៈ នៅឆ្នាំ៧៥ដែលបែកណឹង ។

ខស្មានៈ ប្រហែលជាឆ្នាំប៉ុន្មាន?

កង់ គីមៈ ឆ្នាំ៧៦ ។

ខស្មានៈ ឆ្នាំ៧៦?

កង់ គីមៈ បាទ ហ៊ឺក្រោយមកគេផ្ទេរកម្លាំងខ្ញុំឲ្យទៅយាម ហៅថាយាមគុក ។ គុកណឹង គុកនៅម្តុំខាងកើតវត្តភ្នំណឹងគឺកន្លែង១គុកកម្មង គឺគុកពីសង្គមពីដើមមក គឺមានកន្លែងគេស្រេច បន្ទប់គេធ្វើ កន្លែងគេស្រេច ។

ខុស្នានៈ	គុកណឹងមានឈ្មោះអីដែរ?

គង់ គីមៈ	គុកណឹងគ្រាន់ថា កាលណឹងឈ្មោះមិនដឹង បុិនគុកប្រចាំកងពល ។

ដារ៉ាៈ	សម្រាប់កងពល៣១០?

គង់ គីមៈ	បាទ កងពលណឹង ។

ខុស្នានៈ	គុកប្រចាំកងពល?

គង់ គីមៈ	បាទ!

ដារ៉ាៈ	នៅខាងកើតវត្តភ្នំ?

គង់ គីមៈ	បាទ ខាងកើតវត្តភ្នំណឹង ។

ដារ៉ាៈ	កន្លែងអគ្គិសនីកម្ពុជាណឹងមែន កន្លែងមាត់ទន្លេ?

គង់ គីមៈ	មាត់ទន្លេ បុិនខាងត្បូងរដ្ឋករទឹក ។ គុកណឹង កន្លែងគុកស្រេច ។

ខុស្នានៈ	ចុះឥឡូវគេធ្វើអីគុកណឹ?

គង់ គីមៈ	ឥឡូវខ្ញុំអត់ដែលទៅដង ។

ខុស្នានៈ	ឆ្នាំណាដែលលោកពូទៅយាមគុក?

គង់ គីមៈ	ឆ្នាំ១៩៧៦ ។ ដើមឆ្នាំ១៩៧៦ ហីខ្ញុំយាមណឹងគ្រាន់តែទទួលខុសត្រូវមើលអ្នកគុក ណឹង ហើយពីដើមគុក ពីមុនចាប់ឃើញអ្នកតូចៗទេ ហើយអ្នកមិនស្គាល់ ដល់យូរៗ ទៅ ខ្ញុំអាចស្គាល់ក្នុងកងពលណឹង មានចាប់មេៗកងពលណឹង មេវរសេនាតូចវរសេនា អីនៅនឹងកងពល ណឹងឃើញហ្នឹង ។ ឃើញដាក់ស្តែងយកទៅ ។

ខុស្នានៈ	ចុះក្រោយមកទៀតឆ្នាំ?

គង់ គីមៈ	ដល់ចុងឆ្នាំ៧៦ ចូល៧៧គេដកខ្ញុំចេញ ។

ខុស្នានៈ	ដើមហើយនៅ ដើមឆ្នាំ៧៧ហើយនៅ?

គង់ គីមៈ	បាទ គ្រាន់តែចុងឆ្នាំ៧៦ មកចូល៧៧គេដកខ្ញុំមកព្រលានណឹង មកលព្រលានថ្មីគេ ណឹងមានចិត្តធ្វើគេយកខ្ញុំមកណឹង ។

ដារ៉ាៈ	ឆ្នាំប៉ុន្មានពូ?

គង់ គីមៈ	ចុងឆ្នាំ៧៦ដើមឆ្នាំ៧៧ ។

ខុស្នានៈ	ចុះបន្ទាប់មកទៀតពូ?

គង់ គីម៖ បន្ទាប់មកទៀតដល់ដែលវៀតណាមវ៉ៃណឹង គេប្រមូលខ្ញុំទៅវ៉ៃវិញ ។

ខស្មានៈ ឆ្នាំប៉ុន្មាន?

គង់ គីម៖ ឆ្នាំ៧៧ណឹងហើយ ។ នៅក្នុងឆ្នាំ៧៧ ប្រហែលជាចុងខែ៩ ខែ១០ណឹង យកខ្ញុំទៅវ៉ៃវៀតណាមណឹងចូលទៅខេត្តតៃនិញណឹង ។ ខ្ញុំចូលរួមវ៉ៃកាលណឹង ។

ខស្មានៈ ហឺ លោកពូវ៉ៃនៅណឹង រហូតដល់របបខ្មែរក្រហមណឹងបានចាញ់សង្គ្រាម?

គង់ គីម៖ វ៉ៃដល់៨៨ខ្ញុំរបួសធ្លាយពោះ ។

ខស្មានៈ ៧៨ ឬ៨៨?

គង់ គីម៖ ៧៨ ។

ខស្មានៈ ៧៨?

គង់ គីម៖ បាទ ៧៨ណឹងចូល ៧៨ខ្ញុំចូលដល់ខេត្តតៃនិញណឹង ខ្ញុំរបួសធ្លាយពោះណឹង ចឹងគេបញ្ជូនខ្ញុំមកដេកនៅពេទ្យ ប៉ុល ពតដែរ ពេទ្យ១៧មេសា ។

ខស្មានៈ ពេទ្យ១៧មេសា នៅកន្លែងណា.

គង់ គីម៖ នៅភ្នំពេញណឹងពេទ្យ១៧មេសា ។ ដល់របួសខ្ញុំបានជៀងធូរស្រាលតិច គេបញ្ជូនមកនៅក្នុងព្រលានវិញដដែល ។

ខស្មានៈ ឆ្នាំប៉ុន្មាន?

គង់ គីម៖ ឆ្នាំ៧៨ណឹង ។

ដារ៉ាៈ ពេលជាពីរបួសបង?

គង់ គីម៖ បាទ របួស ។ បានជាសះគេបញ្ជូនពីព្រលានវិញដដែល ។

ដារ៉ាៈ ព្រលានកំពង់ឆ្នាំង?

គង់ គីម៖ បាទ នៅជាមួយពួកខាងបូព៌ាណឹង ។

ខស្មានៈ លោកពូនៅព្រលានណឹងរហូតដល់ពេលណាដែរ?

គង់ គីម៖ ដល់ដែលវៀតណាមវ៉ៃធ្លាយមកចូលដល់ទីក្រុងភ្នំពេញណឹង គេបញ្ជូនពួកព្រលានណឹងយកទៅដាក់អមលាំងណឹង ដែលយកទៅដាក់វ៉ៃចោលម្ដងទៀត ។ វ៉ៃរួមជាមួយពួកបូព៌ាណឹង ។ ឲ្យតែបូព៌ាយកទៅវ៉ៃនៅអមលាំងជាមួយពួកខ្ញុំ ។ ខ្ញុំគេបណ្ដើទៅវ៉ៃដែរ ប៉ុនបានមេកងមួយដែលកាលខ្ញុំ ទៅវ៉ៃនៅតៃនិញ មេកងនោះនៅខាងនិរតីឈ្មោះ

ចាន់ ដល់ពេលគេបណ្ដើរទៅវ៉ៃ គាត់ឃើញខ្ញុំ គាត់ទាញដៃខ្ញុំចេញ ។ របៀបទៅដៃ ណឹង គេថារៀបចំកម្លាំងទៅវ៉ៃយួនទេ ។ គេតម្រង់ជួរមាន អាត្រាក់មួយឈូសដីនៅ អមលាំងណឹង ។ គឺវ៉ៃកាលនោះគឺចម្រាញ់វ៉ៃយកពួកបូព៌ាវ៉ៃទាំងអស់ ។ ខ្ញុំនៅខាង បូព៌ាដែរ ប៉ុនពេលនោះចូលនៅក្នុងភូមិភាគបូព៌ា ដល់គេបម្រុងវ៉ៃទាញខ្ញុំចេញ ។ ហើយកាលហ្នឹងគេវ៉ៃពួកបូព៌ាវ៉ៃម្ដង២០ ម្ដង៣០ ។ វិធីវ៉ៃគេណឹង យកទៅគេតម្រង់ ជួរចឹង អ្នកដែលត្រូវវ៉ៃនៅឈរសេនខាង ។ អ្នកវ៉ៃ ដែលត្រូវគេវ៉ៃនៅកណ្ដាល ។ គេ រៀបចំឡើងឡាននៅសមរភូមិនោះ ដល់ចឹងគេសម្រាកប្រុងឆ្វេងស្ដាំបែរទៅ បានដល់ ចំណុចគេ បានគេចាប់វ៉ៃ ។ ហ៊ី ជុំវិញណឹងគេ ឡោមទ័ពអ្នកមានអាវុធ គេនៅក្រៅ កាលណាអ្នកដែលវ៉ៃហើយរត់រួចទៅគេបាញ់ ។ អ្នកដែល ដែលវ៉ៃហើយចូលណឹងគឺ អាត្រាក់ឈូសលប់នៅណឹង ។ នៅឆ្នាំ៧៨ គឺចុងឆ្នាំហើយជិតចូល៧៩ហើយ ។

ខស្នាន: ណឹង ចុង៧៨?

គង់ គីម: បាទ!

ខស្នាន: មិនទាន់ដើម ៧៩ទេ?

គង់ គីម: បាទ ណឹងគេប្រមូលពួកព្រលានណឹង ប្រមូលពួកព្រលានណឹង ព្រោះព្រលានណឹងគឺ សម្បូរពួកបូព៌ា ។ បានគេយកទៅវ៉ៃបង្ហើយនឹងអមលាំងណឹង ។

ខស្នាន: ចឹងលោកពូខ្ញុំសុំសួរពីដើមឡើងវិញ កន្លែងសំខាន់ៗសុំលោកពូជួយប្រាប់ខ្ញុំផង ។ នៅ ឆ្នាំ៧៣ លោកពូថា លោកពូបានធ្វើជានិរសាស្រុកស្មោងណឹង ណឹងមូលហេតុអីដែរ បានជាលោក ពូបានទៅធ្វើជានិរសាស្រុក?

គង់ គីម: កាលណឹងគេ យកបណ្ដោយ គេហៅយកបណ្ដោយណឹង ។

ដារ៉ា: កាលណឹងហៅតាមរបៀបម៉េច គេហៅយកទៅធ្វើនិរសាណឹង?

គង់ គីម: គេរើសយកតែប្រុស កាលណាបើប្រុសគេចាប់យក បើធំមកសមរភូមិនៅតូចធ្វើនិរ សាឲ្យតែប្រុស លុះត្រាតែវា យើងវាតូចជ្រុលអត់ដឹងអី ត្រឹមម៉ាដឹងត្រូវតែយកកាល ណឹង ។

ខស្នាន៎ គេយកចាប់ពីអាយុប៉ុន្មានទៅធ្វើនិរសា?

គង់ គីម៖ កាលណឹងខ្ញុំនៅអាយុ១៣ឆ្នាំនៅឡើយណឹង។ ក្មេងៗយកទៅគេបំប៉នជាកន្លែងកុមារ បើថានៅស៊ើរគេបំប៉នឲ្យរៀនដឹងពីនិរសារអី ដឹងអីណឹង។ ខ្ញុំតាំងពីណឹងមក ដល់មកបានបេះ កាន់អាវុធ កាន់៧៥ដែលជិតវៃភ្នំពេញហើយនេះ។ កាលមុនដំបូងគេគ្រាន់តែឲ្យដើរតាមគេទេ។

ខស្មាន៖ លោកពូនៅជានិរសាស្រុកស្មោងណឹង គេឲ្យធ្វើកិច្ចការអីខ្លះ?

គង់ គីម៖ រត់សំបុត្រ កាលណឹងមានតែសេះ នឹងកង់ទេ។ ជិះសេះពីឃុំមួយទៅឃុំមួយ។

ខស្មាន៖ កាលដែលទៅធ្វើជានិរសាណឹង តើទឹកចិត្តរបស់ពូចង់ទៅធ្វើជានិរសាណឹងដែរ ឬយ៉ាងម៉េច?

គង់ គីម៖ កាលណឹង ដូចថាសម័យណឹងគេកំណែនយើង ដូចថាមានការនឹកចង់ដែរព្រោះកាលណឹងនៅក្មេងឆោត ពិសេសគឺចង់បានកាំភ្លើងកាន់ហ្នឹង ដូចជានឹកចង់បានកាំភ្លើងកាន់។ ទៅតាមគ្នី ទៅតាមគ្នា កាលទៅជាសមូហភាពចឹងទៅ។

ខស្មាន៖ មូលហេតុអីបានជាចង់បានកាំភ្លើងកាន់?

គង់ គីម៖ វាអត់ដែលមានកាលណឹង អត់ដែលមាន ដូចបានកាំភ្លើងកាន់ដូចថាវាសប្បាយហ្នឹងនឹកកាលណឹងដូចចង់ វារបស់ណឹង វាអត់ដែលមាន កើតមកអត់ដែលឃើញ។

ខស្មាន៖ ហី លោកពូយល់ទេថា ធ្វើជានិរសាណឹងមានផលប្រយោជន៍អី លោកពូធ្វើការនៅពេលណឹង នៅឆ្នាំ៧៣ណឹង គេមានប្រាប់ពូទេ ដើម្បីស្អីទៅ?

គង់ គីម៖ អត់ទេ គេអត់មានប្រាប់អីផងកាលណឹង កាលណឹងគ្រាន់តែកំណែនធ្វើចឹងទៅ ហីរឿងទិសដៅទៅមុខ វាអត់មានមើលឃើញថាម៉េចអត់ទាន់ដឹង។

ដារ៉ា៖ លោកពូ ការងារជានិរសា លោកពូ ធ្វើអីខ្លះលោកពូ?

គង់ គីម៖ បាទ! និរសាសម្រាប់គេប្រើទេ គេប្រើដូចរត់សំបុត្រ មានការងារស្រាលៗ នេះដូចរត់សារថា ហៅថារត់សំបុត្រ គឺដូចជាពាក្យមួយទៅពាក្យមួយចឹងកាលណឹងគេប្រើហ្នឹង ព្រោះ យើងកាលណោះអត់មានប្រដាប់ទាក់ទងអីទេ មានតែមនុស្សរត់ផ្ទាល់ណឹង។

ដារ៉ា៖ ចឹង ពូបានសំបុត្រស្នាមណឹង ពូរត់ពីស្រុកណាទៅស្រុកណាដែរធ្លាប់?

គង់ គីមៈ បាទ ឆ្លងកាត់កាលខ្ញុំនៅស្រុកស្មោងខ្ញុំមានជួនកាលរត់ទៅដល់ស្រុកសណ្តាន់ កាត់តាមកំពង់ស្វាយទៅសណ្តាន់។ កាលទៅជាក្រុម ជួនកាល៣នាក់ ជួនកាល២នាក់ មិនមែនរត់តែឯងទេ។

ខស្នានៈ ហឹ ធ្វើដំណើរដោយមធ្យោបាយអីដែរ?

គង់ គីមៈ សេះ។

ខស្នានៈ ជិះសេះ?

គង់ គីមៈ បាទ!

ជាៈ ហឹ ពួអ្នករត់និរសាណឹង សុទ្ធតែក្មេងៗទាំងអស់?

គង់ គីមៈ បាទ ក្មេងៗទាំងអស់។

ជាៈ ហេតុអី បានជាគេយកក្មេងរត់ចឹងពូ?

គង់ គីមៈ កាលណឹងមិនដឹង ប៉ុនដែល កាលណឹងធ្វើទៅដូចថា គេលើកបញ្ចូលបទចម្រៀងនិរសាអង់អាចណឹង ដោយសារអ៊ី ហើយចិត្តយើងក៏ដោតាមណឹង អត់ចេះខ្លាចមែនកាត់ព្រៃខ្មោចអី នៅក្នុង៣នាក់មានកាំភ្លើងការ៉ាប៊ីនមាំដើមណឹង គឺមិនខ្លាចអីទាំងអស់។ បាទ ណឹងដូចជានាមយើង បញ្ឆោ គឺថាទោះបីត្រង់ណឹងជាសមរភូមិអី ឲ្យតែគេប្រើឲ្យទៅ ដឹងតែពីទៅហ្នឹង ទម្លុះទម្លាយហ្នឹង។

ជាៈ អត់មានការចាប់បង្ខំអី?

គង់ គីមៈ បាទ អត់មានទេ គ្រាន់តែគេប្រើ កន្លងទៅគេបញ្ឆោជាដូច គេមានចម្រៀងនិរសាអង់អាចចឹង មិនខ្លាចអី គេបញ្ឆោតែតាមមនោគមគេណឹង វាទៅជាក្លាហានហ្នឹង ហើយបើសិនថាស្លាប់ គឺវាស្លាប់ដើម្បីជាតិ ស្លាប់មានកិត្តិយសចឹងអត់ខ្លាច។ កាលណឹងទៅតាមចឹងទេ ហ៊ានហ្នឹង ហឹរឿងខ្មោចរឿងអីគឺអត់មានមើលឃើញទេ។ រឿងស្អីដែលស្មុគស្មាញ បើថាស្មុគស្មាញ យើងពុះពារយើងអ្នកក្លាហានហ្នឹង ចឹងចង់តែក្លាហានណឹងហើយ។ អត់ខ្លាចអីទេ។

ដារ៉ាៈ លោកពូ ពេលលោកពូទទួលសំបុត្រដែលលោកពូរត់ជានិរសាណឹង ពូទទួលពីណា?

គង់ គីមៈ ទទួលពីថ្នាក់ស្រុកកាលណឹង។

ដារ៉ាៈ ថ្នាក់ស្រុកជាប្រធាន ឬជាម៉េច?

គង់ គីមៈ បាទ! ជួនកាលប្រធាន ជួនកាលបន្ទាប់ពីប្រធានចឹង ជួនកាលរត់ទៅដាក់ត្រឹមឃុំ គេថាត្រឹមឃុំ គេប្រើត្រឹមណាយើងទៅត្រឹមណឹង ហើយអារឿងបទបញ្ជានោះ បើសិនជាយើងមានគ្រោះមានអី រឿងសំបុត្រនោះ គេអត់ឲ្យចាប់បានហ្នឹងធ្វើម៉េចយើងដុតចោល យើងលេបអាណឹង គឺជាបទបញ្ជាកាលណឹង។ មិនអាចឲ្យអ្នកណាចាប់បានទេ រឿងលិខិតនោះ។ ហ៊ី និរសាកាលណឹង បើសិនជាមានផ្ទាល់រឿងសង្គ្រាមគឺធ្វើម៉េចឲ្យកំណត់ងាប់ខ្លួនឯងបើចាញ់គេគឺសម្លាប់។ មិនឲ្យឆ្លើយ មិនឲ្យយកសារនឹងបែកការអត់។

ជាៈ ហ៊ី មានដែលក្រុមណាមួយបែកការបែកអីចឹងទេ?

គង់ គីមៈ អត់មានក្រុមណាកាត់ទេ ប៉ុនកន្លងទៅកាលណោះ កាលខ្ញុំនៅរត់គេហៅថាខ្មែរស។ ប៉ុនជាក្រុមដៃជើងទាហាន វាមានថា មិនដែលស្ទាក់ទេ ប៉ុនវាមានដែរ ប៉ុនដល់ចឹងគេប្រាប់ថា បើសិនជាជួបក្នុងប្រភេទពួកណឹងគេមិនឲ្យឯកសារនោះ។ អាដេញសំបុត្រស្នាមយើងធ្លាក់មកដល់ ដៃអ្នកដទៃ។ បើនិយាយពីនិរសាជា អាណឹងជាបេះដូងជាជីវិតរបស់គេ គេមិនអាចបែកការបានទេ។

ខស្នានៈ សំបុត្រណឹងនិយាយពីស្អីខ្លះ បានជាមានសារៈសំខាន់ បានគេគិតថាសម្ងាត់ខ្លាំងម៉េះ?

គង់ គីមៈ អានេះជាកិច្ច កិច្ចការរបស់គេ ដែលគេធ្វើដំនាន់ណឹង ឧទាហរណ៍ថាមានផែនការស្អីពីណឹងទៅ ដូចថាទុកដាក់ឲ្យមេឃុំដឹង ព្រោះកាលណោះកិច្ចការលាក់ការណាស់សូម្បីតែអ្នកធ្វើការណឹង មិនអាចដឹងដែរ។ ជួនកាលបើមេៗឃុំណឹងត្រូវដឹងចឹងទៅ ហ៊ីនិរសាណឹងបានន័យថា មើលបានតែស្រោមគេប្រើ កាលនិរសានោះ អត់បេះអក្សរទេ។

ដារ៉ាៈ កាលពីជំនាន់ណឹងពូអាចអានបានទេ?

គង់ គីមៈ បាទ ខ្ញុំអានបានខ្លះ ព្រោះកាលណឹងខ្ញុំមិនបានរៀនសាលាទេ ប៉ុនតាខ្ញុំបានយកទៅបញ្ចូលនៅវត្ត។ បេះតាមលោកខ្លះ។

ខស្នានៈ ហ៊ី យកទៅឲ្យណឹងអ្នកដែលទទួលសំបុត្រណឹងជាអ្នកណាទៅទទួលសំបុត្រពីពូណឹង?

គង់ គីមៈ អាណឹងតាមគោលដៅដែលគេប្រើទៅ ឧទាហរណ៍ បើគេប្រើពីណឹងឲ្យទៅឈ្មោះអី យើង ឲ្យតែឈ្មោះណឹង បើខុសពីឈ្មោះណឹង គេមិនអត់ឲ្យ ឲ្យយើងអតត់ហ៊ានឲ្យទេ ។ គឺតាមរកឈ្មោះណឹងទាល់តែឃើញហ្នឹង ។ កាលហ្នឹងអត់ផ្ញើផ្ដេសផ្ដាសបានទេ ។

ជាៈ ហើ សំបុត្រពូទទួលពីខាងណាមកវិញ?

គង់ គីមៈ ដូចថាខ្ញុំផ្ញើនិរសាស្រុកស្ទោងចឹង ទទួលពីមេស្រុកស្ទោងណឹង ព្រោះនិរសាយើងអាចទទួលបានទាំងអស់ មេប្រធានក៏បាន អនុក៏បាន យើងសម្រាប់តែគេប្រើទេ ។

ដារ៉ាៈ ចឹង លោកពូផ្ញើម៉េចទៅបានកំណត់ថាមួយខាងទៀតបានទទួលសំបុត្រ ហើពេលបានមួយខាងទៀត បានទទួលសំបុត្រហើយ ពូរាយការណ៍មកកន្លែងដើមវិញ?

គង់ គីមៈ យកទៅដល់ដៃគេ ឧទាហរណ៍ថ វយកទៅប្រគល់ណឹង ។

ដារ៉ាៈ ប៉ុន្តែពេលពូត្រឡប់មកកន្លែងដើមវិញ?

គង់ គីមៈ ត្រឡប់ប្រាប់គេ ប្រាប់ថាប្រគល់ដល់ហើយ ហើក្រោយមកក៏គេស្រាវជ្រាវដែរ គេស្រាវជ្រាវពីខាងណឹងថាច្បាស់អត់ ។ ដល់បើសិនយើងអត់ដល់ យើងណឹង យើងគ្រោះថ្នាក់ហើយ

ឧស្មានៈ ចុះអ្នកដែលទទួលសំបុត្រយើងភាគច្រើនមានតួនាទីជាស្អីទៅ ជាប្រជាជនធម្មតា ឬក៏?

គង់ គីមៈ អត់ៗទេ អត់មានទេ កាលណឹងវត់អត់ឲ្យមានប្រជាជនទេ យ៉ាងតូចថ្នាក់មេឃុំ មេឃុំជំនាន់ណឹង ។ អត់មានវត់ឲ្យប្រជាជន ភូមិអីក៏អត់ដែរ ។

ជាៈ ចឹង ពូចៅហ្វាយស្រុកដែលពូទទួលសំបុត្រណឹងមានឈ្មោះអីខ្លះ?

គង់ គីមៈ ឈ្មោះធន មេធំនោះ គាត់ណឹងឈ្មោះ ធន មិនដឹងស្អី ធន ទេ ខ្ញុំភ្លេចហើយ ។

ជាៈ ប្រចាំស្រុកណា?

គង់ គីមៈ ប្រចាំស្រុកស្ទោង ។

ជាៈ គាត់ជាចៅហ្វាយស្រុកហ្នឹង?

គង់ គីមៈ បាទ!

ជាៈ ខាងណា ខាងខ្មែរក្រហមណឹង?

គង់ គឹមៈ បាទ! ខ្មែរក្រហមកាលហ្នឹង វាមិនដឹងថា ខ្ញុំនៅតូច មិនដឹងថាជាស្អី ប៉ុនិនិយាយថា រណៈសិរ្ស គេថារណៈសិរ្ស ។

ដារ៉ាៈ រួបរួមជាតិ?

គង់ គឹមៈ បាទ! រួមរួមជាតិ វានៅស្មើរពេកខ្ញុំអត់យល់ដែរ ។ ហើ ដូចជា ប៉ុល ពត ដែលបែក ភ្នំពេញណឹងក៏អត់ដែលឮដែរ អត់ដែលមានឮឈ្មោះទេ ។ ឮឈ្មោះតែ ខៀវ សំផន ហ៊ូ នឹម, បានឮ ប៉ុល ពត ខ្ញុំអត់ដែលឮទេ ទើបឮដែលយើងសម័យរដ្ឋកម្ពុជា បានឮ ថា ប៉ុល ពត ណឹង ។

ខស្នានៈ ពីមុនអត់ដែលឮ?

គង់ គឹមៈ បាទ! ខ្ញុំអត់ដែលឮទេៗឈ្មោះទេ ហើក៏មិនដែលឃើញមិនដែលអីដែរ ។

ខស្នានៈ ចុះពីការទាក់ទង ពីថ្នាក់ ដូចពីថ្នាក់ខេត្តទៅថ្នាក់ស្រុក ឬពីស្រុកផ្ញើរបាយការណ៍ទៅខេត្ត វិញ តើលោកពូជាអ្នកធ្វើនិរសារត់សំបុត្រឲ្យដែរ ឬក៏យ៉ាងម៉េច?

គង់ គឹមៈ អត់ៗដែលមានដល់ខេត្ត បានត្រឹម កាលណោះគេមិនទាន់ហៅខេត្ត ហៅតំបន់ ។

ខស្នានៈ បាទ ទៅតំបន់ណឹងយ៉ាងម៉េចដែរ?

គង់ គឹមៈ ខ្ញុំបានឮរត់ពីត្រឹមស្រុក ទល់នឹងស្រុក ។

ខស្នានៈ ស្រុកនឹងស្រុក?

គង់ គឹមៈ បាទ! ស្រុកទល់នឹងស្រុក ហើយស្រុកធ្លាក់មកឃុំ ។ បើមកតំបន់អត់ដែលទេ ។

ខស្នានៈ ចុះបើ ការទាក់ទងរយៈតំបន់នឹងស្រុក ឬក៏ពីស្រុកទៅតំបន់វិញផ្ញើរបាយការណ៍ចុះឡើង ណឹងតាមរយៈនិរសាដែរ ឬក៏យ៉ាងម៉េចដែរ?

គង់ គឹមៈ និរសាដូចគ្នា ប៉ុនថានិរសាគេប្រភេទផ្សេង គេធំៗផ្សេងព្រោះកាលណឹង ជំនាន់ណឹង ពិបាកដែល បើថាកិច្ចការណាយើងមិនត្រូវដឹងយើងអត់ដឹងទេ ត្រឹមមកឃើញៗចឹង ។ កាលណាគេប្រើយើង យើងទៅហើយ ហើយយើងដឹងត្រឹមណឹង ទៅត្រឹមណា ដឹងត្រឹមណឹងដែរ ។

ដារ៉ាៈ ចឹងលោកពូ កាលជំនាន់ណឹងលោកពូនៅឆ្នាំ៧៣មែនទេ លោកពូ?

គង់ គឹមៈ បាទ ៧៣ខ្ញុំចេញពីផ្ទះ ។

ដារ៉ាៈ ចឹង ពូមានស្គាល់ឈ្មោះប្រធានស្រុក ឬប្រធានឃុំដែលពូធ្វើការជាមួយណឹង?

គង់ គីមៈ ប្រធានស្រុកឈ្មោះ ធន ណឹងហើយ ។

ដារ៉ាៈ បន្ទាប់មកលោកពូ?

គង់ គីមៈ បន្ទាប់មកនារី អូ នារីណឹងឈ្មោះ យន ។

ខស្មានៈ យួន?

គង់ គីមៈ បាទ អក្សរ យ និង ន គឺយន ។

ដារ៉ាៈ យន?

គង់ គីមៈ បាទ យន ។

ដារ៉ាៈ ចុះនៅឃុំ?

គង់ គីមៈ វាភ្លេចអស់ហើយអត់ចាំបានទេ ។

ខស្មានៈ ចុះតួនាទីក្រៅពីរត់សំបុត្រណឹង មានធ្វើកិច្ចការអីផ្សេងទៀតទេ ជានិរសាណឹង បើអត់មានសំបុត្ររត់ គេឲ្យធ្វើអី?

គង់ គីមៈ អត់មាន ប្រចាំការហ្នឹង សម្រាប់តែរត់និរសាហ្នឹង ។ អត់មានធ្វើស្អីក្រៅពីនិរសាទេ ។ បើយើងរត់ទៅ យើងទៅបាត់ចឹងទៅ វាដូរគ្នា ក្នុងនិរសាណឹងម៉ាក្រុមហ្នឹង ។ មានគ្នាពី១០ទៅ១៥នាក់ ។ ពួកខ្ញុំ៣នាក់រត់ទៅបាត់ ប្រចាំការណឹងនៅនេះ ចាំមានផែនការទៅចេះទៅ ខ្ញុំមកណឹងទទួលទៅចេះទៅ គឺអត់មានថាតែ៣នាក់ណឹងរត់ទៅទេ ក្រុមនិរសាគឺនៅនិរសា សម្រាប់គេប្រើរត់ទេ ។

ជាៈ និរសាមួយស្រុកណឹងគឺរត់ពេញស្រុកណឹងហ្នឹង?

គង់ គីមៈ បាទ រត់ពេញម៉ាស្រុកហ្នឹង ។

ជាៈ អត់មានថាទៅ?

គង់ គីមៈ ឆ្លងស្រុក ។

ជាៈ ឆ្លងស្រុក?

គង់ គីមៈ បាទ ស្រុកទល់នឹងស្រុក ហើយនឹងក្នុងស្រុកណឹង ។

ជាៈ តែទៅខេត្ត?

គង់ គីមៈ អត់មានទេ ។

ជាៈ ចុះ ពូមានដែលដឹងថា មាននិរសាពីខេត្តមកស្រុកដែរ?

គង់ គីមៈ មាន ប៉ុនក្រុមគេផ្សេង ក្រុមណឹង ក្រុមធំៗ ។

ជាៈ ហឺ អានកិច្ចការនៅក្នុងសំបុត្រណឹងយើងអាចមើលបានទេ?

គង់ គីមៈ អត់ដឹងទេ យើងដឹងបានតែស្រោម និងនិរសាដែលនៅជាមួយខ្ញុំណឹង អ្នកខ្លះអត់ចេះទេ ហ៊ីខ្ញុំក៏ចេះស្ទើរតែ ប៉ុនទោះបីចេះឬមិនចេះគេប្រាប់ហ្នឹង ពេលដែលខ្ញុំចូលទៅដល់ខ្ញុំចូល និរសាចឹងគេយកអ្នកចាស់នាំ នាំឲ្យស្គាល់កន្ទុកកន្ទៀត ស្គាល់មនុស្សស្គាល់ផ្លូវអស់ហើយ គេបញ្ជូនចាស់ណឹងមកធ្វើទាហាន។ ដូចខ្ញុំដែរ ខ្ញុំនៅធ្វើនិរសាណឹង ដល់គេបញ្ចូលថ្មី ខ្ញុំនាំឲ្យគេស្គាល់គេ បញ្ជូនខ្ញុំមកមុខ។ បន្តៗចឹងទេ មិនមែនអ្នកណានៅនិរសានៅរហូតទេ។ គេបញ្ចូលថ្មី ដឹងកន្លែងថា ស្គាល់គ្រប់អស់ហើយ គេបញ្ជូនអ្នកចាស់មកមុខហ្នឹង។

ខស្នានៈ ចុះ ពេលដែលប្រគល់សំបុត្រទៅឲ្យ ដូចជាមនុស្សម្នាក់ណឹង តើយើងត្រូវការស៊ីញ៉េទទួល ឬក៏ផ្តិតមេដៃទទួល?

គង់ គីមៈ អត់មានទេ។

ខស្នានៈ អត់មានទេ?

គង់ គីមៈ បាទ អត់មាន។

ដារ៉ាៈ ចឹង កាលជំនាន់ណឹង បែងចែកជាស្រុកជាភូមិដូចយើងឥឡូវដែរ?

គង់ គីមៈ បាទ ដូចយើងមានមេភូមិ មានមេឈ្លប ឈ្លបគេហៅឈ្លបចឹង។ មាននគរបាលភូមិ មានឈ្លបភូមិ មានឈ្លបឃុំ មានមេឃុំ មានមេភូមិ។

ដារ៉ាៈ ស្រុកអីបែងចែកចឹងដែរ?

គង់ គីមៈ ស្រុកស្មោងណឹង ហើយស្រុកដទៃកំពង់ស្វាយ សណ្តាន់ដូចគ្នាបែងចែកចឹងមានភូមិ មានឃុំ ហើយចំពោះប្រជាជនមានរហូតដល់ក្រុម គេប្រមូលធ្វើជាស្រែ ទៅជាក្រុមៗ អត់ឯកជន ទេ ឆ្នាំ៧៣ណឹង ដែលខ្ញុំនៅណឹង។

ជាៈ ចុះ ពូកាលរត់សំបុត្រណឹង បើយើងអត់មានស៊ីញ៉េទទួលពីអ្នកគោលដៅណឹង ចឹងម៉េចដឹងទៅ រាយការណ៍ដល់ទៅថ្នាក់លើវិញថា យើងបានប្រគល់សំបុត្រណឹងទៅឲ្យគេ?

គង់ គីមៈ អត់ទេនៅណឹងអត់ស៊ីញ៉េទទួលទេ ដល់ពេលយើងវិលទៅវិញយើងទៅប្រាប់ថាឲ្យដល់ហើយ។ ឲ្យដល់គេហើយ។ ចឹងឲ្យដល់កិច្ចការគេធ្វើ គេដឹងតែដល់គេធ្វើ វាទាក់គ្នា

ប៉ាត់ហើយ គេចង់ធ្វើស្អីមួយ បើអត់ធ្វើ គេតាមដានយើងណឹង ។ កាលណឹងទទួលបទបញ្ជាសំបុត្រអីណឹង សំបុត្រអីណឹង ទៅដល់កិច្ចការអីគេធ្វើដឹងភ្លាមៗហ្នឹង ។ ឧទាហរណ៍យើងយកសំបុត្រគេឲ្យខាងមេឃុំ ឬ ខាងមេស្រុក ខាងណឹងត្រូវធ្វើអី ខាងនោះគេចាត់វិធានការធ្វើភ្លាម បើកាលណាគេអត់ធ្វើ បានន័យថាយើងណឹងយកសំបុត្រអត់ដល់ទេ មិនរឿងយើង ។

ជាៈ ហ៊ីកាលដែលយកសុំបុត្រទៅណឹង មានកំណត់ថ្ងៃអី កំណត់ពេលវេលាច្បាស់លាស់ទេ ថាត្រូវ ប៉ុន្មានថ្ងៃទៅដល់គោលដៅ?

គង់ គីមៈ បាទ គេប្រាប់ចឹងឧទាហរណ៍ថាយើងរត់សំបុត្ររយៈប៉ុន្មានថ្ងៃឲ្យដល់ បើមានរឿងមានហេតុអីវាមិនដល់ម៉េច មកវិញធ្វើម៉េចឲ្យគេដឹង ។ បើទៅអត់ឲ្យហួសពេលវេលាទេ ឧទាហរណ៍ សំបុត្រឲ្យយើង គេកាល់គីលេទៅតាមតំបន់ឆ្ងាយជិតដែរ បើថាឆ្លងស្រុក គេទុកពេលឲ្យយើងមកអាទិត្យចឹងឲ្យទៅ ទៅ ។

ជាៈ លោកពូ ដែលមានបញ្ហាទៅ អត់ទាន់ពេលវេលាឲ្យគេទេ?

គង់ គីមៈ អត់ដែលមាន ទៅទាន់ ។

ឧស្មានៈ ចុះដែលរត់សំបុត្រឆ្លងកាត់តំបន់ដូចមានខ្មាំងមានអី ត្រូវបត្កប់ខ្លួនលាក់ខ្លួនយ៉ាំងម៉េចទេ?

គង់ គីមៈ អត់ អត់មាន កាលនៅនិរសារអត់មាទេ ។

ឧស្មានៈ អត់មានទេ?

គង់ គីមៈ បាទ!

ជាៈ កាលនៅនិរសាណឹង អ្នកដទៃក្រុមផ្សេងពីនិរសាណឹងគេដឹងថាយើងជានិរសារអត់?

គង់ គីមៈ ដឹង ឧទាហរណ៍អ្នកធ្វើការទាំងអស់ ដឹងយើងនិរសា ។

ជាៈ ចុះប្រជាជនដទៃ?

គង់ គីមៈ ប្រជាជនដួនដឹងដួនមិនដឹងទេ ព្រោះមិនផ្សារភ្ជាប់ជាមួយប្រជាជនទេនិរសា ផ្សារភ្ជាប់ជាមួយត្រឹមថ្នាក់ឃុំអ្នកធ្វើការ អ្នកកាន់អំណាចបានផ្សារភ្ជាប់ បើប្រជាពលរដ្ឋអត់ដឹងទេ ។ ដឹងថាយើងជាកងទ័ព តែឃើញកាំភ្លើងដឹងថាយើងជាកងទ័ព មិនដឹងជានិរសារអី បើថ្នាក់គេធ្វើការបានគេ ដឹងថាយើងនិរសា ។

ដារ៉ា៖ ចុះ បើតាមដែលពូធ្លាប់ធ្វើនិរសាណឹង ឧទាហរណ៍ថា រត់ពីស្រុកទៅឃុំ រត់ពីស្រុកមួយទៅស្រុកមួយទៀត បើសិនជាស្រុកមួយទៀតណឹង ដូចថាបានអនុវត្តតាមផែនការណឹង មានន័យថា សំបុត្រណឹងបានទៅដល់ភូមិឃុំណឹង?

គង់ គីម៖ បាទ បានទៅដល់ៗ

ដារ៉ា៖ បញ្ជាក់តាមរយៈនៃលទ្ធផលនៃការធ្វើវិញ?

គង់ គីម៖ បាទ តាមធ្វើវិញៗ

ដារ៉ា៖ បន្ទាប់ពីនិរសាមក បងទៅកន្លែងមួយទៀតជាទាហាន?

គង់ គីម៖ បាទ ដល់គេបញ្ជូនៗមកតំបន់ខេត្តកំពង់ធំៗ

ដារ៉ា៖ ទាហានណឹងបង?

គង់ គីម៖ បាទ បញ្ជូលចូលមកក្នុងទាហានៗ ប៉ុន ទាហានខ្ញុំណឹង វាក្មេងគេមិនទាន់ឲ្យយើងកាន់កាំភ្លើងអីទេ ប៉ុនដើរតាមៗ ទោះបីគេវៃគ្នាក៏នៅជាមួយគេណឹង គ្រាន់តែមកនៅគេយកមកផ្សាំ ណឹងរយៈពេល៦ខែ ខ្ញុំនៅតំបន់កំពង់ធំណឹង ៦ខែ បានគេបញ្ជូមកៗ ដើរៗអត់ដឹងតាមថ្នល់តាម ព្រៃៗ

ដារ៉ា៖ ដែលទាហាននៅកំពង់ធំណឹង ហៅឈ្មោះកងអីដែរ?

គង់ គីម៖ គេហៅថា ប៉ុនលេខខ្ញុំមិននាំទេ ប៉ុនខ្ញុំគ្រាន់ដឹងថាទ័ពតំបន់ៗ

ដារ៉ា៖ ទ័ពតំបន់?

គង់ គីម៖ បាទ បានដល់គេហ៊ឹកហ៊ឺន គេយកខ្ញុំមកហ៊ឹកហ៊ឺននៅណឹង យប់ឡើងហាត់ ហាត់លូនហាត់ធ្វើវៃគ្នាណឹង ធ្វើម្ខាងធ្វើទាហាន ម្ខាងធ្វើខាងណឹង ឡូនមកនៅហ្នុង ហើយគេឲ្យជញ្ជូនគ្រាប់ ជញ្ជូនអីឲ្យគេ កាន់មកជាមួយគេណឹង ជួនកាលផ្ទុះអាវុធជាក់ស្ដែងជាមួយទាហានចិនទៅ នៅជាមួយគេណឹងទៅៗ

ដារ៉ា៖ ហឺ កាលណឹងពូអាយុប៉ុន្មានដែរ?

គង់ គីម៖ ខ្ញុំបើតាមស្មានទៅ បើមិន១៨, ១៥ហើយ បើឥឡូវខ្ញុំកាល៥៦ខ្ញុំកើត ឥឡូវ ៤៦ហើយៗ

ដារ៉ា៖ កាលណឹងចូលធ្វើទាហាន ចូលធ្វើទាហានណឹងឆ្នាំណា?

គង់ គីម៖ ចូលធ្វើទាហាននៅក្នុងឆ្នាំចេញពីណឹងមក ចូលពី៧៤ៗ ៧៣ ខ្ញុំនៅនិរសាៗ

ខស្នានៈ ហឺ លោកពូគិតថាភារកិច្ចទាហាន ហឺនិរសាណឹងមួយណាដែលស្រួល ឬ ពិបាកជាងវា ខុសគ្នាយ៉ាងម៉េចខ្លះទៅ?

គង់ គីមៈ និរសាលំបាកគឺគេប្រើអត់ដឹងពេល ដឹងម៉ោងទេ ប៉ុន្តែវាអត់មានបាត់គ្នាទេ អត់មានបាញ់គ្នាទេ។ បើមកទាហានមានខ្លះបាញ់គ្នា ប៉ុនកាលណោះដូចថាមកទាហាន វាឆ្អិនហ្វឹកដែល នៅនិរសាមិនចេះខ្លាចអីសោះ វាឆ្អែតពីណោះហើយ ដូចថារៀនសូត្រគេលត់ដុំចឹង បើមកទាហាន ណឹងបើយើងស្លាប់ក៏ស្នាហាជាតិដែរអត់ខ្លាចអីទាំងអស់។ ហឺកាលណឹងគេមានឯកសារដែលជំនាន់ ប៉ុល ពត ប្រោះ បើមានអ្នកណាស្លាប់មួយគេលើកវីរភាពនោះ។ យើងមិនចេះអាន គេអានឲ្យស្តាប់ ចឹងវាចង់បានគំរូនឹងគេណឹងណា។ គំរូណឹងស្លាប់ទៅវាមានឈ្មោះ បញ្ចូលក្នុងឯកសារគេណឹង។ អ្នកស្លាប់ក្នុងនិរសាណឹងមួយ ស្លាប់ក្នុងសមរភូមិ។ ឲ្យតែអ្នកណាក្លាហានគឺចូលកន្លែងខ្លះហើយ។ ចឹងមានស្លាប់ហើយ ស្លាប់ទៅអ្នកក្រោយគឺឈឺចាប់ចង់យកគំរូណឹងកាលណឹង។ ដល់ខ្ញុំធ្វើទាហានណឹងអត់ខ្លាចទេ។

ខស្នានៈ ហឺ ទ័ពតំបន់អ្នកណាជាប្រធានទ័ពតំបន់?

គង់ គីមៈ អត់ ខ្ញុំអត់ដឹងព្រោះកាលណឹង គេយកគ្រាន់តែមកហ្វឹកហ្វឺន៦ខែ។

## Side B

គង់ គីមៈ គេយកមកប្រមូលតាមស្រុក គេយកមកដាក់តំបន់ គេហាត់ដើម្បីបញ្ចូលមកភូមិភាគ។

ខស្នានៈ ចឹង នៅកន្លែងតំបន់ណឹងអត់ដែលបានវ៉ៃគ្នាទេ?

គង់ គីមៈ បាទ អត់ដែលវ៉ៃទេ គ្រាន់តែក្នុងហាត់ ហាត់ធ្វើជាវ៉ៃ។ គេបំភ័យបាញ់ គេបំភ័យចឹងដែរ ប៉ុន្តែគ្រាន់តែក្នុងនាមហាត់ទេ។ រយៈ៦ខែ។

ខស្នានៈ ចឹង លោកពូ បានមកនៅកងទ័ពភូមិភាគណឹងនៅឆ្នាំ៧៥?

គង់ គីមៈ នៅចុងឆ្នាំ៧៤ហើយ។

ខស្នានៈ ចុងឆ្នាំ៧៤ហើយ?

គង់ គីមៈ បាទ ខ្ញុំមកនៅត្រឹម គេបញ្ជូនមកមិនដឹងដើរខ្សៀងពីខាងណាទេកាលណឹង មកនៅត្រឹមព្រែកក្តាមណឹង បានខ្ញុំស្គាល់ព្រែកក្តាម ពាងតា ខាងដែលកន្លែងខ្ញុំនៅ ព្រែកតាទែន

ណឹង ។ ខ្ញុំនៅត្រឹមព្រែកតាទែន ទាហាននៅត្រឹមព្រែកឡោ ហើយខ្ញុំនៅបានប្រហែលជា៥ខែនៅកន្លែងណឹងដែល វ៉ៃចូលភ្នំពេញ វ៉ៃចូលតាមឃ្នួញ ទួលសង្កែណឹង ។

ដារ៉ា: ចឹង ពូពេលទាហាននៅតំបន់ណឹង ពេលហាត់ហើយបញ្ជូលទៅទាហានភូមិភាគអីគេកាលណឹង?

គង់ គីម: ភូមិភាគឧត្តរ ។

ដារ៉ា: ភូមិភាគឧត្តរ?

គង់ គីម: បាទ!

ខស្នាន: ហឺ អឿន ដែលជាប្រធានកងពល៣១០?

គង់ គីម: បាទ ៣១០ ។

ខស្នាន: ចឹងលោកពូស្គាល់ថា មានខ្សែរយៈជាបងប្អូន ឬស្គាល់អ្នកធំណាខ្លះ អឿនណឹង?

គង់ គីម: អត់ដឹង ។

ខស្នាន: ពូអត់ដឹងទេ?

គង់ គីម: បាទ!

ដារ៉ា: ហឺ នៅភូមិភាគឧត្តរជាទាហាន ពូស្គាល់ដូចថាមេបញ្ជាការទាហានភូមិភាគឧត្តរអីទេ?

គង់ គីម: ស្គាល់មេកងពល ស្គាល់ច្បាស់ហ្មង ធ្លាប់ទាំងឃើញទៀត ប៉ុនមេកងពលដែលណឹង គេ

ដារ៉ា: កងពលលេខប៉ុន្មាន?

គង់ គីម: កងពល៣១០ ។ ក្នុងម៉ាកងពលណឹង ម៉ាកងពល៣១០ ជំនួនឲ្យម៉ាភូមិភាគ ។

ខស្នាន: មួយកងពលណឹង?

គង់ គីម: បាទ ជំនួសភូមិភាគឧត្តរយើងណឹង ហើយកំពង់ចាម, កំពង់ធំ គឺមកភូមិភាគ៣១០ណឹង ហើយជាទទួលខាងទ័ព ។ ភូមិភាគឧត្តរណឹង ។

ដារ៉ា: ចឹងកងពល៣១០ ទទួលយោធានៅក្នុងភូមិភាគឧត្តរ?

គង់ គីម: ភូមិភាគឧត្តរ ២តំបន់កំពង់ចាមកំពង់ធំ ។

ដារ៉ា: ហឺ ចឹងនៅក្នុងកងពល៣១០ណឹង បែកចេញជាស្អីទៀតទេពូ?

គង់ គីម: វរសេនាធំ ៣វរសេនាធំ ។

ដារ៉ា: ៣ វរសេនាធំ?

គង់ គីមៈ បាទ!

ដារ៉ាៈ ហើ បន្ទាប់ពីវរសេនាធំ?

គង់ គីមៈ ៣វរសេនាធំ ក្នុងម៉ាវរសេនាធំ វាមាន៣វរសេនាតូច ។

ដារ៉ាៈ ៣ វរសេនាតូចតទៀត ហើ បន្ទាប់ពីវរសេនាតូចមានបែងចែកទេ?

គង់ គីមៈ អនុសេនាធំ៣ ។

ឧស្មានៈ ៣ៗរហូត?

គង់ គីមៈ បាទ ៣ៗរហូត ដល់អនុសេនាតូច ៣ក្រុមទៀត ហើយបានវាមានពីរខែ ពិសេស កងពល វាពិសេសឲ្យកងពួកម៉ាវរសេនាតូច អាណឹងពិសេស ។

ឧស្មានៈ ពិសេសមួយដាច់ផ្សេង?

គង់ គីមៈ ក្នុងមួយកងពលវាមានវរសេនាតូចជាពិសេស ហើយមួយវរសេនាធំវាពិសេស មួយ អនុសេនាធំ ហើយដល់វរសេនាតូចវាពិសេស មួយអនុសេនាតូច វាអត់ដាច់ពិសេស ទេ ពួកពិសេសៗវា ។

ដារ៉ាៈ ចឹង ពូស្ថិតនៅក្នុងកងពល ឬក៏ស្ថិតនៅក្នុង?

គង់ គីមៈ ខ្ញុំនៅវរសេនាតូច ប៉ុនពិសេស ។

ឧស្មានៈ ពិសេស?

ដារ៉ាៈ ពិសេសនៅកងវរសេនាតូច?

គង់ គីមៈ បាទ កងពិសេស ។

ឧស្មានៈ ហើ លោកពូមានតួនាទីជាស្អីដែរនៅពេលណឹង?

គង់ គីមៈ កាលណឹង ខ្ញុំនៅណឹងខ្ញុំអនុសេនាតូច ។

ឧស្មានៈ ប្រធានអនុសេនាតូច?

គង់ គីមៈ បាទ ប្រធានអនុសេនាតូច ។

ឧស្មានៈ គ្រប់គ្រងទាហានប៉ុន្មាន?

គង់ គីមៈ គ្រប់គ្រង៣៦នាក់ ។

ឧស្មានៈ គិតថា លោកពូមាន គុណសម្បត្តិយ៉ាងម៉េចបានជាគេឲ្យធ្វើប្រធាន?

គង់ គីមៈ កាលណឹង ឲ្យតែអ្នកដែលធ្វើការងារល្អ បានន័យថាការងារ ប្រការ១មិនសូវជាឈឺៗ ដេកពេទ្យ ព្រោះកាលណឹងរឿងអាហារ មិនដូចអាហារបច្ចុប្បន្ន អត់មានច្បាប់ទេៗ រឿងទៅលេង ផ្ទះលេងអីគ្មានហ្នឹងៗ អត់មានទេៗ អត់មានច្បាប់ឲ្យតែយើងធ្វើការងារល្អណឹងខាំងហើយ មិនសូវឈឺមិនសូវអីណឹងគឺបានហើយ ។

ដារ៉ាៈ ចឹងនៅកងពិសេសរបស់បងណឹងប្រធានឈ្មោះអី ប្រធានកងពិសេសរបស់បងណឹង?

គង់ គីមៈ នៅកំពង់ចាម ឈ្មោះ ប៉ុន ណឹងហើយៗ បង ផន គឺគាត់ប្រធានអនុសេនាធំៗ ហឺ ប៉ុន ណឹងគឺប្រធានអនុសេនាតូចពិសេសណឹងៗ ភូមិភាគណឹងអត់មានចូលខេត្តណាទេ អ្នកធ្វើមាន តែកំពង់ចាមកំពង់ធំ ចូលតែ២ខេត្តណឹងៗ

ខស្នានៈ នៅ៣១០ណឹង?

គង់ គីមៈ បាទ! ៣១០ណឹង ហើយបាននិរតីខាងតាកែវផ្សេង ព្រោះចាប់ដៃពួកខ្ញុំដែលវៃទៅដើង ទៅពីពួកខ្ញុំទៅគឺចាប់ដៃជាមួយពួកខាងតាកែវៗ ខាងកងភូមិភាគពិសេសៗ

ដារ៉ាៈ ហឺ ក្រោយមកទៅបានពូផ្លាស់ទៅណាទៀតទេ?

គង់ គីមៈ ដែលបែកភ្នំពេញគេឲ្យខ្ញុំឈរភ្នំពេញណឹង ក្នុងការងារណឹង ហើយបើនិយាយពីកាលនៅទូត ខ្ញុំស្គាល់ទូតកូរ៉េៗ ទូតកូរ៉េមានៗ

ខស្នានៈ នៅពេលណឹង?

គង់ គីមៈ ទូតកូរ៉េនៅយើងស្ពានជ្រោយចង្វារ នៅខាងត្បូងជ្រោយចង្វារនោះៗ បើកូរ៉េខ្ញុំឃើញមានខុសពីនោះអត់ ហើយមានកម្មវិធីចឹងដែរៗ ឧទាហរណ៍ថា ពេលដែលទូតអីមកណឹង គេឲ្យយើងស្លៀកពាក់អាហារណឹង ប៉ុនដោះអស់ស្លៀកពាក់ជាស៊ីវិល ទៅទទួលដល់ហើយរៀបចំ បោសផ្លូវណឹងឲ្យស្អាតកាលណឹង គេដាំដូងដាំអីពពុះថ្មណឹង ពួកខ្ញុំណឹងហើយគេឲ្យដាំដូងណឹងៗ ប្រហែលជា៤ជ្រុងដាំថ្មណឹង ហឺចាំទទួលណឹង ហើយផ្លូវណាដែលទទួលភ្ញៀវគេបោស ផ្លូវណាដែល គេអត់ទទួលគេបោសកខ្វិះកខ្វក់ទៅផ្ទះមួយៗសុទ្ធក្រដាសអីស្អុយពេញផ្ទះណឹងហើយៗ ផ្លូវណាដែល គេចាំទុកស្អាតតែមួយផ្លូវៗណឹងហើយៗ យកកម្មករណឹងឲ្យអាហារអីស្លៀកពាក់ជាស៊ីវិលចឹងទៅ ទៅកាន់ផ្កាទៅកាន់អីទទួលចឹងទៅៗៗ

ជាៈ កាលណឹងកូរ៉េខាងណាដែរ?

គង់ គីមៈ វាអត់ដឹង ពូថាទូតកូរ៉េៗមក ។

ខស្នានៈ អត់មានដឹងថាកូរ៉េខាងជើងកូរ៉េខាងត្បូងអីទេ?

គង់ គីមៈ ផ្ទះទូតកូរ៉េនៅខាងជើងពេទ្យកេតុមាលាណឹង ។

ខស្នានៈ និយាយជនជាតិកូរ៉េណឹង វាមាន២ប្រទេស មានកូរ៉េខាងជើង កូរ៉េខាងត្បូង?

គង់ គីមៈ អត់ក្តាប់បានថា ខាងត្បូង ខាងជើងអត់ដឹង ប៉ុនដឹងថាកូរ៉េមានចូលនៅ ។

ជាៈ ហ៊ី ពូដែលបានទទួលគណៈប្រតិភូមិមក?

គង់ គីមៈ បាទ! ទទួលពេលណឹងគេឲ្យយើងដោះខោអាវទាហានអស់ស្លៀកបំពាក់ខោអាវស៊ីវិល ណឹង គ្រាន់តែឈរចឹង ឈរតាមថ្នល់ចឹងគេមក ។

ជាៈ គណៈប្រតិភូពីខាងណាមក ពីប្រទេសណាមកបង?

គង់ គីមៈ ដឹងតែកូរ៉េណឹងហើយ ព្រោះក្នុងដីឡូយើង ឃើញគេពេញ មិនដឹងដីឡូគេ មិនដឹង ខាងណា ប៉ុនដីឡូខ្ញុំណឹង ខាងជើងកេតុមាលាណឹងផ្ទះមួយណឹង គឺទូតកូរ៉េណឹងហ្នឹង ព្រោះណឹង នៅក្នុងប្លុកការពារដើរប្រទ្រុយនោះ ណឹងទូតកូរ៉េនៅក្នុងណឹង ។ ដល់ តំបន់គេ ដូចថាប៉ែកទៅត្បូងៗទៀត វាមានតាមភូមិភាគគេផ្សេងៗយើងអត់ដឹងទេ ។ យើងអត់ចូលបានទេ ។

ខស្នានៈ ចុះពេលដែលបែកភ្នំពេញហើយភ្លាមៗណឹង លោកពូមានតួនាទីធ្វើអីខ្លះភារកិច្ចគេឲ្យ ធ្វើអី? បែកដូចជាប្រជាជននៅទីក្រុងនៅឡើយ?

គង់ គីមៈ កាលចូលទៅគេឲ្យដើរជម្លៀស ។ បញ្ចេញហ្នឹង ដូចថាទាហានណឹង ដើរបញ្ចេញ ប្រជាពលរដ្ឋណឹង ដល់ចឹងយើងដើរកៀរ ។ ជួនកាលប្រជាពលរដ្ឋដែលនៅហ្នុំ ចុះ ដល់ទាល់គេមាន ដែនការគេផ្តាច់ទឹក ។ គេបិទអាមាំស៊ីនរដ្ឋករទឹកនោះ ។

ខស្នានៈ បើសិនជាផ្ទះណាមិនចុះ?

គង់ គីមៈ បាទ! មុនដំបូងមុនៗយើងទៅដល់កៀរមកណែន ប្រជាពលរដ្ឋណឹងចេះតែមកហើយ គ្រាន់តែអ្នកខ្លះអត់មក ដល់អត់មកចឹងដល់ហើយផ្ទះថ្មបិទទ្វារជិតៗ យើងមិនអាច អត់ឡើងបានទេ កាលណឹងមិនមានប្រតិកម្មវាមិនបាញ់គ្នាដែរនោះ ។ មានចូលទៅមាន បាញ់គ្នាសាប់ ជួនកាលទាហាន និងទាហានណឹងច្រឡំគ្នាក៏មានដែរ ព្រោះទាហានកាល ណឹងវាច្រើន ពេលចូលដល់វាភ្ញើតភ្ញើន យកខោអាវទាហានខាងណោះយកមកពាក់ ។

រួចទាហានខាងខ្ញុំដែលទៅពីព្រៃណឹងខោអាវគេតារុង ។ ស្ដើងពណ៌ស្វៃ មួកយើងដេរ ជួយគ្នាអំបោះនោះ ដេរកាត់ៗចឹង ។ ដល់ទាហានយើងទៅដល់មួយចំនួនទៅដល់វា ដូចថា វាភ្លឹតភ្លើនវាសប្បាយនោះ រួចដល់ទៅឃើញខោ អាវទាហានថ្មីៗ យកមក បំពាក់ខ្លួនឯង ។ ដល់ចឹងអាណាដែលគេកាន់បានអានោះយកទៅប្រឡំគ្នា បាញ់គ្នាម៉ា នុលណឹងទៅងាប់ច្រើនដែរ ។ ដល់ខ្ញុំណឹងជម្លៀសប្រជាពលរដ្ឋណឹង ជម្លៀសៗមកដល់ ប្រជាពលរដ្ឋគឹងដែលយើងនិយាយការបន្តបន្ទាប់តាមកងតាមក្រុមយើង យើងដើរ តាមតំបន់យើង ដែលគេឲ្យបែកយើងដឹងថាប្រជាពលរដ្ឋអត់ចេញទេ យើងចូលទៅមិន បានទេរកវិធីវាយការណ៍ទៅ ។

ខស្នានៈ ម៉េចបានចូលមិនបាន?

គង់ គីមៈ ខ្ទប់ផ្ទះថ្មបិទជិតឈឹងហ្នង ជួនកាលបាញ់ទម្លាយចឹងទៅ ហីក៏នៅមានមនុស្សនៅណឹង ។ គាត់អត់ចុះ គេក្រាញអត់ចុះ ដល់ចឹងចុងក្រោយមកដែនការផ្ដាច់អាវផ្ការទឹកនោះ ។ ក្រោយមួយអាទិត្យគេផ្ដាច់អត់ឲ្យមានទឹកប្រើ ។ ពន្លត់ទឹកពួកខ្ញុំអីណឹង ។

ខស្នានៈ ហី ចុះភ្លើង?

គង់ គីមៈ អត់ទេ ភ្លើងនៅ ពួកខ្ញុំណឹងដឹកទឹកទន្លេ ទឹកទន្លេសុទ្ធតែខ្មោចអណ្ដែតសំពោង ។

ជាៈ អាណឹងខ្មោចស្លាប់ដោយសារស្អីគេណឹង?

គង់ គីមៈ ខ្មោចដែលចូលទៅ ដែលថាបាញ់ មិនដឹងណាណីប្រជាជនក៏ងាប់ទៅបាញ់ ដូចថាតាម ចំណង់ចិត្តយើង ។ ដូចថាមនុស្ស ដូចថាអត់សូវមានតម្លៃ បើយើងចង់បាញ់ គឺបាញ់ បានជៀសវៀងទាហានគ្នាឯង រឿងប្រជាពលរដ្ឋបើយើងដាច់ចិត្តថាបាញ់គឺបាញ់ អត់មានទោសទេ ទៅជាខ្មាំងហើយនោះ ។ រួចដល់ចឹងអាត្រាក់អាអីនោះ និយាយទៅ ចាប់ពីគីឡូលេខ៦ទៅ និយាយពីខ្មោចនៅតាមថ្នល់ណឹង ។ ដល់ចឹងអាខ្ទះឡានបើក ជាន់ទៅ ដល់នេះអាត្រាក់គេរុញបញ្ចូលទៅទន្លេទាំងអស់ និយាយពីអណ្ដែតមិនដឹង ប៉ុន្មានថ្ងៃដែលបែកភ្នំពេញណឹងនិយាយពីទន្លេសុទ្ធតែខ្មោចអណ្ដែត ។

ជាៈ ហី ពូនិយាយម៉ិញថា ពេលដែលចូលទៅយើងបាញ់ប្រជាជនអីបាន យើងចាត់ទុក ប្រជាជនណឹងជាខ្មាំង ទ័ពគ្នាឯងណឹងយើងមិនអាចបាញ់បានទេ?

គង់ គីមៈ បាទ!

ដារ៉ា: បទបញ្ជាណឹងចេញពីថ្នាក់លើ?

គង់ គីម: បាទ ថ្នាក់លើបញ្ជាតៗចឹង ។ ប៉ុននោះមានគ្រោះថ្នាក់ទ័ពដោយសារប្រទ្បំ ។ ប្រទ្បំគ្នាដោយសារដូចខ្ញុំថាទាហានយើងដែលទៅពីក្រៅ ទៅដល់វាយកខោអាវទាហាននោះវាថ្មី វាយកមកបំពាក់ ដល់បំពាក់អាទាហានណឹងទៅ ស្មានតែទាហាននោះចឹងចូលទៅមានបាញ់គ្នាចឹង ។

ដារ៉ា: ពូ ខ្ញុំសុំសួរកន្លែងដែលថា បើសិនជាប្រជាជនអត់ចេញពីផ្ទះអីណឹង ហីក្រោយមកមួយអាទិត្យមានការផ្ដាច់ទឹក កន្លែងរដ្ឋករទឹកណឹង តើពូមានដឹងទេថា បទបញ្ជាដែលឲ្យផ្ដាច់ទឹកណឹងចេញ ពីខាងណាមក?

គង់ គីម: រឿងពីថ្នាក់ធំមកខ្ញុំមិនដឹង ប៉ុនដឹងត្រឹមថ្នាក់ដែលគេត្រួតខ្ញុំផ្ទាល់ណឹង ត្រឹមវរសេនាតូចផ្ទាល់ណឹង ។ ប៉ុន ។

ដារ៉ា: បញ្ជាមកយ៉ាងម៉េច?

គង់ គីម: បញ្ជាមកថា មុនដំបូងយើងមិនរាយការណ៍ ពេលណាយើងធ្វើយើងរាយកាណ៍ថា មិនទាន់អស់ទេ ប្រជាពលរដ្ឋ ព្រោះនៅក្នុងមិនព្រមចុះ យើងធ្វើអីអត់កើត ព្រោះផ្ទះថ្មខ្លះ ៣ជាន់-៤ជាន់ យើងឡើងអត់ទៅរួចវាជិតទ្វានោះ ។ កាលហ្នឹងដែលឡើង ជួនកាលប្រជាជនខ្លះមានអាវុធ ព្រោះវាមានការពិសោធន៍ ។ អាខ្លះឡើងទៅប្រជាជនបាញ់មុនខ្លះដើរទៅដើរប្រហែសគ្រាប់បែកមកពីលើ ។ កាលនោះនៅចឹងដើរធ្វើការនៅមានគ្រោះថ្នាក់ ក៏រាយការណ៍បន្តបន្ទាប់ចឹង ដល់ចឹងគេមានផែនការមក ។ យើងរាយការណ៍ទៅបានគេដាក់ផែនការមក គេរកវិធីបិទទឹក ។

ដារ៉ា: ចឹង លោកពូជាអ្នករាយការណ៍ ឬក៏មានអ្នកផ្សេងរាយកការណ៍ឡើងទៅលើ?

គង់ គីម: បាទ ខ្ញុំក៏រាយការណ៍ គេក៏រាយការណ៍ដែរពិគ្រោះគ្នា ក្នុងដូចថាក្រុមយើងធ្វើការ ។ រាយការណ៍ គេទទួលតាមមុខសញ្ញាចឹងឲ្យយើងទទួលខុសត្រូវធ្វើម៉េចឲ្យអស់ ។ ដឹងពីអស់ បើយើងមិនអស់យើងត្រូវរាយការណ៍ឲ្យគេ ។

ដារ៉ា: ចឹង ពេលពូរាយការណ៍ណឹង រាយការណ៍ត្រឹមថ្នាក់ណាពូ?

គង់ គីម: ថ្នាក់វរសេនាតូចដែលបន្ទាប់ពីលើយើងផ្ទាល់ណឹងណា ។

ដារ៉ា: ប្រធានរបស់ពូផ្ទាល់?

គង់ គីមៈ   បាទ! ប្រធានខ្ញុំ ។

ដារ៉ាៈ   យើងរាយការណ៍ត្រឹមប្រធានវរសេនាតូចណឹងឲ្យគេ?

គង់ គីមៈ   បាទ ណឹងហើយត្រឹមណឹងហើយ ។

ដាៈ   កាលណឹងឈ្មោះអីគេ ប្រធានវរសេនាតូចពូ?

គង់ គីមៈ   យឹម ។

ដាៈ   យឹម?

គង់ គីមៈ   បាទ!

ដារ៉ាៈ   ចឹងលែង ប៊ុន ហើយ?

គង់ គីមៈ   ណឹងប្រធានអនុសេនាតូចខ្ញុំស្គាល់ទេ គេប្រធានខ្ញុំក្នុងអង្គភាព វាគ្រាន់តែបន្ទាប់ៗធ្វើការទាំងអស់គ្នា ។ ពិគ្រោះគ្នា បានយកទៅរាយឲ្យមេ ។

ដារាៈ   ឲ្យមេឈ្មោះយឹម?

គង់ គីមៈ   ប៊ុន គាត់អ្នកប្រធានក្នុងអង្គភាពជាមួយខ្ញុំស្គាល់ ។ ជាមួយគ្នាណឹង ។

ដាៈ   ហឺ ពូ ការផ្តាច់ទឹកណឹងរយៈពេលប៉ុន្មានថ្ងៃទៅ?

គង់ គីមៈ   បើតាមខ្ញុំដឹងជាងមួយអាទិត្យ ។ មិនត្រឹមមួយអាទិត្យ ជាងមួយអាទិត្យ ផ្តាច់យូរដែរ ។

ដាៈ   ហឺ លទ្ធផលម៉េចដែរ?

គង់ គីមៈ   បាទ! ដល់ផ្តាច់ទឹកទៅ វាមានការចុះ ដល់ពេលផ្តាច់ទឹក ដូចថាមានអត់ទឹកអីមកមួយឈុលទៀត ។

ឧស្មានៈ   ចុះមកយើងធ្វើម៉េចចំពោះអ្នកដែលគេចុះមកក្រោយ?

គង់ គីមៈ   ចុះមកក្រោយគឺបញ្ជូនមក វុញមកចឹងទៅ មកតាមផ្លូវចឹង ។

ដាៈ   អត់មានការដាក់ទោសដាក់អី បាញ់អី?

គង់ គីមៈ   អត់ទេ ទោសអីទេ ក្នុងកន្លែងនោះអត់មានទោសអីទេ ។

ឧស្មានៈ   ការបញ្ជូនចេញពីក្នុងណឹងតើមានទិសដៅទេ គេឲ្យប្រជាជនទៅម្តុំណា ទៅកន្លែងណាមួយ?

គង់ គីមៈ   អត់ គោលដៅដែលខ្ញុំចូលផ្ទាល់ណឹងអត់មានដឹងទេ ។

ឧស្មានៈ   ឲ្យតែចេញ?

គង់ គឹមៈ ដឹងធ្វើម៉េចវុញឲ្យមកតាមថ្នល់ដែរ ។

ខស្នានៈ ច្រកណាក៏បានដែរ?

គង់ គឹមៈ បាទ! ច្រកណាក៏បានដែរ គេយកទៅដាក់ណា គេនាំទៅខាងណាអត់ដឹង ធ្វើម៉េចឲ្យតែបានចេញពីទីក្រុង ។

ខស្នានៈ លោកពូ វុញណឹង វុញមកដល់ត្រឹមណាបានប្រលែងគេ?

គង់គឹមៈ ដូចថាយើងហ្នឹងងប្រាប់គាត់ឲ្យទៅតាមផ្លូវ ឧទាហរណ៍ មកដើងឲ្យទៅតាមផ្លូវជ្រោយចង្វារ ទៅព្រែកក្តាមគ្រាន់តែបង្ហាញផ្លូវចឹងហើយដល់ ។

ខស្នានៈ ចុះលោកពូអត់នាំមក?

គង់ គឹមៈ អត់នាំទេ ដល់គេទៅចឹងមានដំណាក់គេ ដែលនៅមួយក្រុមៗដែលគេបន្តចឹងទៅ ។ ដូចខ្ញុំកកាយ ព្រោះពិសេសនោះ គេឲ្យដើរកកាយមុខគេណឹង ។

ខស្នានៈ ពូអ្នកកកាយតាមផ្ទះណឹង?

គង់ គឹមៈ បាទ! កកាយឲ្យចេញមក ដល់បញ្ជូននាំទៅ គេស្រាប់គេទៅ ត្រង់គេយកទៅដាក់ណាគេបញ្ជូនទៅណា ហ្នឹងកិច្ចការគេរៀបចំយើងមិនអាចដឹងបាន ។

ដារ៉ាៈ ចឹងពូ ពេលដែលវ៉ៃចូលដល់ភ្នំពេញមុនដំបូង គឺមានផែនការស្រេចហើយថាត្រូវជម្លៀស ប្រជាជនចេញហើយយ៉ាងម៉េច?

គង់ គឹមៈ អត់ដឹងរឿងវ៉ៃណឹង អត់មានប្រជុំប្រាប់ថា ទៅដល់ជម្លៀសប្រជាជនអីអត់មាន អត់មានបានផ្សព្វផ្សាយថា ពេលយើងទៅដល់ជម្លៀសប្រជាជនរបៀបម៉េចៗអត់មានទាំងអស់ ។ ដឹងតែគេវ៉ៃពេលបែក ពេលឡើងដល់ថ្នល់រទេះភ្លើងនោះ ដែលងាប់ខ្លាំងនោះ ខាងហ្នឹងក៏ងាប់ខ្លាំង ដែរមួយថ្ងៃៗសែងឡើងលុឹងមុខហើយ ។ ពេលដែលជិតដល់ខ្លាំងងាប់ក៏ខ្លាំង ជំរុញក៏ខ្លាំងដែរ មានតែផែនការវ៉ៃបុកប៉ុណ្ណឹង អត់មានថាឲ្យបានមកទៅជាជម្លៀសអីអត់មានទេ ។ គ្រាន់ថាបែករួច បែកហើយមានផែនការដាក់ផែនការភ្លាមនោះ ។

ដារ៉ាៈ បែកភ្លាមនៅពេលដែល?

គង់ គឹមៈ បែងចែកថាកងនេះ កងពិសេស កងនេះជម្លៀសប្រជាជនដើរកកាយឲ្យចេញ កងនេះអ្នកនាំផ្លូវ កងនេះបង្ហាញផ្លូវគេបែងចែកចឹង ។

ដារ៉ា: ចឹងកង បានទទួលបញ្ជាពីខាងនាមកវិញ?

គង់ គីម: ទទួលពីមេមកវិញ មេដូចជាវរសេនាតូចចឹង ហើយវរសេនតូចក្រោមបញ្ជាពីកងពល ដែរកន្លែងខ្ញុំអត់ស្គាល់ខ្ញុំស្គាល់ត្រឹមតែកងពលហ្នឹង ។ ត្រង់សេនាធិការពីលើកងពល ហ្នឹងអត់ដឹង ។

ខស្មានៈ ចុះអ្នកដែលចេញបញ្ជាធំហ្នឹងពូដែល?

គង់ គីម: អត់ដែលឃើញ ។

ដារ៉ា: អត់ដឹង ។

គង់ គីម: បាទ! បានត្រឹមកងពលបានឃើញខ្លួន ពីលើហ្នឹងមិនដែលឃើញទេ ។

ដា: ចុះពូ កាលពូនៅធ្វើទាហានពូបានចូលរួមសមរភូមិណាខ្លះ?

គង់ គីម: ទាហានកាលវៃភ្នំពេញ?

ដា: បាទ!

គង់ គីម: បានទៅចាប់ត្រឹមពីកៀនថា វត្តសំរោង វត្តអីហ្នឹង ឃ្លាញអីណឹង ។

ខស្មានៈ ចុះដល់ពេលវៃនៅជិតវត្តហ្នឹងធ្វើម៉េចទៅពូ?

គង់ គីម: មានវត្ត សំបកវត្តណឹង កាលណឹងមានស្អី ។

ដា: ព្រះសង្ឃអីត្រូវគេ?

គង់ គីម: អត់មានទេ បែងផ្សេងនិយាយពីកប៉ាល់ហោះទម្លាក់មួយថ្ងៃៗ មានតែគ្រាប់ មាន ប្រជាជនណា ចាប់ពីព្រែកក្តាមពីព្រៃលិចផ្លូវជាតិហ្នឹង គ្មានផ្ទះប្រជាជនទេ វត្តមានតែ សំបក មានថ្នល់ជាតិហ្នឹងសុទ្ធតែកាត់អ្នកដែលនៅសមរភូមិក្រោយ យប់ឡើងកាប់ ថ្នល់ជាតិហ្នឹង កាប់កំណាត់ៗ ។

ដារ៉ា: កាត់ផ្តាច់?

គង់ គីម: បាទ! កាត់ផ្តាច់ ។ អ្នកដែលនៅត្រៀមមុខ ត្រៀមពីភូមិធំ ត្រពាំងព្រាយអីហ្នឹង ។ មួយវីកឯកសារទន់៣ យុទ្ធមិត្តសាយគេនោះ វៃត្រពាំងព្រាយហ្នឹងឯងកាលទម្លាក់ ។

ដា: ឈ្មុះទេកាលហ្នឹង វៃនៅមុខព្រួញហ្នឹងឈ្មុះទេ ពូ?

គង់ គីមៈ បាទ! យុទ្ធមិត្តសាយដែលគេលើកក្នុងឯកសារនោះ គេជិះយន្តហោះឲ្យរូចកង់ទ័ពមួយកងហើយកប៉ាល់ហោះវាវត់ដេញ ឲ្យវារត់ទៅ កប៉ាល់ឃើញកប៉ាល់ហោះដេញទម្លាក់ដេញមិត្ត សាយឲ្យងាប់ទៅ អង្គភាពវារស់ បានវីរភាពគេហ្នឹង ។ ដាក់នៅក្នុងឯកសារ

ខស្នាៈ មានឯកសារហ្នឹងចុះនៅក្នុងណា ខ្ញុំមិនដែលបានឮផង?

គង់ គីមៈ ឯកសារកាលហ្នឹង គេវ៉ៃផង គេឲ្យមើលផងមានទង់៣ ឯកសារសស្កុះៗទេ ប៉ុនទង់គេក្រហមៗកាលហ្នឹងមាន ។ ឲ្យតែអ្នកណាក្លាហានមានស្លាប់ដោយវីរភាព គឺមានចុះហើយ អ្នកដែលនៅគហ្នឹងគឺចង់បានចឹង ។ គេអត់ចង់ អត់ខ្លាចទេស្លាប់នោះកាលហ្នឹងនោះ ។

ខស្នាៈ កន្លែងជម្លៀសប្រជាជនខ្ញុំសុំសួរតិចទៀតថា ហ្នឹងគេមានប្រាប់ពីមូលហេតុទេថា មូលហេតុអីបានជម្លៀសប្រជាជនចេញពីក្រុង?

គង់ គីមៈ អត់ អត់ដឹង ។

ខស្នាៈ ប្រធានពូអីមានប្រាប់មូលហេតុទេ?

គង់ គីមៈ អត់ទេ ។

ជាៈ អត់មានគោលនយោបាយពីលើ?

គង់ គីមៈ អត់មានទេ គ្រាន់តែប្រាប់ចឹង ព្រោះកាលដែលបញ្ជាពី គេប្រាប់ថាធ្វើអី ធ្វើហ្នឹងហ្នង ។ អត់មានយកហេតុផលអីវែងឆ្ងាយសួរដេញដោលក៏អត់ដែរ ប្រាប់ថា គេប្រើឲ្យ យើងឲ្យដេញប្រជាជានចេញ ឲ្យតែចេញគឺមុខការងារយើងធ្វើទៅ ធ្វើតែប៉ុណ្ណឹងឲ្យសួរថាយកទៅធ្វើ អីអត់មានដូចយើងពិគ្រោះពិចារណាគ្នាចឹងទេ ។

ជាៈ ចឹង គោលនយោបាយ ឬបញ្ជាពីលើ មានថាឲ្យដេញប្រជាជនចេញពីក្រុងទេ?

គង់ គីមៈ បាទ! ធ្វើម៉េចឲ្យជម្លៀសចេញឲ្យផុត ប៉ុនត្រង់ថាគេរៀបចំម៉េចអត់មានប្រាប់ទេ ដឹងពីដេញចឹង ។

ជាៈ ចុះ ពូព្រះសង្ឃអីក្នុងវត្តអីត្រូវយ៉ាងម៉េចដែរ?

គង់ គីមៈ ដេញមកទាំងអស់ណឹងហើយ កាលហ្នឹងចេញមកទាំងថា ទាំងទាហាន ទាហានហ្នឹងបើដោះខោអាវទាន់ចឹងទៅរស់បានយូរទៅ បើថាអត់ដោះខោអាវប្រផេងប្រផាំងគឺបាញ់ចោលហ្នឹងបណ្តោយ ។

ជា៖ ចុះលោកសង្ឃ?

គង់ គីម៖ លោកសង្ឃក៏វិញមកដែរ ។

ជា៖ ចុះបើលោកគាត់មិននិមន្តចេញពីវត្តណឹងធ្វើម៉េច?

គង់ គីម៖ កាលហ្នឹងខ្ញុំឃើញត្រូវតែមក អត់មានប្រកែកប្រណាំងអីទេ ។

ខស្នាន៖ ហឺ ពាក្យដែលប្រើសម្រាប់ឲ្យគេចេញហ្នឹងនិយាយថាម៉េចទៅ ពេលហ្នឹងដូចថាប្រជាជននៅក្នុងផ្ទះហ្នឹង យើងប្រាប់ឲ្យចេញហ្នឹង ប្រាប់ថាយ៉ាងម៉េចទៅ?

គង់ គីម៖ ប្រាប់ថាមេបញ្ជាឲ្យការឲ្យចេញ គ្រាន់តែដេញឲ្យចេញ បើមិនចេញបាញ់ចោលចឹង ។ ប្រើអំណាចបាញ់ចោល អត់មាននិយាយថា គេឲ្យទៅធ្វើនេះធ្វើនោះទេអីអត់មានដឹងទេ យើងដែរ យើងដើរដេញចឹង បើថា បើឃើញហ្នឹងហៅមិនចុះ ឲ្យតែឃើញគឺបាញ់ហ្មង បាញ់ចឹង ។ ថា បើមកដល់ហ្នឹងច្រងើងច្រងរ៉ាងមិនទៅគឺបាញ់បណ្ដោយ មានអីមានតែគេឲ្យប្រើតែប៉ុណ្ណឹងទេ ។ ត្រង់ថានាំទៅ មិនទៅចេះចុះគេយកទៅនេះអត់មានទេ ។

ជា៖ ហឺ ពូដេញប៉ុន្មានថ្ងៃបានប្រជាជនចេញអស់ពីក្នុងក្រុង?

គង់ គីម៖ អូ! ដេញយូរណាស់ បើពាថ្ងៃដែលទៅដល់នោះ និយាយពីណែនមិនដឹងជាស្អីទេ និយាយពីអ៊ូរអ៊រ វាច្របូកច្របល់ហើយផ្ទុះគ្រាប់បន្តបន្ទាប់ គ្រាប់បែក ហើងនឹងគ្រាប់ ។ ទាហានណាដែលភ្លើតភ្លើនទៀត អ្នកណានៅជាកងច្រើនរស់បានបើអ្នកណាវាភ្លើតភ្លើនរុករករបស់ រករបរអី ព្រោះកាលហ្នឹងវាបែក ដូចថាភ្នំពេញវាសំបូរសម្ភារនោះច្រើនស្លាប់ ។ អ្នកខ្លះវាភ្លើតភ្លើនជិះម៉ូតូអីមិនចេះទៅផាប់ចឹងក៏មាន ច្របូកច្របល់ក្រោយប្រហែលកន្លះខែបានគ្រាន់ស្ងប់ ។ ប៉ុននៅមានរប៉ុយៗចឹង យើងយកបានមួយដុំៗបញ្ជូនទៅ ចេះបញ្ជូនទៅមួយដុំៗ ។ ឡានអត់មាន ធ្វើដំណើរបើកទេ ឡានខ្លះវិញនិយាយពីប្រជាជននោះ ។ មានអ្នកខ្លះយកឡានមកប៉ុនវិញ កាលហ្នុងដឹកអី ដឹកលុយប្រាក់មកហ្នឹងលុយកន្លះៗឡាន ។

ខស្នាន៖ ហឺ សម្ភារៈអាចដឹកយកបានទាំងអស់?

គង់ គីម: យកបាន ប៉ុន្តែមានសូវយកទេ យកតែលុយ ប៉ុនលុយកាលនោះគាត់អត់ដឹង អត់ដឹងថាគេអត់ចាយ ព្រោះកាលណឹងមានចាយអី ខាងយើងខាងក្រៅអត់មានចាយលុយទេខាងខ្ញុំ ។ គេរើទៅមានចាយលុយណាអត់ ។

ជា: ចឹងពូ ពេលពូចូលទៅមុខព្រួយពូ មានដេញចំវត្តណាវត្តណីអីទេ?

គង់ គីម: វត្តមានដែរ ប៉ុនមុខព្រួយខ្ញុំចាប់ពីថ្នល់ជាតិពីព្រែកក្តាមទៅរហូតទៅដល់វត្តភ្នំ វត្តភ្នំក៏មុខព្រួញខ្ញុំ វត្តមួយដែលនៅខាងជើងកេតុមាលានោះ ព្រោះមួយកង ៗ ផ្លូវវាច្រើនពេក វត្ត ៗ វាពិបាកណាស់ វត្តភ្នំពេញ វត្តប្រឡាំ ៗ នឹងផ្ទះដែរ ។ វត្តវាធ្លា ខ្ញុំចាំវត្តមិនអស់ដែរ ។

ដារ៉ា: ចឹងមុខព្រួញពូ មានជួបប្រទះពេលចូលមកដល់ ជួបប្រទះមានវត្តមានអាគារដូចជាសារមន្ទីរដូចជាបណ្ណាល័យអីដែរ មុខព្រួញរបស់ពូ?

គង់ គីម: អត់មាន ជួបតែវត្តណាដែលមានលោក ក៏ដេញលោកចេញមកដែរ ។

ដារ៉ា: មានផែនការថាហ្នឹង ពេលជួបវត្តអីចឹង មានផែនការថាត្រូវកម្ទេច ឬយ៉ាងម៉េចទេ?

គង់ គីម: កាលពីជំហានមុនដំបូងអត់ អត់មានដាក់ផែនការថាចូលមកកម្ទេចវត្តកម្ទេចអីអត់មានដែលចូលបែកភ្នំពេញ គឺដឹងតែដេញចេញហ្នង លោកក៏ដេញចេញដែរ គឺប្រើដូចប្រជាពលរដ្ឋដែរ ប្រើលោកដូចតែគ្នាហ្នឹង គឺគេដឹងតែបង្ខំឲ្យចេញដូចតែគ្នាហ្នឹងនិយាយរួមថាបើមានសិទ្ធមិនមក គឺមានសិទ្ធតែបាញ់ចោលណឹងហើយ គឺត្រូវតែដេញចេញ ហើយលោកដែលពេលមកហ្នឹងវាជាទំនៀមទម្លាប់វាចង់ទៅបាត់ជាលោកទៅហើយ ។ កាន់លែងបានហើយ ព្រោះគេមកគេដេញ វាគ្មាន អ្នកណាបម្រើអ្នកណាពេលវេលាអី វាប្របូកប្របល់អីពេលហ្នឹង ។

ជា: ភ្លាម ៗ ហ្នឹងមានគេផ្សឹកលោកទេ?

គង់ គីម: អត់ផ្សឹកទេ គឺដេញមក មិនដឹងយកទៅនៅវត្តណា បើគេអត់កាន់វាគ្មានវត្តគ្មានអីមកតាមដំណើរហ្នឹង ។ អាណឹងជំនាន់ហ្នឹងបើតាមខ្ញុំស្មាន ប្រហែលជាបកខ្លួនឯង ខ្ញុំបានទៅជំហានមុខហ្នឹង ។ បានទៅដេញមក ដេញឲ្យមកក្រោយចឹងមក ។

ខស្មាន: ចុះពេលដែលប្រជាជនចេញស្ងាត់អស់ហើយ លោកពូគេឲ្យធ្វើអីការកិច្ចធ្វើអីទៅ?

គង់ គីមៈ ដល់គេ ប្រជាជនចេញអស់បានប្រធានធំគេប្រកាសតាមតំបន់ភ្នំពេញ ពីត្រឹមណាភូមិភាគឧត្តរពីត្រឹមណាភូមិភាគបូព៌ា ត្រឹមណាភូមិភាគនិរតី យើងអត់ចូលទៅដីគេបានទេ ។ ចឹងគេចែកព្រំហើយ បានពុះជាវរសេនាធំ វរសេនាតូចចែកគ្នាការពារ ហើយវរសេនាតូចខ្ញុំហ្នឹងនៅត្រឹម ជ្រោយចង្វារទៅទល់ត្រឹមឃោសនាការខាងត្បូងវត្តភ្នំហ្នឹង ប៉ុស្តិ៍យាមខ្ញុំមានក្បាលនៅជ្រោយចង្វារ និងវត្តភ្នំ ហើយនឹងរដ្ឋាករទឹក ។

ខស្នានៈ គេឲ្យយាមស្អីបើ?

គង់ គីមៈ យាមនោះមួយយប់ៗចេះតែអន្ទុយទៅណា អន្ទុយយាមទៅណា ហើយមេណើងដើររវីបើកឡាន ក្រវីជាប់ ។

ខស្នានៈ នៅភ្នំពេញណឹងចែកជាភូមិភាគមាន៣ ចឹងលោកពូ បាននិយាយម៉ិញហ្នឹង?

គង់ គីមៈ បាទ! ចាំមើលមានឧត្តរហ្នឹង និរតី បូព៌ាចឹង ។

ខស្នានៈ ហឺ ខាងឧត្តរហ្នឹងនៅតែ៣១០ដដែល?

គង់ គីមៈ បាទ! កងពលគឺលេខដែលកងពលឲ្យទ័ពណឹង គឺឈ្មោះកងពល៣១០ ។

ខស្នានៈ ចុះនិរតីលេខប៉ុន្មាន?

គង់ គីមៈ និរតីអត់ដឹងទេ ។

ខស្នានៈ បូព៌ាអី?

គង់ គីមៈ បូព៌ាក៏អត់ដឹងលេខដែរ ប៉ុនដឹងតែភូមិភាគគេ គេមានទ័ពរបស់គេចឹង ប៉ុនលេខកងពលគេអត់ដឹងទេ ប៉ុនលេខកងពលខ្ញុំ ខ្ញុំដឹង កងពលទ័ពសម្រាប់ភូមិភាគឧត្តរហ្នឹងគឺ៣១០ ។

ជាៈ ពូមានស្គាល់ប្រធានភូមិភាគហ្នឹងទេ?

គង់ គីមៈ ភូមិភាគអត់ ពីមុនខ្ញុំស្គាល់ប៉ុនឥឡូវភ្លេច ភូមិភាគធំនោះគឺ គាត់នៅតែក្រោយហ្នឹងទេ នៅតំបន់គេនោះណា ព្រោះខ្ញុំនោះជាសាច់ទ័ព ។ ប្រធានភូមិភាគជាប្រធាននិយាយរួមគេក្តាប់រដ្ឋបាល ក្តាប់ប្រជាជនក្រោយទេ ។

ជាៈ គាត់នៅ គាត់ឈ្មោះអីគេកាលហ្នឹង?

គង់ គីមៈ ភ្លេចហើយប្អូន ខ្ញុំភ្លេចយូរហើយ ។

ខស្នានៈ លោកពូថា ដើមឆ្នាំ៧៦ លោកពូបានមកយាមគុកហ្នឹង?

គង់ គីមៈ បាទ! ដល់ពេលគេឲ្យខ្ញុំយាមចុះយាមឡើងដល់ពេលអាសម្រាញ់ចាស់ មេកងពល ខ្ញុំហ្នឹងគេចាប់ដែរតើ ខ្ញុំនៅយាមហ្នឹងដែរតើ ។

ខស្មានៈ ឈ្មោះអី?

គង់ គីមៈ តាអឿននោះ ។

ខស្មានៈ តាអឿន?

គង់ គីមៈ បាទ! គេចាប់យកទៅខ្ញុំនៅយាមហ្នឹងដែរ មេខ្ញុំផ្ទាល់ហ្នឹង មេកងពលហ្នឹងមួយ មេវរសេនាធំឈ្មោះ សុងនោះ ក៏គេចាប់ដែរ ហើយខ្ញុំបានយាមគុកហ្នឹងដែរ ។ ដល់ចឹងក្រោយមកបានគេដកខ្ញុំ ។ ដកខ្ញុំហើយចាប់ផ្ដើមចាប់ហើយ ។ ចាប់ពីត្រឹមអនុសេនាធំគេចាប់បន្តៗហើយ គេចាប់សាច់ទ័ពហ្នឹងណា ។ ចាប់ៗគេបញ្ជូនខ្ញុំមកព្រលានហ្នឹងបណ្ដោយ ។ មុនដំបូងគ្រាន់ចាប់ត្រឹម មេៗហើយ ដល់ខ្ញុំមកព្រលានហ្នឹងចាប់ផ្ដើមភ័យហើយ ប៉ុនអ្នកដែលត្រួតពិនិត្យធំលើគេ គេចាប់មេខាងភូមិភាគឧត្ដរ មេអនុសេនាធំ មេវរៈហ្នឹងគេចាប់មួយ គេយកពីនិរតីមកធ្វើមេ ។

ខស្មានៈ ធ្វើមេភូមិភាគហ្នឹង?

គង់ គីមៈ បាទ! ធ្វើមេនិរតីគេយកមកដាក់តាមហ្នឹង យកមេៗមកគ្រប់គ្រងយើងហើយ ។ ខាងតាកែវខាងអីហ្នឹងណា ខាងខ្ញុំនោះគេចាប់កងពល គេយកពីនិរតីធ្វើមេកងពលជំនួស ។

ខស្មានៈ ចាប់ មេកងពល?

គង់ គីមៈ គេជំនួសបំពេញនោះ ដកខ្ញុំមកណោះបាត់ហើយ ។

ខស្មានៈ អូ! អត់ដឹងទេ?

គង់ គីមៈ បាទ! អត់ដឹងទេ ហើយដល់ចឹងគេសម្លាប់ គេចាប់អនុសេនាធំគេយកពីហ្នឹងមករហូតដល់ខ្ញុំមកនៅព្រលានហ្នឹងបានគេយកមកហ្នឹងបាន តាគីម, ៥០២, តាវ៉ៃ, តាធួកនៅព្រលានថ្មីហ្នឹង នៅជាមួយពួកចិនហ្នឹង ។

ខស្មានៈ ចុះលោកពូកន្លែងគុកហ្នឹង ក្រែងជាគុករបស់កងពល?

គង់ គីមៈ បាទ! គុករបស់កងពល ។

ខស្មានៈ ចុះអ្នកកាន់ខុសត្រូវប្រធានគុកហ្នឹងឈ្មោះអីទៅ?

គង់ គីមៈ មេដែលគ្រប់គ្រងគុកផ្ទាល់ហ្នឹង?

ឧស្មានៈ បាទ!

គង់ គីមៈ ពីដើម គុកហ្នឹងឲ្យកងពល គ្រប់គ្រងដោយកងពលហ្នឹងទៅ ដល់ក្រោយមកវា គ្រលប់វាមិនដឹងណាទទួលខុសត្រូវស្រាប់តែឃើញចាប់អាមេកងពលហ្នឹង ចាប់មេកងពលរួចបានមេដែលយាមគុកនៅដដែលទេ អត់ផ្លាស់ប្តូរទេ ប៉ុន្មានអ្នកត្រួតពីលើគេចាប់ហ្នឹងហ្នឹងថាអ្នកនោះក្បត់ៗ ក្បត់អ្នកនោះ នាំអ្នកចាប់មកហ្នឹង ម៉េចអ្នកហ្នឹងឆ្លើយទៅថាមេកងពលហ្នឹងថាគេ មកអប់រំខ្ញុំអ្នកយាមថាមេហ្នឹងឯងជាខ្សែរយៈដែរបានគេចាប់នោះចឹងការឆ្លើយដាក់ ដល់ចាប់ មេហ្នឹងទៅ ទៅចាប់វរសេនាធំបន្តបន្ទាប់ ឃើញបន្តវាប្រហូលប្រហល់ត្រឡប់ចុងឆ្នាំ៧៦ ចាប់ផ្តើមចាប់មេៗហើយ ។ ដល់ចាប់មេៗចឹងបាគេដកខ្ញុំពីក្នុងគុកហ្នឹង ដកមកបញ្ជូនមកព្រលានមក ។ បញ្ជូនហ្នឹងអត់មានមេ អត់មានកើយទេ គេប្រមូលឲ្យតែកូនចៅក្នុងកងពល៣១០អត់មានមេទេ អស់មេហើយគេទម្លាក់ពីយកមករៀបចំព្រលានហ្នឹង គេយកមេអនុសេនតូចពីនិរតីហ្នឹងយកមកក្តាប់ឃើង ឃើងកូនទាំងអស់ ។ កាលនៅក្នុងព្រលានកូន ។

ជាៈ កាលហ្នឹងខាងណាទៅចាប់មេៗបង?

គង់ គីមៈ ចាប់ពីភ្នំពេញ ។

ជាៈ ខាងណាទៅចាប់?

គង់ គីមៈ ខាង គេហៅថាកង៥០២ ។

ជាៈ ភូមភាគខាងណា?

គង់ គីមៈ ៥០២ បើនិយាយរួមគេហៅថា វាចំណុះឲ្យសេនាធិការមជ្ឈិមគេ ។ មិនមែនតាមភូមិភាគទេ នេះគេជំនួសឲ្យកងមជ្ឈិមគេ ។

ជាៈ ចឹង កាលហ្នឹងពូស្គាល់ទេ កាលអគ្គសេនាធិការមជ្ឈិមហ្នឹងឈ្មោះអីគេមេ?

គង់ គីមៈ អត់ៗស្គាល់ ។

ជាៈ ពូមានស្គាល់ឈ្មោះអ្នកទៅចាប់ហ្នឹងទេ?

គង់ គីមៈ អត់ៗមានស្គាល់ទេ ។

ដារ៉ាៈ ចុះលោកពូថា កន្លែងគុកហ្នឹងជាគុករបស់កងពល៣១០ ដល់ពេលទៅចាប់ប្រធានកងពល៣១០ ពូគិតថាពីខាងណាទៅចាប់វិញ?

គង់ គីមៈ ស្រាប់តែឃើញគេទៅហើយ ដល់ទៅគេថាអប់រំយើងថាកងពលហ្នឹងគឺក្បត់ៗ ពីមុនដំបូងពេលដែលខ្ញុំយាមគុកហ្នឹងគេចាប់ហ្នឹងខ្ញុំអត់ស្គាល់ទេ ក្នុងនោះមានចាប់យកពីក្រោយទៅ យកពីតំបន់ យកពីក្រោយៗអត់ចាប់ពីផ្ទៃកងទ័ពទេ ប៉ុនដឹងយកពីណាមកទេ បញ្ចូលៗទៅ ខ្លះនៅកន្ទុះខែ ខ្លះនៅ២អាទិត្យគេប្រមូលមក គេបញ្ជូនទៅទៀតប៉ុនទៅណាខ្ញុំមិនដឹងទេៗ គេចងមុខបញ្ជូន ទៅទៀតទៅៗ រួចការធ្វើបាបហ្នឹងវៃសួរចម្លើយអី ខ្ញុំបានចូលរួមឈរមើលគេវៃហ្នឹងៗ វៃហ្នឹងគ្តគោហ្នឹង ពីដើមហ្នឹងខ្ញុំមិនស្គាល់គ្តគោណា គ្តគោហ្នឹងមូលៗ ៗ ឯវនឹងគ្តគោហើយ គេធ្វើទារុណដូចខ្ញុំថាកាត់ស្លាបមាន់ហ្នឹងបញ្ចូលក្នុងកហ្មណឹង ណឹងរុញប៉ាច់មួលប្រកាច់មនុស្សបណ្តោយ ៗ ហ្នឹងខ្ញុំឃើញជាក់ស្តែងចឹងៗ ដល់ចុងក្រោយមកគេចាប់ ដល់យូរៗធ្លាក់ពីគេ មកចាប់មេកងពល ចុងឆ្នាំ៧៦នេះ វាត្រូវច្របូកច្របល់ចឹង ដល់នេះគេថាមេហ្នឹងវាក្បត់ៗ

ដារ៉ាៈ ពេលប្រជុំមកប្រាប់លោកពូហ្នឹង ខាងណាមកប្រជុំប្រាប់ថាមេរបស់ពូក្បត់?

គង់ គីមៈ ខាងនេះ ប៉ុនអត់ស្គាល់ឈ្មោះ គេចូលមក គេចូលមកប្រាប់មកប្រជុំ ប្រាប់ថាមេកងពលដែលគេចាប់មក មេកងពលអ្នកឯងក្បត់ ចាំគេប្តូរមេកងពលឲ្យៗ

ដារ៉ាៈ ប៉ុន្តែខាងណាដែលមកប្រជុំប្រាប់?

គង់ គីមៈ ខាងមជ្ឈិមគេហៅថាខាងសេនាធិការមជ្ឈិមៗ

ដារ៉ាៈ ពូ មានស្គាល់ឈ្មោះអ្នកដែលមកប្រាប់?

គង់ គីមៈ អត់មានស្គាល់ទេៗ

ឧស្មានៈ ចុះដំបូងពេលចាប់មេហ្នឹង លោកពូឃើញអ្នកជាប់គុកនៅកន្លែងហ្នឹងជាអ្នកណាទៅ មុនដែលចាប់មេ កាលពូដែលជាអ្នកយាម?

គង់ គីមៈ ថាខ្ញុំវាអត់មានខាងសួរចម្លើយក៏គ្មាន ខាងទៅយាមកុំឲ្យវារួច ឧទាហរណ៍គេ មកហើយគេអ្នកនាំ គេទៅដាក់អី យើងយាមដើម្បីកុំឲ្យតែរួចទេ ឧទាហរណ៍ក្នុងពេលយាម បទបញ្ជាបើរួចនឹងវេនខ្ញុំយាម វាមានម៉ោងវា ម៉ោងខ្ញុំ២ម៉ោង បើរួចក្នុងម៉ោងខ្ញុំ ខ្ញុំជាប់គុក រួចនោះគេដាក់ខ្ញុំទៅកន្លែងហ្នឹងហើយ ចឹងអត់មានឲ្យរួចទេៗ បើធ្វើម៉េចបើថា ធ្វើម៉េចបាញ់ឲ្យតែបានទៅៗ គេកំណត់ចឹងធ្វើម៉េចបាញ់ឲ្យតែបានទៅ គេកំណត់ចឹងធ្វើម៉េចឲ្យបានស្លាប់ទៅ ខ្ញុំរួចខ្លួនហើយៗ រឿងដែលសួរចម្លើយ រឿងទៅសួរណែនាំអីអត់

មានទេ បានការពារកុំឲ្យរត់ ។ គេបញ្ជូលទៅ គេប្រាប់ថានែ៎ចូលហើយការពារចឹងទៅ ហើយបែងក្រឡាយាមនោះមួយម៉ោងប៉ុន្មាននាក់ ហើយទទួលខុសត្រូវបានប៉ុណ្ណឹង ។ ត្រង់កិច្ចការគេសួរចម្លើយដឹងថា ។

ខស្វាន: លោកពូគិតថា អ្នកណឹងជាប្រជាជនធម្មតា?

## កាស្សែតទី២

គង់ គីម: តំបន់អីហ្នឹង អត់តូចតាចទេ ។

ខស្វាន: មេស្រុក មេតំបន់?

គង់ គីម: បាទ! រឿងកន្លែងនោះអត់មានយកប្រជាជនទៅដល់ហ្នឹងទេ សុទ្ធតែដឹកឡានយកទៅ ។

ខស្វាន: មេស្រុកហ្នឹង មេស្រុកមកពីខាងណា ដែលចាប់យកទៅកន្លែងហ្នឹង?

គង់ គីម: តំបន់ខាងគុកហ្នឹង ដូចខ្ញុំនិយាយចឹងមានតែតំបន់កំពង់ចាម-កំពង់ធំហ្នឹង យកមកក្រោយហ្នឹង យកពីហ្នឹង ។ ដល់ចាប់ហ្នឹងទៅ ដល់ក្រោយមកបានគេថា ព្រោះខ្ញុំវាចំណុះឲ្យកងពលហ្នឹង គេអ្នកចាប់គេមកប្រជុំថា មេអ្នកឯងក្បត់ដែរ ។ ចឹងគេចាប់មកហ្នឹងតើចាំគេដូរឲ្យអ្នកឯងអត់ក្បត់ទេ ប៉ុនមេអ្នកឯងក្បត់ហ្នឹងហើយ ។

ជា: ពូកាលហ្នឹងមេក្រុមយាមរបស់ពូឈ្មោះអីគេ?

គង់ គីម: មេយាមជាមួយខ្ញុំ ពិសេសមួយអនុសេនាតូចហ្នឹងយាមទាំងអស់ហ្នឹងហើយ ។ ខ្ញុំរងគេដែរ ប៉ុនឈ្មោះ ប៉ុន នោះប្រធានខ្ញុំ ។

ជា: ចុះពូរងគេ?

គង់ គីម: បាទ! រងបន្ទាប់គេហ្នឹង ។

ជា: ចុះពីលើបន្ទាប់ ប៉ុន ណឹងទៀតមានឈ្មោះអី មានឈ្មោះអីគេ?

គង់ គីម: បើយាមគុកគេយកត្រឹមមួយអនុសេនាតូចទេ អ្នកយាមផ្ទាល់ ដល់វរសេនាធំមួយវរសេនាតូចគេនៅក្រៅទេ ។ ប៉ុនគេដកយើងទៅមួយអនុសេនាតូចសម្រាប់មកយាមគុក ព្រោះគុកហ្នឹងវា របងជុំវិញ ហើយក្នុងហ្នឹងមានគុកតូចៗ ។

ជារ៉ា: ចុះពេលដែលមានប្រជុំថាមេរបស់បងក្បត់ចឹង អ្នកដែលនៅក្នុងកងជាមួយកងពល ៣១០ ឬក៏អ្នកផ្សេង?

គង់ គីមៈ អ្នកផ្សេងទេ គេចូលមកហ្នឹង គេយកមកហៅយើងអ្នកការពារទាំងអស់ប្រជុំគេប្រាប់ថា កងពលមេកងពលអ្នកឯងហ្នឹងដែលគេចាប់នឹងមកពីក្បត់ៗ ចឹងអស់លោកមិនមែនក្បត់ទេ ក្បត់តែមេកងពលទេៗ គេប្រាប់ទៅកុំឲ្យយើងមានសិតអារម្មណ៍ភ័យភិត ព្រោះយើងសុទ្ធអាវុធៗ

ដារ៉ាៈ ពេលបងចូលប្រជុំដែរណឹង បងគិតថាមនុស្សមកពីខាងណា ដែលមកបើកការប្រជុំប្រាប់?

គង់ គីមៈ មនុស្សហ្នឹងបានមិនអាចស្គាល់ឈ្មោះ ប៉ុនមនុស្សគ្រាន់ចំណាំមុខ ព្រោះមនុស្សហ្នឹងធ្លាប់យកអ្នកទោសបន្តហ្នឹងៗ យកឡានមកយកពីគុកខ្ញុំហ្នឹង ព្រោះគុកហ្នឹងវាតូចដល់យូរៗទៅវាច្រើន ច្រើនគេយកមួយឡានទៅទៀតទៅៗ ច្រើនគេយកទៅទៀតទៅៗ មនុស្សដែលដឹកជញ្ជូននឹងហើយៗ

ដារ៉ាៈ មកប្រជុំប្រាប់?

គង់ គីមៈ បាទ! ដែលមកប្រាប់ថា កងពល មេកងពលអ្នកឯងក្បត់បានគេចាប់នោះៗ ប៉ុនអស់លោកមិនមែនអ្នកក្បត់ទេៗ កាលណោះហៅថាមិត្តៗៗ

ជាៈ ពូ កាលហ្នឹងនៅក្នុងគុកហ្នឹងធ្វើអីខ្លះ?

គង់ គីមៈ អត់មានការងារធ្វើទេ គឺយាមចំហ្នង ដេក ខុសពីយាមគឺដេក ងើបពីដេកគឺយាម គឺដូរគ្នារហូត២៤ម៉ោងគឺវិលជាប់ៗ ថាគ្នា៣០នាក់ គឺយាមម្តង ៥នាក់គឺ ៥នាក់ដើរវិមើល ព្រោះក្នុងគុកគេមានប្រឡោះប៉ុនៗណោះទុកឲ្យមើលៗ គ្រាន់តែឈ្ងោកមើលគឺអត់មានធ្វើអីក្រៅពីយាមទេៗ

ជាៈ ហឺ ពូអ្នកទោសណឹង យើងមានបានផ្តល់ចំណីអាហារអីឲ្យគេទេ?

គង់ គីមៈ ផ្តល់ ប៉ុនមានក្រុមគេសម្រាប់ឲ្យបាយ គេឲ្យយើងអ្នកយាមអ្នកមានអាវុធអត់មាន ឲ្យទៅជិតអ្នកគុកអី ឲ្យទៅបម្រើអីទេ គេមានកងបម្រើរបស់គេៗ គេដាំបាយឲ្យៗ បាយគេរុញឲ្យ មានអាគុកគេដាក់រួមហ្នឹង ក្នុង៣ៗនាក់ហ្នឹងគេរុញសម្លមួយចានបាយមួយចានគេរុញបញ្ចូលចឹងទៅៗ ត្រង់ថាហូបចុកម៉េចក្នុងហ្នឹងវាៗ

ជាៈ ចុះថ្នាំសង្កូវអីម៉េច នៅពេលអ្នកទោសឈឺ?

គង់ គីមៈ អូ! អត់ទេ។ អត់មានទេ គ្រាន់តែបាយមិនគ្រប់គ្រាន់ហ្នឹងគ្រាន់ថា ហូបឲ្យមានៗទៅ បើរឿងដល់ថ្នាំសង្កូវរឿងស្អីៗអត់ទេ។

ជាៈ ចុះដែលមានអ្នកទោសឈឺទេ?

គង់ គីមៈ មាន មានងាប់ដេកហ្នឹងមានតើ។

ជាៈ ឈឺដេកស្លាប់នៅហ្នឹង?

គង់ គីមៈ បាទ! មានស្លាប់ ស្លាប់ទៅគេយកចេញទៅ។

ជាៈ អត់មានការព្យាបាលអីពីប្រធានគុក?

គង់ គីមៈ អត់មានទេ ថាស្តីបន្ទោសតែវត់ទេ បើវត់ទើបមានទោសបើងាប់ក្នុងហ្នឹងបាញ់បាន អីក្នុងហ្នឹងអី អត់មានស្តីបន្ទោសទេ ស្តីបន្ទោសតែតែវត់បាត់គឺរឿងអ្នកយាម។

ខស្នានៈ អូ វត់?

គង់ គីមៈ បាទ! បើវត់រួចគឺយើងមានរឿង បើថាងាប់អីអត់មានទេ។

ជាៈ ហើ អ្នកនៅក្នុងគុកហ្នឹងប្រហែលជាប៉ុន្មាននាក់ ពូមានដឹងទេ?

គង់ គីមៈ គុកហ្នឹងវែអស់ច្រើនប្រហែលជា៥០នាក់ បើដាក់ឲ្យគ្រប់ទៅ ព្រោះមានអ្នកដែលមក ពីឆ្ងាយៗបើសាច់ឈាមអ្នកធំៗនឹងគេយកដាក់ជាន់លើ ជាន់លើដាក់ឲ្យដេកមានគ្រែវា មានគ្រែ មានទឹកតែធំៗមានដាំទឹកតែបម្រើចិន។ ថ្នាក់ក្រោមដឹងបន្ទោសរបៀប ម៉េចទេ ឲ្យយើងហ្នឹងមានអ្នកបម្រើ ឲ្យមានថាស មានទឹកតែ មានម្ហូបត្រឹមត្រូវ មាន តាមថ្នាក់ហ្នឹង ដាក់ខ្នោះដែរ ដាក់ច្រវ៉ាក់ ប៉ុនដេក គ្រែចងមុង មានបាយម្ហូបល្អៗ ហ្នឹងទឹកតែដាំបម្រើចិនដែរ។ មានមួយថ្នាក់នោះមានចិន។

ខស្នានៈ ហ៊ានះហ្នឹង ថ្នាក់ហ្នឹង ថ្នាក់អីគេ?

គង់ គីមៈ មិនដឹងថ្នាក់អី អត់ដឹង ប៉ុនគ្រាន់ថា មិនដឹងគេយកពីណាមក ប៉ុនដឹង ព្រោះខ្ញុំនៅយាម គ្រាន់មើលទេ គ្រាន់តែដើរមើលទេ។

ជាៈ ចុះនៅក្នុងគុកហ្នឹងមានអ្នកទោសស្រីទេ?

គង់ គីមៈ មាន ស្រីក៏មានប្រុសក៏មាន មានដូចគ្នា។

ជាៈ ស្រីមានច្រើនទេ?

គង់ គីមៈ ស្រីតិចដែរទេ។

ជាៈ ពូ ដែលយាមប្រទះដែរ?

គង់ គីមៈ បើយាមគុក ត្រូវស្គាល់មនុស្សក្នុងគុកទាំងអស់ បញ្ចូលប៉ុន្មានបញ្ចេញប៉ុន្មាន ព្រោះខ្លាចបាត់ ដែលបាត់អត់ដឹង ។

ដារ៉ាៈ មានការធ្វើបញ្ជីអីដែរ បញ្ជីអ្នកទោសចូល អ្នកទោសចេញ?

គង់ គីមៈ វា ខ្ញុំគ្រាន់តែយាមអាប្រធានគ្រប់គ្រងវាដោយឡែក យើងគ្រាន់តែយាម ។

ដារ៉ាៈ ចុះពូដឹងថា ត្រូវតែមានបញ្ជីអីដែរ?

គង់ គីមៈ បាទ! មានគេធ្វើបញ្ចេញបញ្ចូល អាណាចូលថ្ងៃណា គេធ្វើដាក់ចឹង ចូលថ្ងៃណាចេញថ្ងៃណាមេគេកាលេ(Calculator) ចេញចូលមានផ្សេង ។ ខ្ញុំហ្នឹងគ្រាន់តែប្រធានខាងការងារគ្រប់គ្រងយាម ថាយាមទេ អត់គ្រប់គ្រងបញ្ជីទេ ។

ខស្មានៈ ពូ គ្រប់គ្រងដែរខាងយាមហ្នឹង?

គង់ គីមៈ បាទ! គ្រាន់តែយាមគ្រប់គ្រងយាមទេ ។ គ្រប់គ្រងក្រុមធ្វើម៉េចកុំឲ្យមនុស្សរត់ត្រង់ថាពេលគេយកចេញបានដោយដំណើរហ្នឹងជារឿងរបស់គេទេ ផ្លាស់ចេញទៅ ។

ជាៈ ពូ ស្គាល់ប្រធានគុកហ្នឹងទេ?

គង់ គីមៈ អត់ ខ្ញុំអត់ស្គាល់ ។

ជាៈ ចុះបន្ទាប់បន្តបន្ទាប់មកទៀត?

គង់ គីមៈ អត់ស្គាល់ទេ ស្គាល់ត្រឹមតែប្រធានពួកខ្ញុំហ្នឹង ហើយខ្ញុំ និងប៉ុនហ្នឹង២នាក់ គឺគេហៅថាកងកម្លាំងប្រដាប់អាវុធយាមកុំឲ្យរត់ ។ រឿងគេមកត្រួតពិនិត្យគុកអត់ទេ ។

ជា ពូ មានដែលប្រជុំរួមគ្នាជាមួយអ្នកនៅក្នុងគុកហ្នឹងទេ?

គង់ គីមៈ អត់មានទេ ។

ខស្មានៈ នៅក្នុងគុកហ្នឹងមានប៉ុន្មានកង ក្រៅពីអ្នកយាមមានកងផ្សេងទៀត?

គង់ គីមៈ មាន ដូចគេអ្នកដែលកាន់បញ្ជីគុក ប៉ុនគេមាននៅហ្នឹងណា គេមកពេលបញ្ជូនចូលមកគេមក ។ គេយកចេញ ហើយគេមកធ្វើទារុណកម្មមួយពេល ៗដូចថា គេមកសួរចម្លើយសួរអី គេបញ្ចេញដល់ពេលមកគេមកទាក់ទងនឹងយើងចឹង ។ ឧទាហរណ៍ សុំឈ្មោះនេះចេញឲ្យបញ្ចេញបន្ទប់ទីប៉ុន្មាន ៗ ចឹងទៅ គេយកសោរទៅចាក់ យើងដើរតាម

គ្រាន់តែដើរតាមណឹងការពារក្រែងវារត់ ពេលចាក់សោរទៅដល់មនុស្សដែលនៅក្នុងបន្ទប់អត់មានចងមុខទេ។ ពេលរៀបបញ្ចេញគឺចងពីមុខ ពីក្នុងហ្នឹងស្រេច។

ខស្នាន: បញ្ចេញយកទៅ?

គង់ គីម: បាទ! បញ្ចេញចងមុខស្រេចហើយ ចងមុខបានបញ្ចេញ។

ខស្នាន: ចុះ កន្លែងសួរចម្លើយ?

គង់ គីម: សួរចម្លើយនៅកណ្ដាលហ្នឹង គេធ្វើតូបមួយកណ្ដាលចឹង យកមកធ្វើអត់មានធ្វើកន្លែងក្នុងបន្ទប់ហ្នឹងទេ ធ្វើដោយស្លែក វាដាច់ដែរ។ ដូចថាមួយផ្ទាគុកមានកណ្ដាលមួយកូនខ្ទមនោះ គេធ្វើដោយស្លែក។

ខស្នាន: អ្នកទោសម្នាក់ហ្នឹង ត្រូវបានគេសួរចម្លើយប៉ុន្មានដងទៅ?

គង់ គីម: វាអត់ទៀង ជួនកាលបានសួរមួយដងចឹងទៅ ស្រាប់តែយកទៅវិញ ស្អែកចឹងទៅយកចេញ។ ឡានមកយកទៅ។

ខស្នាន: លោកពូមានដែលឃើញគេសួរចម្លើយលួចមើលឃើញគេដែរ?

គង់ គីម: អត់ដែលបានទៅស្ដាប់ឲ្យព្វទេ ប៉ុនបើឃើញ គ្រាន់អើតឲ្យឃើញ យើងអ្នកការពារគេឈរ ប៉ុនទារុណកម្មខ្ញុំឃើញថាវ៉ៃ ឃើញ ហើយហ្នឹងទាក់ខ្សែរ៉តហ្នឹងជើងឡើងលើក្បាល ចុះក្រោមឃើញ។ ជយនកាលដែលវ៉ៃទៅៗវាអត់ដឹង មិនដឹងគេសួរពីរឿងអីថាអត់ឆ្លើយចឹង ជួនកាលក្នុងមួយព្រឹកហ្នឹង គេសួរចម្លើយប្រហែលកន្លះម៉ោងហ្នឹងវាអត់ឆ្លើយគេដាក់ព្យួរចោលហ្នឹង។ ជើងទៅលើវិលនៅហ្នឹង។ ដល់ពេលបាយបានគេទៅដោះមក មានចឹង គេទៅព្យួរជើងចោលចឹង។

ខស្នាន: ម៉ោងប៉ុន្មានរយៈពេលព្យួរម៉ោងប៉ុន្មាន?

គង់ គីម: ដល់ពេលគេសួរពីទឹកចឹង គេសួរពីម៉ោង៧ ដល់ម៉ោង៨ណឹង សួរអត់បានការទៅ គេព្យួរចោលតាំងពីម៉ោង៨ដល់ម៉ោង១០ចឹង។ ក្បាលមកក្រោមជើងឡើងលើចឹងហើយនិងវ៉ៃ និងបង្វិល។

ខស្នាន: បង្វិលម៉េចបង?

គង់ គីម: បង្វិលចុះជើងឡើងលើ បង្វិលមនុស្សឲ្យវិល ឲ្យវាគួញ ហើយឲ្យវាលាវិញនោះ។ មនុស្សនោះវង្វេងវង្វាន់អស់ហើយ លែងដឹងអីហើយ។

ជា៖ ពូ ដែលឃើញអ្នកធំៗអី មកពីក្រៅមកចូលមើលគុកហ្នឹងដែរ?

គង់ គីម៖ អត់ អត់ដែលឃើញអ្នកធំផ្សេង ឃើញតែអ្នកដដែលៗហ្នឹង ហើយអ្នកដែលធ្លាប់មកនាំយកហ្នឹងឃើញ។ យាមហ្នឹងគ្រាន់តែខ្ញុំ បានតែយាមទេ ប៉ុនអ្នកនាំ នាំបញ្ចូលដល់បញ្ចេញ ពួកហ្នឹងក៏យកចេញដែរ។

ខស្មានៈ ចឹង អ្នកយកបញ្ចូលហ្នឹង ហើយអ្នកយកចេញហ្នឹងមនុស្សតែមួយ?

គង់ គីម៖ បាទ! មនុស្សតែមួយ ក្រុមគេហ្នឹង។

ដារ៉ា៖ ពូ ដែលឃើញថា ចង់អ្នកទោសសំយុងអីហ្នឹង ពូច្រើនតែប្រើពាក្យគេៗ ពុសំដៅទៅខាងក្រុមណា កងការពារ ឬក្រុមណា?

គង់ គីម៖ អត់មានក្រុមការពារទេ ក្រុមដែលគេគ្រប់គ្រងគុកហ្នឹង ក្រុមកាន់បញ្ជី និងក្រុមដែលគេសម្រាប់យកចេញណា។ ពេលគេយកចូលក្រោយមកគេមកសួរចម្លើយ។ ឧទាហរណ៍ថាមកហ្នឹង គេដាក់ប្រគល់ឲ្យអ្នកគ្រប់គ្រងបញ្ជី ដល់ពេលពួកនោះគេមក ថាចង់យកឈ្មោះណាមកសួរចម្លើយគេប្រាប់អ្នកគ្រប់គ្រងរួច គេប្រាប់អ្នកការពារ ហ្នឹងឲ្យទៅយកអ្នកដែលជាប់គុកមក។ ជាប់ក្នុងបន្ទប់ គេពិសោធន៍លើគេ យើងគ្រាន់តែបើគេទៅ គេហៅយើងទៅស្អក។ ក្រែងអ្នកហ្នឹង ចេញមកហើយវារត់ បើកាលណារត់រួចនៅតែលើយើងចឹង។

ខស្មានៈ ពួកដែលសួរចម្លើយ ពួកដែលចាប់ ពួកដែលបញ្ជូនមនុស្សចេញទៅណឹង តើអ្នកហ្នឹងនៅ ក្នុងកងពល៣១០ណឹងដែរ ឬក៏អ្នកផ្សេង?

គង់ គីម៖ មិនមែនទេ គេនិយាយហៅថាសេនាធិកាមជ្ឈិមនោះ ពួកខាងមជ្ឈិមនោះ។

ខស្មានៈ ពួកខាងមជ្ឈិម?

គង់ គីម៖ បាទ! ពួកមជ្ឈិមទេ។

ជា៖ ម៉េចបានជាពូដឹងថា ពួកមជ្ឈិម?

គង់ គីម៖ ព្រោះគេប្រាប់ ព្រោះគុកនេះឲ្យសម្រាប់កងពល ប៉ុនកាលដែលបញ្ចេញបញ្ចូលនោះ គឺខាងគេពីលើមកទេ។

ខស្មានៈ ពីលើនោះ ពូសំដៅ?

គង់ គីមៈ ហើយដែលគងពលវរសេនាធំអីហ្នឹង មិនបានចូលគុក មិនបានអីទៅមើល ទៅត្រួតពួកខ្ញុំ ពួកខ្ញុំនេះគងការពារគឺការពារឲ្យគេទេណា អត់មានមេវរសេនាតូច មេវរសេនាធំនេះទៅ បញ្ជាខ្ញុំឲ្យចូលណែនាំអីអត់មានទេ ខ្ញុំចូលទៅគឺក្រោមបញ្ជាគេអ្នកនាំមនុស្សហ្នឹងបណ្តោយ ។

ខស្មានៈ ពូ ដែលព្យួរចើងឡើងលើបង្កិលអីហ្នឹង ដែលលោកពូនិយាយម៉ិញ លោកពូបានឃើញជាញឹកញាប់ដែរ ឬយ៉ាំងម៉េច?

គង់ គីមៈ ឲ្យតែសួរចម្លើយគឺកម្មវិធីគេចឹង ។

ខស្មានៈ ពូ បានឃើញដូចរាល់ថ្ងៃ ឬក៏ប៉ុន្មានថ្ងៃបានឃើញសកម្មភាពចឹងម្តង?

គង់ គីមៈ ពេលវាហៅសួរចម្លើយ ជួនកាលមួយអាទិត្យម្តង ប៉ុនមិនមែនមនុស្សដដែលទេ ផ្សេងៗគ្នា ។ មុនដំបូងគេចងមុខរួច បានគេដោះពីបន្ទប់គុកមក យកមកដាក់តុមូលចឹង ហៅមានកៅអីឲ្យអង្គុយ គេពិភាក្សាគ្នាដូចយើងប្រជុំចឹង ជួនកាលគេឲ្យបារីគ្នាដូចអ្នកទោសចឹង ដល់គេសួរឬគេនិយាយរអីហ្នឹង គេមានសៀវភៅមានប៊ិចចឹង ដល់ក្រោយពីរអ៊ីៗបានន័យថាគេធ្វើតាមសម្រួលម៉េច មិនដឹងអីមិនដឹង ។ ដល់ក្រោយមកបានឃើញសកម្មភាពទៅជាចាប់ចង ទៅធ្វើសកម្មភាពចាប់ចង ដើងចាប់អីហ្នឹង ។ ប៉ុនមុនដំបូងមិនយកមកភ្ជាមមិនកាច់ក្បាលភ្លាមទេ យកមកដាក់កៅអីឲ្យអង្គុយ ប៉ុនមុខនៅតែចងដដែល ។ ប៉ុនឲ្យបារីឲ្យជក់អីហ្នឹង គេពិភាក្សាគ្នាណឹង ប៉ុនខ្លឹមសារយើងមិនអាចដឹងទេ ។

ខស្មានៈ ចុះគ្រប់អ្នកទោសត្រូវបានធ្វើទារុណកម្ម ឬអ្នកទោសខ្លះបានធូរជាង?

គង់ គីមៈ ខ្លះអត់ដែរ ខ្លះអត់ទេ ។

ខស្មានៈ ហ្នឹងយ៉ាំងម៉េចបានចឹង មានការខុសគ្នាចឹង?

គង់ គីមៈ អត់យល់ ។

ដារ៉ាៈ ចុះ ពូអ្នកទោសមានប៉ុន្មានប្រភេទទៅនៅក្នុងហ្នឹង ដូចថាមានលោកសង្ឃ មានយុវជនធម្មតា?

គង់ គីមៈ អត់មាន អារឿងលោកសង្ឃអត់មាន ។ កាលណោះគ្មានហ្មង អត់មានអីលោកសង្ឃទេ

ជា៖ ចុះពូដែលគេមកយកអ្នកទោសចេញ ឬក៏ពេលដែលគេយកអ្នកទោសមកចូលក្នុងគុក ហ្នឹងអី គេមានសំបុត្រស្នាមអីពីថ្នាក់លើទេ?

គង់ គីម៖ ដល់ពេលមក គេមកដល់គេទាក់ទងអ្នកគ្រប់គ្រងគុក ។ អ្នកគ្រប់គ្រងវាដោយឡែក គេគ្រប់គ្រងបញ្ជី ដល់នេះគេនាំយើងទៅការពារ គេនាំមក គេយកមកគេត្រូវដាក់បន្ទប់ណា ឧទាហរណ៍ បន្ទប់ណាដែលវាអត់មានមនុស្សគេបញ្ចូលក្នុងបន្ទប់ហ្នឹង ហើយគេនឹងប្រគល់ឲ្យយើងការពារ ។ គ្រន់ថារឿងសំបុត្រស្នាមផ្ទេរទូអីអត់ដឹង ។

ជា៖ ពូអត់ដែលឃើញ ។

គង់ គីម៖ បាទ! អត់ ។

ជា៖ អត់មានដែលឃើញលិខិតបញ្ជាអីពីលើមក?

គង់ គីម៖ អត់មាន ។

ឧស្មាន៖ ពូ មានស្គាល់ឈ្មោះអ្នកខាងសួរចម្លើយ ឬខាងកាន់បញ្ជីខាងអីក្រៅពីអ្នកយាម?

គង់ គីម៖ អត់ ។

ឧស្មាន៖ អត់មានបានស្គាល់ឈ្មោះខ្លះម្នាក់ពីរនាក់អីទេ?

គង់ គីម៖ អត់ ។ ខ្ញុំគ្រាន់ចេះ កាលណឹងបើនៅជាប់ប្រហែលជាចាំ ឥឡូវវាយូរហើយអត់យកចិត្តទុកដាក់ចឹង មិនអាចចាំបានទេ ព្រោះពេលខ្ញីដែរខ្ញុំនៅគុកមិនបានយូរដែរ ។ ៧៦ ហើយនៅហ្នឹងខ្វះមិនបានមួយឆ្នាំពេញ ។

ឧស្មាន៖ ចុះនៅកន្លែងណឹង ដូចពេលដែលលោកពូយាមហ្នឹងប៉ះឃើញ អឿន ប្រធានកងពលពូហ្នឹងចាប់យកមកដាក់នៅហ្នឹងដែរ?

គង់ គីម៖ បាទ! ចុះកាលហ្នឹងហើយដែលវាចូលចាប់ដល់ទ័ពហើយ គេដកខ្ញុំចេញ ។ ចុងក្រោយមកបានក្រឡុកកន្លែងទ័ពហ្នឹង ។ បានចាប់ផ្តើមឃើញ ឃើញវរសេនាធំ វរកងពលអីហ្នឹង ដល់ចឹងគេហៅខ្ញុំប្រជុំប្រាប់ថាកងពលក្បត់ ។ ដល់ក្បត់ចឹងដល់ក្រោយបន្ទាប់មកបានគេថាទៅដកពួកខ្ញុំហ្នឹង មកព្រលានហ្នឹងបណ្តោយ ។

ឧស្មាន៖ ចុះពេលដែលលោកពូយាមហ្នឹង លោកពូបានឃើញ អឿន ហ្នឹង?

គង់ គីម៖ បាទ! ឃើញច្បាស់ហ្នង ។

ឧស្មាន៖ ហើយលោកពូអាចនិយាយគ្នាបាន?

គង់ គីមៈ   អត់ បានមួយឃើញទេ គ្រាន់មួយឃើញស្គាល់ ។

ខស្នានៈ   ហេតុអីបានមិននិយាយ?

គង់ គីមៈ   គេអត់ឲ្យទៅ អ្នកគុកតែចាប់ហើយ អត់ឲ្យយើងទៅនិយាយទេ បើយើងមានសិទ្ធិតែការពារទេ ។ អត់មានដឹងកិច្ចការសួរសុខសួរទុក្ខសួរពីរឿងហេតុអីអត់ទេ ព្រោះដូចថាវាបាក់មុនវាឲ្យដឹង បើសិនជាយើង អ្នកណាទៅស្និទស្នាលអី គេមានទោស យើងអត់អាចទៅស្និទស្នាលបានទ្បេ

ជាៈ   ចុះពួកគុកហ្នឹងមានក្រៅពីការធ្វើទារុណកម្ម មានការកាប់សម្លាប់អីអ្នកទោសនៅក្នុងហ្នឹង?

គង់ គីមៈ   អត់មានទេ ដល់ទៅវ៉ៃទៅអីធ្វើនោះបានមាន គ្រាន់ទារុណកម្មសួរចម្លើយមាន បើថាវ៉ៃចោលហ្នឹង វ៉ៃអីអត់មានទេ ។ ស្លាប់ហ្នឹង បើស្លាប់ដោយជំងឺស្លាប់ដោយរត់ ។ ជួនកាលដាក់ពីលើឡានមក រត់ហ្នង បាញ់បណ្តោយហ្នឹងមាន បើថាឲ្យ ។

ដារ៉ាៈ   ចឹង ពេលអ្នកទោសរត់អី អ្នកការពារហ្នឹងមានសិទ្ធិបាញ់?

គង់ គីមៈ   បាទ! មានសិទ្ធិបាញ់ ។

ដារ៉ាៈ   អ្នកណាឲ្យសិទ្ធិបាញ់ហ្នឹង?

គង់ គីមៈ   អ្នកដែលគេគ្រប់គ្រងបញ្ជីហ្នឹង គេកំណត់ថាធ្វើម៉េចកុំឲ្យតែរួច ។ បើរួចយើងជាប់ទោស ។ អត់រួចបានទេ ។ តែបើស្លាប់អត់អីទេ ។

ខស្នានៈ   ការដែលយកមនុស្សចូលហ្នឹង ពូបានឃើញជារៀងរាល់ថ្ងៃ ឬក៏ប៉ុន្មានថ្ងៃម្តង?

គង់ គីមៈ   មិនមែនរាល់ថ្ងៃទេ ពីរបីថ្ងៃមកពី២-១ ។ មកចឹងគេគ្រាន់មក យើងគ្រាន់ទៅទទួលគេ គេឲ្យយើងទៅការពារ ជួនកាលតាមថ្នាក់គេឲ្យឡើងទៅលើចឹងទៅ ។ ដូចខ្ញុំនិយាយថាមានពីរបីប្រភេទនោះ មានបីប្រភេទ ។ មានអាថ្នាក់លើយើងគេឲ្យកន្ទេលមានមុងដែលអ្នក បម្រើបាយមានដាក់ថាសចឹងទៅណា ។ ម្ហូបឆ្ងាញ់ ហើយមានបម្រើទឹកតែដាំទឹកតែមួយប៉ាន់ដាក់ឲ្យចឹងដេកទៅ ។ មួយចំនួនទៀតថ្នាក់ក្រោម ក្នុងមួយបន្ទប់ម្នាក់ចឹងមួយបន្ទប់ចឹងប៉ិនថ្នាក់អន់ ហ្នឹងដាក់រួមៗចឹងហ្នង ។ ក្នុងម៉ាបន្ទប់ណឹងឲ្យនៅតែខោខ្លីទេ ។

ជាៈ   ដាក់ខ្នោះដាក់អីដែរ?

គង់ គីមៈ   ដាក់រួមហ្នឹងគឺអត់មានខ្នោះទេ ប៉ិនចាក់សោរពីរបីជាន់ ហើយមានតែខោខ្លីអត់មានស្លីទេក្នុងគុកគឺរលីង ។ អត់ឲ្យមានស្លីទេ គឺមានតែខោខ្លីគត់ ។

ជា៖ ចុះពូនៅពេលអ្នកទោសសម្អាតខ្លួន ឬបត់ដៃបត់ជើងអីធ្វើម៉េចដែរ?

គង់ គីម៖ ឲ្យប្រាប់អ្នកយាម អ្នកយាមស្រែកប្រាប់ ដល់ស្រែកប្រាប់គេបញ្ចេញ យើងមានសិទ្ធិបញ្ចេញឲ្យមកបត់ជើង។ បើថាអ្នកណាមួយឈឺបត់ជើងស្រែកទៅ បញ្ចេញមួយមកជូនទៅបត់ ជើង បត់ជើងរួចបញ្ចូលទៅវិញ។

ជា៖ នៅក្នុងគុកមានអ្នកយាមស្រី?

គង់ គីម៖ អត់មានទេ។

ជា៖ ចុះខបមាអ្នកទោសស្រីអី?

គង់ គីម៖ អ្នកទោសស្រីគឺយើងហ្នឹងដែរ អ្នកយាមយើងហ្នឹង។

ជា៖ ចុះការពេលងូតទឹកងូតអីចឹងធ្វើម៉េច?

គង់ គីម៖ ងូតទឹកមិនដឹងមានបញ្ចេញមួយៗដែរ ងូតទឹក ជូនកាលដាក់ទឹកបញ្ចូលឲ្យទុយោទៅក្នុងហ្នឹង។ កន្ទែងរួមរុញទុយោទៅមុជនៅកន្ទែងហ្នឹង បើយើងជាជងគ្រាន់តែចូលច្រមុះមិនបានជងណឹង។ អ្នកចេញមកមើលខ្លួនមើលប្រាណដូចជ្រូកហ្នឹង ព្រោះអត់មានអាវណា។ មានតែខោមួយខ្វីៗហ្នឹង។ បើអ្នកដែលថ្នាក់លើហ្នឹង បានគេយកចិត្តទុកដាក់មានមុងមានខោអាវត្រឹមត្រូវ។

ដារ៉ា៖ តែក្រោយមកអ្នកទោសទាំងអសហ្នឹងត្រូវបានបញ្ជូនទៅខាងណា?

គង់ គីម៖ ដល់ពេលគេបញ្ជូនខ្ញុំមក អាគុកហ្នឹងនៅដដែល មនុស្សនៅដដែល ដល់នេះទៅវា បាត់ត្រឹមហ្នឹង។ មិនដឹងអ្នកណាគេបន្តទៀត។

ដារ៉ា៖ អត់ទេ ចង់និយាយថា ពេលកំឡុងដែលពូយាមនៅគុកហ្នឹង ជាអ្នកយាមគ្រប់គ្រងអ្នកយាមនៅហ្នឹង។ អ្នកទោស។

គង់ គីម៖ មានចេញមានចូលចឹង ដល់ពេលនេះគេយកបញ្ចេញចឹងទៅ។

ដារ៉ា៖ ប៉ុន្តែពូមានដឹងថាបញ្ចេញទៅណា?

គង់ គីម៖ អត់បានដឹងទេ ព្រោះកាលហ្នឹង បើថាខ្ញុំទ័ពចឹង បើថាគេដាក់នៅក្នុងកំឡុងណា ប្លុកណាគឺនៅមួយប្លុកហ្នឹងទេ។ ទោះបីយើងអ្នកទាហាន ទាហានយាមគុកហ្នឹងអត់បានចេញក្រៅគុកទេ អត់មានចេញដើរលេងទេ។ គឺទំនេរគឺដេកទៅ បាយក៏ហូបហ្នឹងនៅហ្នឹងអត់មានបានដើរអីចេញទៅ មើលនេះមើលនោះដើរលេងអីអត់មានទេ។ អត់ឲ្យដឹងអី

ទាំងអស់ ។ សូម្បីតែក្រៅគុកគេកើតស្អីខ្ញុំ អត់ដឹងដែរ ។ មួយក្រុមដូចតំបន់ដែលយើង ការពារដីប៉ិនណា ឲ្យអ្នកឯងដើរថ្នល់ហ្នឹង ដើរតែថ្នល់ហ្នឹង ។ ទៅមកៗតែប៉ុណ្ណឹងទេ ។ បែកឡូគ្នាច្បាស់ៗចឹងហ្នង ។ ក្រុមខ្ញុំហ្នឹងបើថានៅខាងក្រៅ យាមថ្នលហ្នឹង ពីជ្រោយចង្វារទៅរដ្ឋាករទឹកដើរតែផ្លូវហ្នឹង ។ អត់ឲ្យចូលផ្លូវគេទេ ។

ជាៈ ហឺ គុកពូណឹងនៅកន្លែងណារដ្ឋ ករទឹក?

គង់ គីមៈ គុកខ្ញុំហ្នឹងនៅខាងកើតវត្តភ្នំ ត្បូងរដ្ឋាករទឹក ។

ខស្នានៈ ពិបាកដែររដ្ឋាករក្រែងលោវាមិនរដ្ឋាករឥឡូវ?

គង់ គីមៈ រដ្ឋាករខាងកើតព្រះកេតុមាលានោះ ស្គាល់ពេទ្យកេតុមាលអត់ ។

ខស្នានៈ ឥឡូវមានការផ្លាស់ប្តូរកន្លែងហ្នឹង ។

ដារ៉ាៈ ពេទ្យកេតុមាលាគេហៅថាពេទ្យធំរាល់ថ្ងៃ ពេទ្យទាហានហ្នឹង?

គង់ គីមៈ ពេទ្យហ្នឹងដឹង ។

ខស្នានៈ ពេទ្យហ្នឹង?

ដារ៉ាៈ ពីមុនគេហៅពេទ្យមួយ៧៩ ។

គង់ គីមៈ កៅប៉ុន្មាន?

ជាៈ កាលសម័យក្រោយ ។

ដារ៉ាៈ ហ្នឹងហើយ គេហៅពេទ្យធំៗពីមុនមក ។

គង់ គីមៈ ពេលយើងទៅ ទៅត្បូងតាមផ្លូវជ្រោយចង្វារ រដ្ឋាករទឹកហ្នឹង មិននៅខាងជើងទឹកហ្នឹង ។ ប៉ុនកាលពីជំនាន់ខ្ញុំគេកម្ទេចនេះមួយ ។ កម្ទេចអាវិហារកាតូលិកខាងលិចវត្តភ្នំនោះ ។ ចុចដល់ហើយ ពួកខ្ញុំហ្នឹងគេប្រើឲ្យទៅកម្ទេចហ្នឹងដែរ ។

ដារ៉ាៈ វិហារកន្លែងណា?

គង់ គីមៈ វិហារដូចថាវត្តភ្នំចឹងមក វាមានសួនស្មៅយើងខាងលិចវត្តភ្នំចុះ ហើយបានខាងលិចហ្នឹងគឺមានវិហារមួយ គេហៅកាតូលិក មិនដឹងវិហារអីដឹង ។ កម្ទេចពីរបីខែចុចមីនបោល ។ ដូចគាត់សួរមិញ មានគេកំទេច ។

ដារ៉ាៈ ណឹងហើយ ។

គង់ គីមៈ ហើយកម្ទេចចោលហ្នឹងមួយ ហ្នឹងបើមានចាស់អីដឹងស្គាល់ ឲ្យចំកន្លែង វត្តភ្នំ ។

ឧស្មាន៖ តែវិហារកាតូលិកទេ?

គង់ គឹម៖ ខ្ញុំគ្រាន់តែហៅកាត់ទេ មិនដឹងស្អីទេ ។

ឧស្មាន៖ តើវិហារចាមមានទេ មានកម្ទេចចឹងទេ?

គង់ គឹម៖ អត់ឃើញទេ ខ្ញុំឃើញតែវិហារហ្នឹងមួយកម្ទេចៗឲ្យប្រើយកម៉ឺនដាក់ចុចមួយថ្ងៃៗ ហ្នឹង ។

ជា៖ វត្តអារ៉ាមអីអត់ទេ?

គង់ គឹម៖ អត់ទេ អត់មានទេ អត់មានកម្ទេចទេ ។

ដារ៉ា៖ កាលកម្ទេចវិហារហ្នឹង ពូទទួលបទបញ្ជាពីខាងណាពូ ឆ្នាំណា?

គង់ គឹម៖ ពីឆ្នាំ៧៥ ដែរហ្នឹង ។

ដារ៉ា៖ ចុះអ្នកដែលបញ្ជា?

គង់ គឹម៖ អ្នកបញ្ជាមេវរៈហ្នឹង ព្រោះនោះវានៅក្នុងដីឡូវរៈហ្នឹង ។ ប៉ុនឡានោះវាបន្តជំនួយដឹក គេមកពីសេនាធិការ គេមកពីមជ្ឈិម ។

ដារ៉ា៖ ដែលជំនួយរឿងម៉ឺន រឿងអីកម្ទេចហ្នឹង?

គង់ គឹម៖ បាទ! កម្ទេច ហើយដល់ពេលហ្នឹងកម្ទេចរួចដឹក ។ កម្ទេចរួចចូកដឹកទៅ ។

ដារ៉ា៖ តែពូទទួលបញ្ជាឲ្យកម្ទេចវិហារហ្នឹង ទទួលបញ្ជាផ្ទាល់ពីអ្នកណាមកពូ?

គង់ គឹម៖ ពីវរសេនាតូច ។ ប្រធានយើងវាប្រចាំថ្ងៃដូចថាថ្ងៃស្អែកខ្ញុំទៅ ទៅហ្នឹងគឺទៅគ្រាន់តែ ចុកតែម៉ឺនទេ ។ រៀបចំដាក់ម៉ឺនអាតេតេនោះ ។ មុនដំបូងដាប់ ដាប់វាឲ្យបានកន្ទុក ចឹងទៅ បានដាក់តេតេទៅ បានថយខ្សែឲ្យឆ្ងាយទៅបានចុច ។

ដារ៉ា៖ ចឹងវរសេនាតូចរបស់ពូ ប្រធានឈ្មោះអី?

គង់ គឹម៖ យឹម ណើងហើយ ។

ដារ៉ា៖ ឈ្មោះយឹម ចឹងពូទទួលបញ្ជាពីឈ្មោះយឹមណើងដែលឲ្យទេកម្ទេចវិហារណើង?

គង់ គឹម៖ បាទ! ចឹងបានន័យថា កាលខ្ញុំធ្វើចឹងឃើញកម្ទេចផ្ទះហ្នឹងមួយហើយ ប៉ុនមិនមែនតូច ទេធំណាស់ ។

ដារ៉ា៖ ប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យទៅបាន?

គង់ គឹម៖ ខ្ទង់៣ខែ ។

ដារ៉ា៖ បានកម្មេច?

គង់ គីម៖ បាទ! បានកម្មេចបានយកអស់ៗ កម្មេចហើយអត់មានទុកទេ ឈូស ហ្នឹងចូកកម្មេច មិនដឹងយកទៅចាក់ណា កម្មេចវាៗ

ដារ៉ា៖ ចឹងពេលដែលពូទទួលបញ្ហាទៅកម្មេចវត្ត ទៅកម្មេចវិហារហ្នឹង គេមានប្រាប់ហេតុផលថាហេតុអីបានកម្មេចទេ?

គង់ គីម៖ អត់ កាលហ្នឹងដូចខ្ញុំថា ដូចជាអត់ដឹងសួរទំនៀមទម្លាប់កាលហ្នឹង គេបញ្ជាអីត្រូវធ្វើ អត់មានគឺអត់មានឡូត ឲ្យសួរនាំអីនៅតែអត់ៗ

ខស្វាន៖ ចុះម៉េចបានលោកពូដឹងថា សម្ភារៈដូចជាម៉ឺនអីដែលត្រូវយកទៅកម្មេច សម្ភារៈកើបចូក អីហ្នឹងមកពីមជ្ឈិម ម៉េចបានពូដឹងថារបស់អស់ហ្នឹងមកពីមជ្ឈិម?

គង់ គីម៖ ព្រោះរបស់អស់ហ្នឹង ដល់នេះគេយកមកធ្វើទាំងឡាន ឡានចូកអី ទាំងឧបករណ៍ហ្នឹង កងពលអត់មានទេ ព្រោះបែកភ្នំពេញហ្នឹង កងពលតែឡានអត់មានទេៗ តាមកងពលហ្នឹងអត់ មានឡានអត់មានអីទេៗ មានតែម៉ូតូ វរសេនាធំមានតែម៉ូតូដិះហ្នឹង ហើយអ្នកតូចហ្នឹងៗ អនុសេនាធំម៉ូតូឡានអត់ឲ្យមានទេពួកខ្ញុំហ្នឹងអត់ឲ្យមានទេៗ អនុសេនាធំឲ្យមានកង់ជិះអីហ្នឹងតែមួយហ្នឹងៗ ទាហានឲ្យដើរៗ ម៉ូតូឡានអីហ្នឹងអត់ឲ្យមានទេៗ គឺកម្មសិទ្ធបានបាឡូហ្នឹងហើយៗ គឺបាឡូហ្នឹង គឺទាហានកន្លះខែឆែកម្តងៗ តម្រង់ជួរឆែកបាឡូហ្នឹងៗ សូម្បីតែរបបប្រើប្រាស់បន្តិចបន្តួច ហ្នឹងអត់ឲ្យមាន២មាន៣ទេ មានតែ១ៗទេៗ ឆែកដកសាប៊ូក្រអូប សាប៊ូស្អីដែលយើងយកបានច្រើនៗ ដល់យូរទៅឆែកដកៗ គេអត់ឲ្យមានកម្មសិទ្ធច្រើនទេ កម្មសិទ្ធមាំបាឡូតូចៗ

ដារ៉ា៖ ពូខ្ញុំសុំសួរកន្លែងវិហារហ្នឹង ពូមានដឹងថាវិហារហ្នឹង វិហាររបស់ខាងស្អីទេ?

គង់ គីម៖ អត់ៗ

ដារ៉ា៖ វិហារហ្នឹងរៀងម៉េចពូ?

គង់ គីម៖ មានអាជណ្តើរ២ធំៗ ខ្ញុំធ្លាប់បានឡើងលេងដែរ ដូចថាវិហារហ្នឹង៤ជ្រុងចឹង ៤ជ្រុងហើយខាងមុខហ្នឹងមានជណ្តើរ២ៗ មូលដែរប៉ិនជណ្តើរក្នុងៗ នោះវាវិលយើងឡើងរហូតដល់ លើនោះខ្ពស់ៗ

ខស្វាន៖ ចុះខាងក្នុងមានរូបស្អី?

គង់ គីមៈ អត់ដែលបានឡើងខាងហ្នឹងទេ អា២មុខហ្នឹងឡើង ។

ដារ៉ាៈ ចឹងគ្រាន់តែពូដឹងថា វិហារហ្នឹងសម្រាប់សាសនាអីមួយ?

គង់ គីមៈ បាទ! នេះជាគ្រឹះរបស់តំណាងស៊ីមួយហើយបានកម្ទេច ។

ដារ៉ាៈ ហឺ ពូនៅពេលដែលទទួលបញ្ជាទៅកម្ទេចវិហារហ្នឹង ដូចជាម៉ុន ដូចអីសម្រាប់កម្ទេចវិហារហ្នឹង មិនមែនបានពីកងពលរបស់ពូទេ?

គង់ គីមៈ បាទ! អត់ទេ គេដឹកមកឲ្យពេលហ្នឹងខបករណ៍ទាំងឡានៗ ឡានដែលត្រូវដឹកកម្ទេចកម្ទីដែលយើងកម្ទេចហើយ ហើយទាំងរបស់ចូកអីគឺបញ្ចេញពីខាងក្រសួបមជ្ឈិមគេមក ។

ដារ៉ាៈ ចុះ ពូហេតុអី ពូធ្វើម៉េចបានដឹងថា ទាំងម៉ុនទាំងឡានមកពីមជ្ឈិមពូសំគាល់យ៉ាងម៉េច?

គង់ គីមៈ សម្គាល់ពេលយើងចូលរួម យើងមានវេនដែលកម្ទេចដែរ ដល់ចឹងគេប្រគល់ឲ្យគឺក្រុមគេ គឺយើងដឹងថាហ្នឹងសុទ្ធតែក្រុមព្រោះខាងមជ្ឈិមទេ ព្រោះកងពលយើងយើងស្គាល់ ។ របស់កងពលអត់មានទេ កងពលអត់មានឡានអត់មានស៊ីទេ ។

ដារ៉ាៈ ប៉ុន្តែវាអាចថាឡាន ឬគ្រប់ម៉ុនហ្នឹង មិនមែនមកពីមជ្ឈិមវាអាចមកពីក្រុមអីផ្សេងទៀតពូសម្គាល់យ៉ាងម៉េចបានដឹងថាឡានអីណឹងមកពីមជ្ឈិម?

គង់ គីមៈ ឡាន បានដឹកឡានមជ្ឈិមព្រោះរបស់របរហ្នឹងគេនិយាយថា របស់ដែលដូចឡានហ្នឹងគ្រឿងល្អៗគ្រឿងធំៗហ្នឹងកងពលអត់មានទេ គេកំណត់របស់ហ្នឹងជារបស់មជ្ឈិម ។ សូម្បីតែយើងខទាហរណ៍កងទាហានយើងហ្នឹង ដែលត្រូវដកទៅណាទៅណី គឺបញ្ជូនទៅណាទៅណីគឺដឹកស៊ីៗ វរសេនាតូចគេថាទាល់តែយកឡានពីមជ្ឈិមគេថាចឹង ។ រឿងនៅក្នុងអគ្គភាពអត់មានឡានទេ កងពលក៏អត់មានដែរ ។

ជាៈ ចុះពូខ្ញុំសុំសួរតិចអាកន្លែងវិហារហ្នឹង នៅខាងណាវត្តភ្នំ?

គង់ គីមៈ ខាងលិច ។

ជាៈ ខាងលិចចំសួន?

គង់ គីមៈ បាទ! សួនស្មៅយើងរហូតយើងខាងជើងហ្នឹង មានអូតែលមួយ ។ អូតែលហ្នឹងកាលហ្នឹងមិនដឹងណាមិនដឹងទេ ដូចជាខ្ញុំស្តាប់មិនច្បាស់ ។ កាលហ្នុងដូចផេកូដឹង មិនដឹងណាមិនដឹង ប៉ុនមានទូតនៅហ្នឹង អូតែលខាងជើងវត្តភ្នំ នៅចំសួនស្មៅហ្នឹង វិហារហ្នឹងពេញ ។

ជា៖ ខាងណោះថ្នល់?

គង់ គីម៖ ខាងលិចថ្នល់។

ជា៖ ខាងលិចថ្នល់?

គង់ គីម៖ បាទ!

ជា៖ ខាងក្នុងវិហារហ្នឹងគេមានដាក់និមិត្តសញ្ញាអីសម្គាល់?

គង់ គីម៖ ខ្ញុំអត់បានចូលមើល ប៉ុនបើយើងអើតពីខាងលិចវត្តភ្នំចំសួនស្មៅហ្នឹង គឺធំណាស់ពេញមើលទៅបាំងពេញធំណាស់នៅជាប់នឹងថ្នល់ហ្នឹង ខាងលិចថ្នល់ អាថ្នល់ធំនោះ។

ជា៖ ខាងក្រៅក៏អត់មានដាក់រូបសញ្ញាសម្គាល់អី?

គង់ គីម៖ បាទ! មានក្បាច់ក្បូរចម្លាក់អីខេងខាងអីមាន មានចម្លាក់អីមាន។

ដាវ៉ា៖ នៅខាងលិចចំ ចំកន្លែងសួនច្បារទៅត្រង់ចេស?

គង់ គីម៖ បាទ ខាងលិចចំនោះហើយ ខាងលិចផ្លូវទៀត។

ដាវ៉ា៖ ចឹងរាល់ថ្ងៃពូមានដែលបានទៅកន្លែងហ្នឹងទៀតទេ?

គង់ គីម៖ អត់ដែលបានទៅទេ ប៉ុនដែលខ្ញុំនៅណឹង ដែលកាលពីកម្មេចនោះអត់មានធ្វើអីគឺដីស្មើហ្នូង។

ដាវ៉ា៖ ព្រោះរាល់ថ្ងៃចេស រាល់ថ្ងៃហ្នឹងនៅខាងលិចវត្តភ្នំហ្នឹង វាជាក្រសួង នៅខាងស្តាំដៃក្រសួងហិរញ្ញវត្ថុ បន្ទាប់ពីក្រសួងហិរញ្ញវត្ថុ បណ្ណាល័យជាតិ បន្ទាប់ពីបណ្ណាល័យជាតិទៅវាមាន សណ្ឋាគារឡឺរ៉ូយ៉ាល់។ ដល់នៅខាងឆ្វេងដៃនេះ វាមានកន្លែងពីមុនគេហៅកន្លែងយុវជនក្លិបយុវជន ហើយបន្ទាប់មកទៀតសាលាវិទ្យាស្ថានគ្រប់គ្រងជាតិអីហ្នឹង។ ដែលគេហៅថាសាលាពាណិជ្ជកម្ម។ ដល់ពេលត្រង់ធ្លាទៅ វាទៅចំផ្លូវធំមួយកាត់ផ្តាច់ត្រឹមណឹងហ្នូង។ ចឹងវិហារនៅត្រង់ណា?

គង់ គីម៖ នៅខាងលិចផ្លូវហ្នឹង។

ឧស្មាន៖ នៅខាងលិចផ្លូវមួយទៀត។

គង់ គីម៖ បាទ!

ឧស្មាន៖ នៅកន្លែងសព្វថ្ងៃនៅ?

ដាវ៉ា៖ អត់ទេ សព្វថ្ងៃដាក់កន្លែងផ្កាយរណប។

គង់ គីមៈ វាទៅហ្នឹង វាទៅជិតកន្លែងរដ្ឋាករទឹក កន្លែងលាយទឹក មានឃើញនៅហ្នឹងអត់ ។

ខស្មានៈ ឃើញៗ ។

គង់ គីមៈ វាមានអាងៗ វាចេញពីអាងមួយ ទៅអាងមួយ ។

ដារ៉ាៈ កន្លែងណឹងជិតសាលាក្រុងភ្នំពេញ?

គង់ គីមៈ បាទ! ខ្ញុំនិយាយហ្នឹងនិយាយតាំងពីជំនាន់ហ្នឹងទេ បានដឹងប៉ុនឥឡូវខ្ញុំអត់ដែលដឹងទេ ហ្នឹងវានៅខាងកើតជាប់អាងទឹកគេបង្ហូរទឹកអីនោះ ។

ខស្មានៈ ជាប់ហ្នឹង?

គង់ គីមៈ បាទ!

ខស្មានៈ ជាប់នឹងស្ថានីយ៍រថភ្លើងដែរ?

គង់ គីមៈ បាទ! ប៉ុនខាងជើងស្ថានីយ៍ទេ ។ ខ្ញុំចាំបានប៉ុណ្ណឹង ។

ខស្មានៈ ចុះលោកតា អាចគិតមើលថា វិហារណឹងជាតំណាងសាសនាឥស្លាម យេស៊ូ ឬក៏សាសនាអី?

គង់ គីមៈ អត់ កាលហ្នឹងអត់យល់ ។ ប៉ុនគ្រាន់ដឹងថា គោលដៅគេកំទេចហ្នឹងបំបាត់ភស្តុតាងហ្នឹង គ្រាន់ដឹងចឹង ព្រោះកម្ទេចអត់មានយកទៅធ្វើអីទេ គឺកម្ទេចឲ្យវាបាត់ហ្នឹងទេ ។ កម្ទេចទៅមានដីទទេដដែលហ្នឹង ។ គេកម្ទេចចោលកុំឲ្យមានរូបភាពនៅហ្នឹង ។ ប៉ុនត្រង់ថារូបហ្នឹងជារូបអី ប៉ុនខ្ញុំថាបើសិនជាមានចាស់នៅហើយអ្នកនេះអាចដឹង ។ គេដឹងហើយស្គាល់ហើយ មិនស្លាប់អស់ ទេមនុស្សនោះអាចសួរអ្នកនៅទីក្រុងភ្នំពេញថា តើត្រង់ហ្នឹងជាវិហារស្អីដឹងហើយ ។ ឲ្យដឹងថា ។

ជាៈ ចុះ ពូចេញមកនៅកំពង់ឆ្នាំងវិញ នៅឆ្នាំណាដែរ?

គង់ គីមៈ ខ្ញុំដែលនៅព្រលានហ្នឹង ដែល៧៩ វៀតណាមវៃចូលទឹកដីហ្នឹង ខ្ញុំមិនរត់ទៅព្រៃវិញ ។ នៅជាមួយទ័ព ប៉ុល ពតដដែល ធ្លាក់ទៅនៅទ័ព ប៉ុល ពត ដដែលខ្ញុំនោះ ។

ជាៈ អត់ទេ ក្នុងរបប ប៉ុល ពត ហ្នឹង កាលគេបញ្ជូនមកធ្វើព្រលានហ្នឹង?

ដារ៉ាៈ មកធ្វើព្រលានកំពង់ឆ្នាំងវិញ នៅឆ្នាំចិតសិបប៉ុន្មាន?

គង់ គីមៈ អូ! ៧៦ ប៉ុនវាចុងហើយ គ្រាន់តែមកដល់ហ្នឹងបានប្រហែលម៉ាខែជាងចូល៧៧ហ្នុង ។ មកព្រលានហ្នឹងគ្រាន់តែបានមកហ្នឹង គ្រាន់តែឲ្យមកនៅដឹងឃើញ ដើរមើលថាគេធ្វើ

ព្រលានហ្នឹងហើយ មានចិនមានអីហ្នឹង ។ ដល់បាននៅចឹងក៏គេបញ្ជូនខ្ញុំទៅវៃរៀបចំកូនៗ មេៗ គេចាប់ចឹងហើយ ។ ដល់ហើយយួនវ៉ៃខាំងគេរើសកូនៗ ហ្នឹងយកខាងនិរតីមកធ្វើជាមេ ។ បញ្ជូនឲ្យទៅវៃ យួនណឹងបណ្ដោយ ។ ដល់ទៅវៃនៅព្រំដែនហ្នឹងអត់មានមេខាងភូមិភាគខត្តរទេ ។ មានសុទ្ធតែកូន ទេ ។

ដារ៉ាៈ ចឹង ទ័ពដែលទៅវៃជាមួយវៀតណាមហ្នឹង ខាងពូហ្នឹង គឺទ័ពពីមុនមក?

គង់ គីមៈ បាទ! សុទ្ធទ័ពពូមុន ។

ដារ៉ាៈ ប៉ុន្តែខាងក្បាលម៉ាស៊ីនខាងលើ?

គង់ គីមៈ ក្បាលយកពីលើមកក្តាប់ទេ បានដឹកទៅវៃ ។

ជាៈ ខាងហ្នឹងខាងណាពូ?

គង់ គីមៈ តាកែវ សំបូរតែតាកែវ សុទ្ធតែពួកតកែវ និយាយអីវ៉ាន់អីចឹង ។

ជាៈ ចុះប្រធាននៅក្នុងព្រលានយន្តហោះហ្នឹងប្រធានគាត់ឈ្មោះអីគេ?

គង់ គីមៈ តារវៃ តាធួក ។

ខស្នានៈ ខ្មែរ?

គង់ គីមៈ បាទ! ខ្មែរ ដុះក្បាលពោះក្រហ៊ុយៗ នៅហ្នឹង ។

ខស្នានៈ ចុះខាងចិន មេដឹកនាំ?

គង់ គីមៈ អូ! ចិននោះអត់មានស្គាល់ទេ ។

ខស្នានៈ អត់ស្គាល់ឈ្មោះទេ?

គង់ គីមៈ អត់មានស្គាល់ទេ គ្រាន់មកជាកម្មករចិននោះពាក់អាវខៀវយើងហ្នឹង ។ឡានទេសចរណ៍ក្រហមៗ នោះ មកព្រឹកឡើងពីយកមកពីកំពង់ឆ្នាំងយកមក ។ ដូចថាចិនមួយចឹង ខ្មែរមួយក្រុមឲ្យធ្វើអីទៅ ចិនដូចថាគេអ្នកបច្ចេកទេស ខ្មែរអ្នកកម្លាំងនោះ ។

ជាៈ ចិន មានចំនួនច្រើនពូ?

គង់ គីមៈ ចិន ច្រើនណាស់ ចិនរាប់រយ ។ ខ្ញុំដើរទៅកន្លែងម៉ាស៊ីនអាឈើចិននោះ អត់វុញនឹងកម្លាំងទេដាក់ម៉ាស៊ីនមួយ ។ ឈរបញ្ឈរលើហ្នឹងហ្នង ។ ទៅមកៗ អត់មានវុញជិះលើហ្នឹងទេ ។

ដារ៉ាៈ ពូកាលដើមឆ្នាំ៧៧ កាលពូបាននិយាយថា មានខាងនិរតីមករៀបទ័ពនៅវ៉ៃវៀតណាម ពេលហ្នឹងគេប្រាប់ថាយ៉ាងម៉េច?

គង់ គីមៈ ថាទៅវ៉ៃយួន ថាយួនឈ្លានពាននោះ ថាយួនឈ្លានពានចូលដល់កំពង់ចាម ។ រៀបចំកម្លាំងទៅវ៉ៃ ។

ដារ៉ាៈ ពេលដែលទៅវ៉ៃណឹងមានប្រជុំប្រាប់ទៀតថា គេជួបវៀតណាមពេលចាប់បានធ្វើយ៉ាងម៉េចៗអីទេពូ មានបានប្រាប់ទេ?

គង់ គីមៈ ដែលទៅ គ្រាន់តែបេះ កាលហ្នឹងវាប្រជុំដូចថា វៀតណាមហ្នឹងចូលមកឈ្លានពានសម្លាប់ពួកនៅខាងត្រើយម្ខាង ខាងកំពង់ចាម ។ ចឹងឲ្យយើង បើសិនជាឃើញអីថាសម្លាប់កុំឲ្យនៅសល់ កាលហ្នឹងមិនប្រាប់ចឹងហីពួកខ្ញុំហ្នឹង កាលគេយកមកនៅព្រលានហ្នឹងគេគាប គេបង្អត់បាយមិនឲ្យស៊ីគ្រប់ណា ដែលគេយកខ្ញុំមកដូចដាក់ឲ្យរៀនហ្នឹងរបៀបដូចថាកាលមេៗក្បត់ហ្នឹង គេឲ្យស៊ីតិចៗណឹង ។ ចឹងវាល្វើយ ដល់បានគេឲ្យទៅវ៉ៃ វាអរ វាមានសិទ្ធិមានកាំភ្លើងកាន់នោះ ។ លើកដៃព្រមទៅគេ ។

SideB

គង់ គីមៈ វ៉ៃពីនោះមក ចុះមកទ័ពតំបន់ ទ័ពស្រុកវាខ្សោយនោះ ដល់ពួកខ្ញុំនៅចាំ វាបាក់ទៅវិញបានពួកខ្ញុំដេញវ៉ៃចឹងទៅ ។ ឆ្ងាយដល់ទៅតាមផ្សារក្រដាសចូលទៅដល់តែនិញហ្នឹងណា ។ ប៉ុនមិនចូលដល់ខេត្តទេខ្ញុំនោះ ។ គ្រាន់តែឆ្លងមួយស្រុកខ្ញុំរបួសខ្ញុំមកវិញមក ។

ជាៈ ចឹង ពូកម្មករដែលធ្វើការនៅព្រលានហ្នឹងប៉ុន្មាននាក់ដែរ?

គង់ គីមៈ រាប់ពាន់ណោះ ប៉ុនសុទ្ធតែខាងបូព៌ា ។

ជាៈ ខាងពួកបូព៌ាមក?

គង់ គីមៈ បាទ! ពួកបូព៌ាទាំងអស់ ប៉ុនអត់មានមេ អត់មានថាមេ មេគេគ្រាន់តែមេដែលក្រុមការងារទេ អត់មានមេក្នុងប្រដាប់អាវុធអីទេ ។ ចិនគេជំនាញហ្នុង ។ ឧទាហរណ៍ថាក្នុងការងារអីមួយចិនមួយ ។ យើង២០ ទៅតាមការងារសំណង់ចាក់ពុម្ពជីករណ្ដៅជីកអីហ្នឹង ជំនាញការលើចិន យើងគ្រាន់កម្លាំងលើយើង ។

ខស្មាន:	ចុះ តាធូក, តារ៉េវ ហ្នឹងតួនាទីគាត់ស្អីដែរ?

គង់ គីម:	ពួថាកងពលផង ពួថាសេនាធិកា គេថាដៃស្តាំនៅក្នុងមជ្ឈិម ។

ខស្មាន:	អូ! ដៃស្តាំមជ្ឈិម?

គង់ គីម:	បាទ!

ដារ៉ា:	ចុះ ពួបានឡើងទៅចូលក្នុងសមរភូមិវៃវៀតណាមហ្នឹង?

គង់ គីម:	បាទ!

ដារ៉ា:	នៅឆ្នាំ៧៧?

គង់ គីម:	បាទ! នៅឆ្នាំ៧៧ ។

ដារ៉ា:	ពេលកំឡុងមានការវៃប្រទង់គ្នាហ្នឹង មានបានចាប់បានវៀតណាមទេ?

គង់ គីម:	សមរភូមិខ្ញុំអត់មានចាប់បាន បើបាញ់ស្លាប់បាញ់ បើថាចាប់រស់អត់មានទេ ។

ដារ៉ា:	អត់មានចាប់បានទេ?

គង់ គីម:	បាទ!

ដារ៉ា:	ទាហានអី?

គង់ គីម:	អត់មានទេ ។

ដារ៉ា:	ចុះពេលវៃចូលដល់តៃនិញហ្នឹង ប្រជាជនប្រជាអីហ្នឹង?

គង់ គីម:	អូ បើប្រជាជនអត់មានទុកទេ ផ្ទះវៀតណាមផ្ទះដី ដូចបិទដីដំបូកហ្នឹង ។ សំបូរអំពៅ សំបូរអីណាស់ ។ អារឿងចូលទៅ អារឿងអត់ទុកទេ ។

ដារ៉ា:	ឲ្យតែប្រទះដឹងតែ?

គង់ គីម:	បាទ! គឺអត់មានចាប់មានអីទេ ។

ដារ៉ា:	អត់មានគិតថាវៀតណាមណឹងជាទាហាន ឬជាប្រជាជន?

គង់ គីម:	អត់ទេៗ អត់គិតទេ ។

ដារ៉ា:	ការបញ្ជាចឹងមេកងពលហ្នង?

គង់ គីម:	បាទ! មេបន្តបន្ទាប់តាមមេយើង បន្ទាប់យើង ។

ដារ៉ា:	ចឹង ពេលដែលទៅវៃជាមួយវៀតណាមហ្នឹងប្រធានកងពលពួឈ្មោះអី?

គង់ គីម:	ផន ។

ដារ៉ាៈ ឈ្មោះ ផន មកពីណា?

គង់ គីមៈ មកពីខាងតាកែវ ។

ដារ៉ាៈ ខាងតាកែវវិញ?

គង់ គីមៈ បាទ!

ដារ៉ាៈ បន្ទាប់ពី ផន មានពីណាទៀត?

គង់ គីមៈ អត់ អត់ស្គាល់ព្រោះខ្ញុំទៅមុខបាត់ហើយ ពួកពលនៅក្រោយ ប៉ុន្តែដឹងថាផនពេលទៅដល់រៀបចំប្រជុំនោះ ។ ប្រជុំមុនដំបូង ។ ប៉ុនទៅបានមួយឈុលទេ ពួកកងពលបញ្ជូននិរតីតែមេៗ វាងាប់អស់ទៅ ។ ចឹង អាពួកខ្ញុំឡើងទៅដែរ ។ ខ្ញុំបានអនុសេនាធំមកវៃបញ្ជូនទៅកន្លែងដដែល មកវៃរហូតដលរបួស ។

ដារ៉ាៈ ចុះឈ្មោះ ផន ដែលមកពីនិរតីមករៀបចំទ័ពទៅវៃនឹង?

គង់ គីមៈ បាទ ពេលយើងទៅពីនេះទៅ ឆ្លងដល់កំពង់ចាម គាត់ទទួលគាត់រៀបចំណឹង ។ រៀបចំអាវុធបំពាក់ហ្នឹងតើ ។ ទៅពីនេះខ្លួនទទេទេ ។ ទៅដល់ឆ្លងកំពង់ចាមបានបំពាក់អាវុធ ។

ដារ៉ាៈ ចឹង ពេលបំពាក់បំពាក់អីណឹង ឈ្មោះ ផនហ្នឹង?

គង់ គីមៈ បាទ កងពលណឹងហើយរៀបចំទៅវៃវៀតណាម ។

ដារ៉ាៈ ពេលហ្នឹងមានឈ្មោះអី?

គង់ គីមៈ ខ្ញុំអត់ ដល់ហ្នឹង អត់ចាំលេខទេ ។

ជាៈ មិនមែន៣១០ទេ?

គង់ គីមៈ មិនមែន ហ្នឹងកែប្រែហើយ ៣១០បានទៅវៃកាលទាហានប្រចាំការ ។

ខស្មានៈ ៧៥នេះទេ?

គង់ គីមៈ ឫ ៴ទ ហ្នឹកដែលគេនេះ តាសោភីម ណឹងខ្ញុំនៅខាងតើ ។

ខស្មានៈ នៅណា?

គង់ គីមៈ ខ្ញុំនៅខាងមុខហួស ដល់ហើយដែលគេដាក់ តាសោភីម អូសនឹងឡានហ្នឹងហើយ ។ នោះកងពលខ្ញុំហើយ ប៉ុនខ្ញុំចំណែកខ្ញុំនៅមុខ ។

ជាៈ កាលហ្នឹងហេតុអីបានចាប់ តាសោភីម?

គង់ គីមៈ គេផ្សព្វផ្សាយថា តាសោភីម ក្បត់នៅក្រោយ គេរំលែកទ័ពមកពីមុខដែរតើ យកមកត្រៀមចាំបាញ់តាសោមភីមណឹង ។ កាលហ្នឹងខ្ញុំនៅហ្នឹងតើ ។

ជាៈ គេចាប់គាត់បាននៅណាពូ?

គង់ គីមៈ គឺស្អីទេ ត្រង់ណឹង ចំការកៅស៊ូខាងក្រោយជប់មិនដឹងត្រង់ហ្នឹង ។

ជាៈ ពេលគេចាប់គាត់បានហ្នឹង គេអូសគាត់ហ្នឹង គាត់ស្លាប់ ឬក៏រស់?

គង់ គីមៈ គេថា ចាប់បានហ្នឹង បាញ់ៗគាត់ស្លាប់ហើយ បានគេយកទ័ពដាក់ឡានអូស ។

ជាៈ អូសតាមណា?

គង់ គីមៈ អូសតាមថ្នល់ហ្នឹង កាលហ្នឹងគេដាក់ក្នុងសៀវភៅតូចៗ សៀវភៅខាង ប៉ុល ពត ។

ជាៈ ពូ ខ្ញុំសុំសួរនៅព្រលានយន្តហោះហ្នឹងវិញ ពូថា ពួកពូដែលទៅធ្វើការហ្នឹងរាប់ពាន់នាក់កាលដែលឲ្យចំណីអាហារអត់សូវគ្រប់គ្រាន់ចឹង?

គង់ គីមៈ បាទ! អត់គ្រប់គ្រាន់ទេ ។

ជាៈ គេចាត់ទុកពួកពូហ្នឹងជាស្អីគេបានគេមិនឲ្យ?

គង់ គីមៈ ព្រោះគេយកទៅធ្វើព្រលានហ្នឹង បើយើងប្រៀបធៀបថា យើងជានិន្ទាការព្រោះមេៗយើងជាក្បត់ ចឹងគេយកឲ្យទៅធ្វើពលកម្មធ្វើព្រលានហ្នឹងរួមនឹងភូមិភាគឧត្តរមួយចំនួន និងបូព៌ា ។ សុទ្ធសាច់បូព៌ា បូព៌ាអស់អត់មានមេទេ មេៗប្រហែលគេយកទៅដាក់គុកដាក់អីហ្នឹង ។ កូនៗមកហ្នឹងទាំងអស់ ។ ចឹងដល់មកដល់ហ្នឹងគេរៀបជាក្រុមហើយទៅសហករណ៍ ។ ដូចថាក្នុង៦០នាក់គេដាក់សហករណ៍មួយ គេចំហុយបាយឲ្យស៊ីហ្នឹង ។ គេធ្វើកាធុនប៉ុនៗណេះ ដល់ចំណុយ នោះគេឲ្យមួយកាធុន៤នាក់ ។ ដល់៤នាក់មិនកែងចឹង កូតចឹង ហើយម្នាក់បានតែប៉ុណ្ណឹងទេបាយ ។

ជាៈ មួយថ្ងៃធ្វើការប៉ុន្មានម៉ោង?

គង់ គីមៈ គ្រាន់ចាំមើល ព្រឹកឡើងម៉ោង៤កន្លះហាត់ ងើបពីហាត់មួយពីរបេះតែហាត់ចឹងអត់ល្ងាចទាល់តែម៉ោង១០បានឲ្យដេក ធ្វើស្មៅ ទៅពីនេះទៅឲ្យដាំដំឡូងដាំអីចឹង ។ ព្រឹកឡើងម៉ោង៧ចូលដល់ ។ ចូលដល់ការងារ ដល់ម៉ោង១១បានចេញ ។ ម៉ោង១ចូលទៀត ។ ធ្វើការអត់មាន សម្រាកទេ ។

ជាៈ អាហារឲ្យប៉ុន្មានថ្ងៃក្នុង ប៉ុន្មានដងក្នុងមួយថ្ងៃ?

គង់ គីមៈ ពីរពេលទេ ។

ជាៈ ពីរពេលទេ?

គង់ គីមៈ បាទ! ម៉ោង១១ និងម៉ោង៥ ។ បាយដូចខ្ញុំថាចឹង បាយគេចំហុយគេធ្វើកាធុន កាធុនចឹង គេចំហុយចឹង ពេលហូបគេឲ្យយើងមាំកាធុនគ្នា៤នាក់ ចឹង៤នាក់មិនកែវចេញដូចគ្នា ។

ជាៈ ពេលដែលយើងធ្វើខុសធ្វើអី មានគេចាប់យកទៅធ្វើបាបធ្វើអីទេ?

គង់ គីមៈ កាលនៅកូនៗអត់មានទេ ខ្ញុំនៅណឹងអត់មានឃើញចាប់ឃើញអីទេ ប៉ុនដូចថាគេតិទៀនអី គេថាមិត្តឯងខ្ជិលអីចេសៗធ្វើការមិនកើត គេមានការតិទៀនចឹងប៉ុនចាប់វៃអត់មានទេរឿងកូនៗ ។ ប៉ុនទៅហ្នឹងអត់មានទេរឿងមេអស់ហើយ ។ ចាប់ពីអនុសេនាតូចឡើងទៅមេមកពីគេ ទាំងអស់ ។

ជាៈ ពូការងារសំខាន់នៅក្នុងព្រលានហ្នឹងធ្វើអីគេពូ?

គង់ គីមៈ ធ្វើព្រលានហ្នឹងហើយ ឧទាហរណ៍តាមមុខសញ្ញា ខ្ញុំទទួលខាងកាត់ដែក កាត់ដែកអ្នកណាជញ្ជូនអាថ្មបញ្ចូលមាំស៊ីនឲ្យវាខាំនោះ ។ ខាំទៅអាណាជីកតាមប្ញសនោះ ដូចថាគល់មួយគេមិនឲ្យ ជីកតាមប្ញសឲ្យអស់ ។ តាមប្ញសចឹងទៅ ។ ការងារច្រើនណាស់ ប៉ុនចិនហ្នឹង យើងមាំក្រុមចិនម្នាក់

ជាៈ យើងមួយក្រុមប៉ុន្មាននាក់?

គង់ គីមៈ មួយក្រុមតាមការងារហ្នឹងទី១ប៉ុន្មាន គេដាក់ប៉ុណ្ណឹង ។ ក្រុមខ្លះ២០ទៅចិន១ ។

ជាៈ ពូ ពូមានដឹងពីគោលបំណងនៃការធ្វើព្រលានហ្នឹង ធ្វើដើម្បី?

គង់ គីមៈ អត់ដឹងទេ ដឹងតែគេហៅមកធ្វើៗរឿងគោលការណ៍ម៉េចអត់ដឹងទេ ។

ដារ៉ាៈ ចឹងពូចូលទៅក្នុង ខ្ញុំសួរត្រឡប់ទៅវិញ ពេលដែលពូចូលក្នុងសមរភូមិវៃជាមួយវៀតណាម ពូ ធ្លាប់ឃើញផ្ទាល់ភ្នែកថាមានការសម្លាប់ប្រជាជនវៀតណាម ឬក៏ដុតផ្ទះសំបែងអីទេពូ?

គង់ គីមៈ បាទ! ហ្នឹងចូលរួមផ្ទាល់ហ្នង ដឹកនាំខ្ញុំក៏ដឹកនាំដែរ ខ្ញុំណឹងដែរ ចូលមេទ័ពដែរ ប៉ុនមេថ្នាក់តូច ។

ដារ៉ាៈ ប៉ុន្តែចំពោះផ្ទះរបស់ប្រជាជនវៀតណាមក៏ដោយដុតចោល?

គង់ គីមៈ បាទ! ដុត ប៉ុនផ្ទះវៀតណាមវាអត់សូវផ្ទះធំ វាច្រើនផ្ទះទាបចឹង វាច្រើនដនបទដែរ ដែលខ្ញុំទៅចូលដល់ផ្សារក្រដាសហ្នឹង ប៉ុនជាឲ្យបំផ្លាញខ្ទេចហ្មងអត់មាន។

ដារ៉ាៈ ចំពោះប្រជាជនស៊ីវិលអីពូ?

គង់ គីមៈ អត់ឲ្យសល់ទេ ឲ្យតែឃើញនៅចំពោះមុខ គឺកាចហ្មង។ ទាំងខ្ញុំទាំងគេកាលហ្នឹងកាចហ្មង ដូចមានមនោគមអីទៅហ្នឹង គេបញ្ចូលអីគឺទៅហ្នឹងគឺអត់មានចេះពិចារណាអីគេ គឺខឹងដូចខឹងពីកាលណាចឹង។

ខស្មានៈ ពូ គេមានប្រាប់ទេ ថាមូលហេតុអីបានជាឲ្យតែឃើញសម្លាប់វៀតណាម ឃើញវៀតណាមសម្លាប់វៀតណាមចឹង។

គង់ គីមៈ ថាគេបង្រៀនតាំងពីតែអ៊ុងយកដាក់ក្បាលដុតអីណា គេថាឲ្យឆាប់ ថាវេទនាណាស់ និយាយតៗចឹង មានដឹងថាវៀតណាមណឹងចាប់ខ្មែរ៣នាក់ យកយើងហ្នឹង កប់យើងទៅយកក្បាលយើងដាំតែទម្រាំឆាប់នោះ។

ខស្មានៈ ប្រាប់ចឹង?

គង់ គីមៈ បាទ! ប្រជុំតាមថ្នាក់គេ ចេះប្រាប់វៀតណាមចឹង តែអ៊ុងតែអីចឹង។

ដារ៉ាៈ នៅក្នុងក្រុមជាមួយពូហ្នឹង ពូមានស្គាល់អ្នកណាផ្សេងទៀតដែលនៅរស់រានមានជីវិតដូចពូចឹង ដែលអាចខ្ញុំទៅជួបសម្ភាសន៍អីចឹងបានទេពូ?

គង់ គីមៈ ហ្នឹងអត់ ព្រោះចេសកងកាលទៅវៃយួនវាមាននេះ មានសមរភូមិផ្សេងទេ ដែលរួមចំណែកជាមួយខ្ញុំអត់មានទេ ឆាប់ៗមែនទែនឆាប់ចង់អស់ ខ្ញុំណឹងមានរបួសធ្លាយពោះកាត់ពោះវៀនពីរកំណាត់។ ប៉ុនអ្នកដែលទៅចូលរួមបានដោយខ្សែកគ្រាន់តែអត់បានមុខព្រួញជាមួយគ្នាប៉ុន្តែដូចគ្នា ប៉ុនគេនៅត្រង់សេ ហ្នឹងរបួសមកជាមួយខ្ញុំដែរ ហ្នឹងផ្សេងណឹងបានមកទៅដូចគ្នា ប៉ុនមុខព្រួញវាខុសគ្នា។

ដារ៉ាៈ បាទ! ឈ្មោះអីគេពូ?

គង់ គីមៈ ឈ្មោះមី នៅត្រពាំងឫស្សី។

ដារ៉ាៈ ស្ដីមីពូ?

គង់ គីមៈ ម៉ែន មី។

ដារ៉ាៈ ម៉ែន មី រាល់ថ្ងៃរស់នៅណាពូ?

គង់ គីមៈ	នៅត្រពាំងឫស្សី ។

ដារ៉ាៈ	ត្រពាំងឫស្សីភូមិ ឬឃុំ?

គង់ គីមៈ	ភូមិត្រពាំងឫស្សី ឃុំជៀបដែរ ។

ដារ៉ាៈ	ភូមិត្រពាំងឫស្សី ឃុំជៀប ឈ្មោះម៉ែន មី ។

គង់ គីមៈ	បាទ!

ដារ៉ាៈ	គ្រួសារគាត់ឈ្មោះអីដែរ?

គង់ គីមៈ	មិនដឹងប្រពន្ធឈ្មោះអីទេ ។

ដារ៉ាៈ	តែរាល់ថ្ងៃនៅរស់ទេ?

គង់ គីមៈ	នៅរស់ ។

ដារ៉ាៈ	នៅរាល់ថ្ងៃ?

គង់ គីមៈ	បាទ! នៅរាល់ថ្ងៃ ។ ម្នាក់ផ្ទះខាងកើតនេះក៏ទៅដែរ ប៉ុនឥឡូវគេធ្វើទាហាននៅវរ៧ ។

ខស្មានៈ	ចុះ ម៉ែន មី ហ្នឹងគាត់ទៅព្រំដែនហ្នឹងដែរ?

គង់ គីមៈ	បាទ! របួសមកដេកពេទ្យជាមួយខ្ញុំដែរហ្នឹង ។

ដារ៉ាៈ	ប៉ុន្តែគ្រាន់តែមុខព្រួញខុសគ្នា?

គង់ គីមៈ	បាទ! មុខព្រួញខុសគ្នាប៉ុនវៃយួនដូចគ្នា ។

ខស្មានៈ	ចុះនៅយាមគុកយាមអីជាមួយគ្នា?

គង់ គីមៈ	អត់ទេ ។ និយាយពីវគ្គត្រឹមព្រំដែនណោះទេ ។

ដារ៉ាៈ	ចុះថាខាងកើតផ្ទះ?

គង់ គីមៈ	ហ្នឹងធ្វើទាហាន ប៉ុនឥឡូវគេធ្វើទាហានដែរ ទៅវៃយួនដូចគ្នាដែរ ។

ដារ៉ាៈ	គាត់ឈ្មោះអី?

គង់ គីមៈ	ឡាយ អឿន ។

ដារ៉ាៈ	ឡាយ អឿន?

គង់ គីមៈ	បាទ!

ដារ៉ាៈ	ចឹងគាត់នៅតែរាល់ថ្ងៃ?

គង់ គីមៈ	អត់ គាត់នៅធ្វើទាហានខេត្តណោះ ។ នៅធ្វើទាហានដែរ ។

ដារ៉ា: នៅខេត្តនោះ?

គង់ គីម: បាទ នៅខេត្តនោះ ។

ខស្នាន: នៅភូមិតាំងក្នុង ។

ដារ៉ា: ភូមិអីភូមិតាំងក្នុង ។

គង់ គីម: តាំងក្នុង ។ ចេស បានវាកម្រអ្នកជួបព្រោះកាលគេបញ្ជូនទៅវ៉ៃគេបញ្ជូនខ្ញុំជាមួយពួកប៉ូពាំនៅហ្នឹងហើយគេបញ្ជូនអ្នកកំពង់ធំ-កំពង់ចាម ។ ដល់ពេលខ្ញុំមកវិញមកនៅណោះវាមកជួបណោះវិញ ។ វាអត់ទៅពីភូមិតាំងអស់គ្នា ។

ខស្នាន: លោកពូសុំសួរមួយទៀតមួយជំនាន់ ដែលលោកពូធ្វើរហូតមកណឹងលោកពូមានដែលគេឲ្យ ថតមានសរសេរប្រវត្តិរូបអីដែរ?

គង់ គីម: ប្រវត្តិរូបធ្វើទ័ពហ្នឹងមាន គេសរសេរក្នុងកង ដូចជាក្នុងកងតូចកងអីក្នុងម្នាក់ៗហ្នឹងមាន ។ មានប្រវត្តិរូបគេ ។

ខស្នាន: លោកពូដែលសរសេរប្រវត្តិរូប គេឲ្យធ្វើប្រវត្តិរូបដែរ?

គង់ គីម: បាទ! គេឲ្យធ្វើប្រវត្តិរូបដែរតើទាហានហ្នឹងធ្វើដែរ ។

ខស្នាន: ធ្វើប៉ុន្មានដងដែរ?

គង់ គីម: គឺសួរទៅទៀត ដូនកាលយើងផ្លាស់កន្លែងមួយកន្លែងគេសួរទៀត គេសួរបញ្ជាក់យើងក្រែងយើងវាផ្លាស់ប្តូរកន្លែងឈ្មោះណឹងដែលយើងជឿដែរតើ ប៉ុនខ្ញុំមិនដឹងម៉េចដល់ចេញពីផ្ទះមក មកដាក់ឈ្មោះហ្នឹង ។

ខស្នាន: គង់ គីមហ្នឹង?

គង់ គីម: បាទ! ប៉ុនជាការពិតរបស់ខ្ញុំណោះទេ កាលណោះដល់ ប៉ុនខ្ញុំមិនដែលទៅលេងផ្ទះទេទៅលេង៩៥ហ្នឹង ។ ទៅម៉ែឪមានស្គាល់ខ្ញុំណាអត់ទេ ។ ខ្ញុំទើបទៅ៩៥ហ្នឹងទេ តាំងពី៧៣ហ្នឹងមក ។

ខស្នាន: ចឹង លោកពូនៅណាមួយរយៈមកហ្នឹងបាត់ប៉ុន្មានឆ្នាំ?

គង់ គីម: នៅហ្នឹងតើ ។

ខស្នាន: ចឹង ពូអត់ទៅផ្ទះ?

គង់ គីម: អត់ទៅ ម៉ែឪមានស្គាល់ខ្ញុំណា ។

ខស្មានៈ ម៉េចបានចឹង បានបែកពីផ្ទះយូរម៉េស?

គង់ គីមៈ បែកកាលហ្នឹង បែកមករហូតដល់យើង៧៩មកហ្នឹងខ្ញុំធ្វើខ្មែរក្រហមហ្នឹងទៀតនោះ ។

ខស្មានៈ អូ! លោកពូធ្វើខ្មែរក្រហមទៀត?

គង់ គីមៈ បាទ! យួនចូលមកនៅខ្មែរក្រហម គេហៅថាកំពតហ្នឹង ៧៩ហ្នឹង ។ ខ្ញុំនៅតាមវៃយួនរហូតហ្នឹង ។

ខស្មានៈ វៃដល់ឆ្នាំណា?

គង់ គីមៈ វៃដល់ឆ្នាំ៨០ខ្ញុំចូលមក វាអត់បាយស៊ីហ្នឹង ដល់ចូលមក ចូលមកស្រុកហ្នឹងគេទទួលចឹងទៅ ។ ខ្ញុំទៅវៀតណាមទទួលខ្ញុំហ្នឹង ។ ដល់វៀតណាម នៅជាមួយវៀតណាមដាំបាយជាមួយវៀតណាមហ្នឹង ឡើងវៃជាមួយវៀតណាម ឡើងវៃ ប៉ុល ពត វិញនោះ ។

ខស្មានៈ ចឹង ធ្វើទាហានវៀតណាមទៀត?

គង់ គីមៈ ធ្វើទាហាន ដល់វៀតណាមគេដកទៅ គេបញ្ជូនទៅលិចខ្ញុំសុំចេញ ។ ដល់សុំចេញខ្មែរគេទទួលខ្ញុំឲ្យធ្វើប្រធានជីវពលឃុំ ។

ខស្មានៈ នៅឃុំនេះ?

គង់ គីមៈ បាទ ឃុំហ្នឹង ដល់ក្រោយមកគេផ្ទេរទៅប៉ូលីសហ្នឹង ។ ដល់ក្រោយខ្ញុំវាដាច់រយៈព្រោះខ្ញុំវាអត់ស្គាល់ផ្លូវស្គាល់អីនោះ មិនដឹងមកតាមណា ចេះតែសួរគេទៅពិបាក ។

ខស្មានៈ អត់ស្គាល់ផ្លូវទៅស្រុកកំណើត?

គង់ គីមៈ បាទ អត់ដឹងទេ មិនដឹងមកតាមណា កាលណោះគេឲ្យដើរតាមព្រៃនោះមានស្គាល់ណាកាល៩៥ហ្នឹងឲ្យគេជូនទៅ ។ ជូនទៅ ប៉ុនខ្ញុំបានចាំឈ្មោះឪពុកខ្ញុំម្តាយខ្ញុំ និងភូមិដល់យកទៅដាក់ទៅម៉ែឪខ្ញុំមានស្គាល់ណា ។ ម៉ែខ្ញុំស្លាប់បាត់នៅតែឪពុក បងប្អូនខ្ញុំអត់ស្គាល់ខ្ញុំទាំងអស់ ។

ខស្មានៈ ម៉េចបានជាឆ្នាំ៨០លោកពូអាចនៅក្នុងភូមិហ្នឹងរហូតមក លោកពូអត់ទៅស្រុក?

គង់ គីមៈ អត់ទៅវានៅសង្គ្រាមនៅតែបាញ់គ្នា នៅតែមានខ្មែរក្រហម អត់នឹកនាផ្ទះ ។

ខស្មានៈ អត់នឹក?

គង់ គីមៈ បាទ! អត់នឹកនាសោះ ។

ជា៖ ចុះពូក្នុងជាជំនាន់ ប៉ុល ពត ពូមានដែលទទួលដំណឹងអីពីអ្នកផ្ទះ?

គង់ គីម៖ ដាច់ម៉ាត់ៗ

ជា៖ ខាងអ្នកផ្ទះក៏អត់មានបានទទួល?

គង់ គីម៖ បាទ! ដាច់ ដែលខ្ញុំទៅជួបគាត់ថាធ្វើបុណ្យម្ដងហើយក្នុងសម័យហ្នឹងៗ ដាច់ម៉ាត់អត់មានអីទាក់ទងគ្នា ទើប៩៥ហ្នឹងទេ តាំងពី៧៣ហ្នឹងមកៗ

ជា៖ គេមិនឲ្យជួបឬក៏យើងមិនចង់ទៅជួបកាលសម័យហ្នឹង?

គង់ គីម៖ ជំនាន់ ប៉ុល ពត អត់មានទេៗ

ជា៖ គេមិនឲ្យ?

គង់ គីម៖ បាទ! ក្នុងនាមរឿងអ្នកស្រុកអ្នកភូមិក្រោយខ្ញុំអត់ដឹងទាំងអស់ ខ្ញុំដឹងតែសាច់ទ័ពបានដឹងរឿងតិចៗ ៗ ក្រោយពីបែកមករឿងប្រជាជនខ្ញុំមិនដឹងទេ ខាងក្រោយ សហករណ៍អីម៉េចៗ អត់ដឹងៗ

ខស្នាន៖ ចុះក្រោយ៩៥ទៀតមានដែលទៅលេងទេ ខស្សាហ៍ទៅទេ?

គង់ គីម៖ ទេ ចាប់ពី៩៥ទៅ ទៅលេងបាន៣ដងហើយ ទៅលេងភូមិនោះៗ

ខស្នាន៖ អរគុណច្រើនពូណាៗ

គង់ គីម៖ បាទ!

ដារ៉ា៖ អរគុណច្រើនដែលពូបានជួយផ្ដល់ការសម្ភាសន៍ៗ ចុះរាល់ថ្ងៃលោកពូមានបានដឹងពត៌ខ្លះទេពីរឿងរដ្ឋាភិបាលបង្កើតច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមអីណឹងពូ ពូមានបានពត៌បានស្ដាប់?

គង់ គីម៖ បាទ! បានពត៌ ស្ដាប់ដែរ ស្ដាប់តាមវិទ្យុទូរទស្សន៍អីហ្នឹងៗ

ដារ៉ា៖ ចុះលោកពូយល់ម៉េចដែរ?

គង់ គីម៖ ខ្ញុំថាបើកាលណឹងកាត់ទោសមេខ្មែរក្រហមពិតជាត្រឹមត្រូវហើយ ព្រោះកាលហ្នឹងខ្ញុំបានមើលឃើញនឹងភ្នែកដែរ កាលធ្វើទុក្ខធ្វើទោស ហើយខ្ញុំមកហ្នឹង មកនៅនឹងស្រុកភូមិនឹងហើយៗ បើនិយាយពីរណ្ដៅតាមហ្នឹងទៅមើលៗ និយាយពីសុទ្ធតែលលាដ៍ខ្មោចៗ

ខស្នាន៖ នៅណា?

គង់ គីមៈ នេះភ្នំនេះ ហើយនេះភូមិចាស់តាំងព្រិចនេះ ។ ក្បាលខ្មោចមួយរណ្ដៅៗអត់តិចទេ ។ បាទ! ហ្នឹងជាក់ស្ដែងដែលឆ្នាំ៨១ហើយខ្ញុំមកនៅហ្នឹង ជួបតែក្បាលខ្មោចហើយជួបតាមប្រជាពលរដ្ឋណឹង ថាសុទ្ធតែរណ្ដៅវ៉ៃ ។ សុទ្ធតែវ៉ៃពួកសំខាន់ៗស្លាប់អស់ច្រើននៅបូព៌ាហ្នឹង ហើយនឹងមូលដ្ឋានថ្មី ហ្នឹងអត់សល់ទេ ហ្នឹងជម្លៀសពីភ្នំពេញហ្នឹង ។ ទើបមកដឹងចឹងទេ សល់តិចណាស់ សល់តែអ្នកដែលគេជួលាក់ជួយលាមមួយពីរ ។

ដារ៉ាៈ ចឹងពូមានការសប្បាយចិត្ត បើសិនជាមានការកាត់ទោសមេដឹកនាំខ្មែរក្រហម?

គង់ គីមៈ បាទ! ព្រោះជាការពិតព្រោះខ្ញុំ ។

ដារ៉ាៈ ចុះពូអត់មានការភ័យខ្លាចអីទេ ព្រោះពូធ្លាប់បម្រើខ្មែរក្រហមអីចឹងដែរ?

គង់ គីមៈ ភ័យខ្លាចអីកាលណោះខ្ញុំនៅក្រោមគេដែរហ្នឹង ព្រោះកាលហ្នឹងត្រូវតែធ្វើមិនដូចយើងឥឡូវទេ ព្រោះកាលហ្នឹងត្រូវតែធ្វើចឹង ។

ដារ៉ាៈ ពូមានដឹងថារាល់ថ្ងៃណឹងមានរឿងអីកើតឡើងចំពោះការចរចាគ្នាឲ្យមានតុលាការទេពូ?

គង់ គីមៈ អត់ ខ្ញុំអត់សូវដឹងដែរ ។

ដារ៉ាៈ ព្រោះរាល់ថ្ងៃនេះ តុលាការហាក់ដូចជាមានការទ្រើងបន្តិច នៅពេលដែលខាងUN ដូចថាដកខ្លួនមិនចរចារការបង្កើតតុលាការហ្នឹង ពូគិតថាចង់ឲ្យមានការកាត់ទោសហ្នឹងឆាប់ៗដែរ?

គង់ គីមៈ ខ្ញុំចង់ឲ្យកាត់ទោសឆាប់ៗហ្នឹងដែរ បើតាមចិត្តខ្ញុំធ្លាប់ដឹងធ្លាប់ឃើញ ។ បើទុកយូរទៅដូចជាបាត់បង់វាសាប បើកាត់ទោសឥឡូវដូចថាមានអ្នកដែលកើតទាន់ជំនាន់នោះអាចឃើញជាក់ស្ដែងឃើញការពិត ហើយបើទុកឲ្យយូរទៅក្មេងក្រោយគ្រាន់តែប្រវត្តិសាស្ត្រនិយាយ រីឯការជាក់ស្ដែងឃើញនឹងចូលរួមខ្វះអ់ដឹងទេ ។

ខស្មានៈ ពូ ហ៊ានទៅនិយាយទេ បើឧបមាថាតុលាការត្រូវការលោកពូធ្វើជាសាក្សីនិយាយពីការងារដែលពូឃើញដូចនិយាយប្រាប់ខ្ញុំចឹង?

គង់ គីមៈ បាទ ថីហ៊ាននិយាយបើអានេះមិនមែនខ្ញុំយករឿងគេនិយាយ ខ្ញុំឃើញជាក់ស្ដែងអត់មាននិទានអីគឺការពិត ។ ចូលរួមចំណែកទាំងការងាររួមចំណែកជាក់ស្ដែងខ្លួនឯងផង ។ ឃើញជាក់ស្ដែងហើយខ្ញុំក៏ចូលរួមការលំបាកដែរ ។ វាមិនបានវ៉ៃខ្ញុំចោលទេ ចូលរួមការគាបសង្កត់ធ្វើទារុណកម្មគាបបាយគាបទឹកអី វាមានជាក់ស្ដែងចឹង ។ ដូចខ្ញុំប្រាប់ចឹង

តាំងពីឆ្នាំ៧៣ទល់៩៥បានខ្ញុំទៅ លេងផ្ទះហើយម៉ែឪមានស្គាល់អត់ទេ ។ បែកដល់ជំនាន់ហ្នឹង ។

ខស្នានៈ ចុះម៉ែឪឃើញស្គាល់ទេ?

គង់ គីមៈ អត់ស្គាល់ទេ ។

ខស្នានៈ ហើយនិយាយធ្វើម៉េចបានស្គាល់?

គង់ គីមៈ ទាល់ខ្ញុំមកវិញ គាត់ហៅឈ្មបទៅការពារខ្មាចខ្ញុំទៅប្ងន់ ។ មកវិញបានខ្ញុំទៅម្តងទៀត ទៅយកប្រវត្តិដែលខ្ញុំអាចចាំនិយាយពីហេតុផលខ្ញុំចេស ៗ គេឲ្យធ្វើនិរសារអីចឹង ខ្ញុំដាក់វត្ថុដាក់អីចឹងដល់យូរ ៗ ទៅ ហើយបងប្អូនខ្ញុំអត់ដូចខ្ញុំទេ គេខ្ពស់ទាំងអស់ គេធំ គេកើតក្រោយដូចថាគេអត់មានការពលកម្មនោះ ។ ខ្ញុំចេញទៅហ្នឹងខ្ញុំទម្ងន់ជាប់ហើយក្រិន ។

ខស្នានៈ ដល់ក្រោយមកគាត់ទទួលស្គាល់វិញ?

គង់ គីមៈ បាទ! ដល់ក្រោយហេតុផល ដែលគាត់ចង់ពិសោធន៍យើងសួរហេតុផលដែលយើងបញ្ជាក់ហេតុផលដែលយើងចាំបានគាត់ទទួលស្គាល់ បានទទួលស្គាល់បានថាយើងដូច ។

ដារ៉ាៈ ពូ មានដឹងថាតុលាការហ្នឹង មានការចូលរួមរបស់អង្គការសហប្រជាជាតិ មួយប្រភេទទៀត អាចថាមិនមានការចូលរួមពូ ពូចង់បានប្រភេទយ៉ាងម៉េច បើតាមគំនិតរបស់លោកពូផ្ទាល់?

គង់ គីមៈ អត់យល់ មើលសួរម្តងទៀត?

ដារ៉ាៈ ចេស ព្រោះរាល់ថ្ងៃហ្នឹងមានការចរចារគ្នាថា នឹងមានការចូលរួមពីអង្គការសហប្រជាជាតិ និងអង្គការ?

គង់ គីមៈ ដើម្បីកាត់ទោស?

ដារ៉ាៈ ដល់ពេលក្រោយមកទៅអង្គការសហប្រជាជាតិបានដកខ្លួនមិនចរចារ បើតាមយោបល់ពូចង់បានតុលាការមួយ ដែលមានការចូលរួមពីអង្គការសហប្រជាជាតិ ឬតុលាការមួយដែលបង្កើត ឡើងដោយរដ្ឋាភិបាលកម្ពុជាតែឯងចឹង?

គង់ គីមៈ វាមិនទាន់ដឹងថា ខ្លឹមសារថាអង្គការដែលចូលរួម មិនដឹងខ្លឹមសារមានន័យថាម៉េចអង្គការសហប្រជាជាតិមិនដឹងគេបង្កើតតុលាការរបៀបម៉េចវាអត់ដឹងចឹង ។

ខស្នានៈ តើលោកពូគិតថា តើមួយណាដែលចង់បានជាង?

ដារ៉ាៈ ចង់ដឹងពូ ចង់ដឹងថា បើសិនជាតុលាការមួយកើតឡើងសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមហ្នឹងបើសិនជាមានខាងអង្គការសហប្រជាជាតិចូលរួមវាប្រសើរជាងអត់ ខ្ញុំចង់សួរចឹង?

គង់ គីមៈ ប៉ុន យើងធ្វើការស្រាវជ្រាវជាងហ្នឹងខាង ។

ដារ៉ាៈ គ្រាន់តែចង់ដឹងគំនិតរបស់ពូផ្ទាល់ដូចជាការសួរនាំខាងក្រៅទេ ហ្នឹងអត់ចូលរួមការងារខ្ញុំទេហ្នឹងនោះ ។

គង់ គីមៈ មិនដឹងយល់ថាម៉េចដែរបើអត់ដឹង ។

ខស្មានៈ អត់អីទេ ។

គង់ គីមៈ បើនិយាយពីរឿងកាត់ទោសខ្ញុំនិយាយគាំទ្រហ្មង ប៉ុន្តែន័យថាអង្គការសហប្រជាជាតិចូលរួមមិនដឹងមានន័យថាម៉េច ហើយអត់ចូលរួមមិនដឹងជាខ្លឹមសារយ៉ាងម៉េច? ។

ខស្មានៈ អរគុណច្រើនពូណាដែលបានជួយនិយាយរឿងរ៉ាវសំខាន់ប្រាប់ខ្ញុំច្រើន ។

ដារ៉ាៈ បើមានការខ្វះខាតត្រង់ចំណុចណាមួយពួកខ្ញុំអាចមកសួរនាំលោកពូបានទៀត ។ លោកពូនៅស្វាគមន៍ពួកខ្ញុំទេ?

គង់ គីមៈ បាទ មានអី ។

ខស្មានៈ ព្រោះមកច្រើនដងហើយទម្រាំបានជួបពូ មកពីរបីដងហើយ ។

ចប់